

# ការបណ្តេញចេញ និងការតាំងទីលំនៅថ្មី

## ខែមិថុនា ឆ្នាំ២០២០

*ការសិក្សាស្រាវជ្រាវពីដំណើរការនៃការបណ្តេញចេញ និងការតាំងទីលំនៅថ្មីក្នុងរាជធានីភ្នំពេញ*

សមាគមធាងត្នោត
Sahmakum Teang Tnaut. a Cambodian Urban NGO

# អង្គការសមាគមធាងត្នោត

អង្គការសមាគមធាងត្នោត (STT) ត្រូវបានបង្កើតក្នុងឆ្នាំ២០០៥ និងត្រូវបានចុះបញ្ជីជាអង្គកាមិនមែនរដ្ឋាភិបាលក្នុងស្រុកជួយគាំទ្រដល់សហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញនៅឆ្នាំ២០០៦។ អង្គការសមាគមធាងត្នោតចាប់ផ្តើមជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលផ្តោតទៅលើការជួយលើកកម្ពស់ផ្នែកបច្ចេកទេសដល់សហគមន៍ក្រីក្រ និងបន្ទាប់មកចាប់ផ្តើមលូតលាស់ខ្លួន ដោយផលិតជាផែនទីសហគមន៍ក្រីក្រ ការសិក្សាស្រាវជ្រាវ និងការតស៊ូមតិ ដើម្បីសម្រេចគោលដៅរបស់ខ្លួនក្នុងការជួយដល់សហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញឱ្យទទួលបានសិទ្ធិដីធ្លី និងសិទ្ធិលំនៅឋាន។


## ការសិក្សាស្រាវជ្រាវនេះបានការគាំទ្រមូលនិធិពី៖

HEINRICH BÖLL STIFTUNG
ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា



សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក សឿង សារ៉ន នាយកប្រតិបត្តិនៃអង្គការសមាគមធាងត្នោត

ទូរសព្ទលេខ៖ (៨៥៥) ២៣ ៥៥៥ ១៩ ៦៤

អ៊ីម៉ែល៖ info@teangtnaut.org

គេហទំព័រ៖ www.teangtnaut.org ហ្វេសប៊ុក៖ https://www.facebook.com/teangtnaut

ហ្វីទ័រ៖ https://twitter.com/teangtnaut

# មាតិកា


**ពន្យល់ពាក្យសំខាន់**............iii
**បញ្ជីពាក្យកាត់**............v
**១. សេចក្ដីសង្ខេប**............**១**
**២. វិធីសាស្ត្រស្រាវជ្រាវ**............**៥**
២.១. គោលបំណង............៥
២.២. ទំហំ និងលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស............៥
២.៣. ការប្រមូលព័ត៌មាន............៦
២.៤. យេនឌ័រ............៧
២.៥. ដែនកំណត់............៧
**៣. សាវតានៃការបណ្ដេញចេញ និងការផ្លាស់ប្ដូរទីតាំងលំនៅថ្មីក្នុងរាជធានីភ្នំពេញ និងប្រទេសកម្ពុជា**............**៩**
៣.១. បរិបទប្រវត្តិសាស្ត្រ............៩
៣.២. ក្របខ័ណ្ឌគតិយុត្តិ............៩
៣.៣. ការពិនិត្យមើលឯកសារពាក់ព័ន្ធផ្សេងៗ............១៥
**៤. ការរកឃើញសំខាន់ៗ**............**១៩**
៤.១. ការបណ្ដេញចេញ និងការផ្លាស់ប្ដូរទីតាំងលំនៅថ្មី............១៩
៤.២. ដំណើរការនៃការបណ្ដេញចេញ............២១
៤.២.១. មូលហេតុនៃការបណ្ដេញចេញ............២១
៤.២.២. ការយល់ព្រម ការបង្ខិតបង្ខំ និងការរួបរួមគ្នារបស់សហគមន៍............២២
៤.២.៣. ការជូនដំណឹងមុនពេលបណ្ដេញចេញ............២៣
៤. ៣. អំឡុងពេលបណ្ដេញចេញ............២៦
៤.៣.១. ការប្រឹក្សាយោបល់ និងការចូលរួមពីភាគីពាក់ព័ន្ធ............២៦
៤.៣.២. ពេលវេលានៃការបណ្ដេញចេញ............២៦
៤.៣.៣. អាជ្ញាធរទទួលខុសត្រូវការបណ្ដេញចេញ និងទំនាស់............២៧
៤.៣.៤. ការបណ្ដេញចេញដោយហិង្សា............២៧
៤.៣.៥. ការគំរាមកំហែង ឬការបំភិតបំភ័យ............២៨
៤.៣.៦. ការមិនទទួលបានការយកចិត្តទុកដាក់............២៩
៤.៣.៧. សំណង............២៩
៤.៤. ដំណើរការនៃការតាំងទីលំនៅថ្មី............៣១
៤.៤.១. មូលហេតុនៃការផ្លាស់ទីលំនៅថ្មី............៣១
៤.៤.២. ការរៀបចំតំបន់តាំងទីលំនៅថ្មី............៣១
៤.៤.៣. ការរៀបចំ ឬភាពអាចរស់នៅបាននៅពេលទៅដល់ទីតាំងលំនៅថ្មី............៣២
៤.៤.៤.ការរៀបចំ និងភាពអាចរស់នៅបាន នៅក្នុងឆ្នាំ ២០១៩............៣៣
៤.៤.៥. ការយល់ឃើញរបស់សហគមន៍ពីភាពខុសគ្នារវាងទីតាំងថ្មី និងទីតាំងចាស់............៣៤
៤.៤.៦. ចម្ងាយរវាងតំបន់តាំងលំនៅចាស់ និងតំបន់តាំងលំនៅថ្មី............៣៧
៤.៤.៧. សុវត្ថិភាព និងសន្តិសុខអំឡុងពេលផ្លាស់ទីតាំងលំនៅថ្មី និងនៅតំបន់តាំងលំនៅថ្មី....៣៧
៤.៤.៨. បំណុល............៣៩

៤.៥. យេនឌ័រ........................................................................................................៤០
៤.៦. ការធ្វើឱ្យប្រសើរឡើងនូវដំណើរការទាំងនេះ.......................................................................៤១
៤.៦.១. សំឡេងរបស់ម្ចាស់សិទ្ធិ ស្តីពីការបណ្តេញចេញ និងការផ្លាស់ប្តូរទីតាំងលំនៅថ្មី.........៤១
**៥.សេចក្តីសន្និដ្ឋាន..........................................................................................................៤២**
**៦.អនុសាសន៍................................................................................................................៤៤**

## តារាង និងក្រាហ្វិច

តារាងទី ១៖ សហគមន៍ដែលចូលរួមក្នុងការសិក្សាស្រាវជ្រាវ........................................................៥
តារាងទី ២៖ អ្នកចូលរួមផ្តល់ចម្លើយសំខាន់ៗ.............................................................................៦
តារាងទី ៣៖ ភេទរបស់អ្នកចូលរួមសម្ភាស................................................................................៧
តារាងទី ៤៖ ការបណ្តេញចេញតាមឆ្នាំ....................................................................................១៩
តារាងទី ៥៖ ហេតុផលក្នុងការបណ្តេញចេញ..............................................................................២២
តារាងទី ៦៖ ការជូនដំណឹងមុនពេលបណ្តេញចេញ.......................................................................២៤
តារាងទី ៧៖ ការផ្តល់លក្ខណៈសំខាន់ៗដល់តំបន់តាំងទីលំនៅថ្មី.....................................................៣២
តារាងទី ៨៖ ការប្រៀបធៀបលក្ខណៈនៃតំបន់តាំងទីលំនៅថ្មីនៅពេលរស់នៅដំបូង និងនៅឆ្នាំ២០១៩............៣៣
តារាងទី ៩៖ ចម្ងាយពីតំបន់តាំងទីលំនៅថ្មី ទៅទីតាំងសំខាន់ៗ........................................................៣៦
តារាងទី ១០៖ ការប៉ាន់ប្រមាណការជំពាក់បំណុល (សហគមន៍ទាំងមូល).............................................៣៩
ក្រាហ្វិចទី ១៖ ការបណ្តេញចេញក្នុងរយៈពេលកន្លងមក (ឆ្នាំ១៩៨០ ដល់ឆ្នាំ២០១៩)..................................២០
ក្រាហ្វិចទី ២៖ ក្បាលដីដែលផ្តល់ជាសំណង.............................................................................៣០
ក្រាហ្វិចទី ៣៖ ភាពអាចរស់នៅបាននៅពេលមកដល់ និងនៅឆ្នាំ២០១៩............................................៣៤

## ពន្យល់ពាក្យសំខាន់ៗ

**ការបណ្តេញចេញ៖** សំដៅទៅលើនីតិវិធីដែលអាជ្ញាធររដ្ឋបង្គាប់ឱ្យប្រជាពលរដ្ឋចេញពីលំនៅឋាន ឬដីធ្លីរបស់ពួកគេ។

**ដំណើរការនៃការបណ្តេញចេញ៖** ការកំណត់សហគមន៍មួយដែលត្រូវបានជូនដំណឹងជាផ្លូវការអំពីការបណ្តេញចេញ ប៉ុន្តែនៅមិនទាន់បានបណ្តេញចេញ ហើយកំពុងរង់ចាំ ឬកំពុងធ្វើការពិភាក្សាអំពីការបណ្តេញចេញ។

**ការបណ្តេញចេញដោយបង្ខំ៖** ដូចការបណ្តេញចេញដែរ ប៉ុន្តែមានការប្រើប្រាស់ហិង្សា ឬកម្លាំងជាទូទៅលើរាងកាយដោយអាជ្ញាធររដ្ឋ ដើម្បីបង្ខំប្រជាពលរដ្ឋឱ្យចេញពីលំនៅឋាន ឬដីធ្លីរបស់ពួកគេ។

**ការផ្លាស់ប្តូរទីតាំងលំនៅថ្មី៖** ការផ្លាស់ប្តូរទីតាំងលំនៅថ្មី គឺជាពាក្យដែលត្រូវបានប្រើប្រាស់នៅក្នុងការសិក្សានេះ ជាជាងការតាំងទីលំនៅថ្មី។ ការផ្លាស់ប្តូរទីតាំងលំនៅថ្មី សំដៅទៅលើការយកប្រជាពលរដ្ឋពីតំបន់មួយឱ្យទៅរស់នៅតំបន់មួយផ្សេងទៀត ប៉ុន្តែមិនមានការផ្តល់នូវការគាំទ្រណាមួយ ដូចជាការសាងសង់ផ្ទះសម្បែងថ្មី ដីថ្មី ឬហេដ្ឋារចនាសម្ព័ន្ធនៅទីតាំងនោះទេ។

**ការតាំងទីលំនៅថ្មី៖** ការតាំងទីលំនៅថ្មី មានន័យដូចនឹងការផ្លាស់ប្តូរទីតាំងលំនៅថ្មីដែរ ប៉ុន្តែរួមបញ្ចូលហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចជាផ្ទះ ឬហេដ្ឋារចនាសម្ព័ន្ធដទៃទៀត ឬការតាំងទីលំនៅ នៅលើតំបន់ធ្លាប់រស់នៅពីមុន។ ភាពខុសគ្នារវាងការតាំងទីលំនៅថ្មី និងការផ្លាស់ប្តូរទីតាំងលំនៅថ្មី គឺថាការតាំងទីលំនៅថ្មីស្ថិតក្នុងតំបន់មានហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត រីឯការផ្លាស់ប្តូរទីតាំងលំនៅថ្មី ស្ថិតក្នុងតំបន់ដែលមិនមានហេដ្ឋារចនាសម្ព័ន្ធ។

**សហគមន៍៖** ប្រជាពលរដ្ឋដែលរស់នៅក្បែរគ្នា ដែលបង្កើតជាក្រុមមនុស្សមួយដោយផ្ទាល់ ឬដោយប្រយោល។ ដូចនេះ ពាក្យថាអ្នកដឹកនាំសហគមន៍មិនមែនមានន័យថា អ្នកនោះត្រូវបានគេបោះឆ្នោតឱ្យ ឬជាអ្នកនយោបាយនោះទេ។

**អាជ្ញាធរ៖** សំដៅទៅលើបុគ្គលដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យអនុវត្តការងារក្នុងនាមរាជរដ្ឋាភិបាល។ ពាក្យនេះមានន័យទូលំទូលាយ ដែលត្រូវបានប្រើប្រាស់នៅក្នុងស្ថានភាពមិនច្បាស់លាស់ថា តើអាជ្ញាធរណាមួយដែលកំពុងអនុវត្តការងារ។

**ទ្រព្យសម្បត្តិសាធារណៈ៖** ទ្រព្យសម្បត្តិ ឬដីធ្លីដែលជាកម្មសិទ្ធិរបស់រដ្ឋ ជាពិសេសដូចបានចែងនៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ ព្រះរាជក្រឹត្យ និងអនុក្រឹត្យផ្សេងៗទៀត។ ទ្រព្យសម្បត្តិសាធារណៈអាចសំដៅទៅលើទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដែលពាក្យនេះត្រូវបានប្រើប្រាស់នៅក្នុងច្បាប់ភូមិបាលឆ្នាំ ២០០១។

**លំនៅឋាន៖** សំដៅទៅលើសំណង់សម្រាប់រស់នៅ ដែលមិនអាចផ្លាស់ទីបាន និងមិនមែនគ្រាន់តែជាទីជម្រក។

ជម្រក៖ សំដៅទៅលើទីលំនៅដែលសាងសង់មិនបានរឹងមាំ ហើយអាចផ្លាស់ទីបាន ឬងាយស្រួលរុះរើចេញវិញ ដោយប្រើរយៈពេលខ្លី ឬត្រូវបានសាងសង់ឡើង ដោយមិនមានគោលបំណងស្នាក់នៅជាអចិន្ត្រៃយ៍។ ឧទាហរណ៍៖ ការសាងសង់ដោយប្រើតង់។

**លំនៅឋានសមរម្យ៖** ជាការផ្តល់លំនៅឋានដែលស្របនឹងគោលការណ៍សំខាន់នៃ "លំនៅឋានសមរម្យ" របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស។[១] លំនៅឋានសមរម្យរួមមាន (១)សុវត្ថិភាពក្នុងការកាន់កាប់ (២)ការមាននូវសេវាសាធារណៈសម្ភារៈបរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធនានា (៣)ភាពអាចលៃលកទិញបាន (៤)ភាពអាចរស់នៅបាន (៥)ភាពងាយស្រួលចូលទៅដល់ទីតាំង (៦)ទីតាំងអំណោយផលដល់កត្តាផ្សេងៗទៀត ជាពិសេសកត្តាឱកាសទទួលបានការងារធ្វើ និង (៧)ភាពគ្រប់គ្រាន់ផ្នែកវប្បធម៌។[២]

---

[១] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស ប័ណ្ណព័ត៌មាន២១ សិទ្ធិមានលំនៅឋានសមរម្យ ខែវិច្ឆិកា ឆ្នាំ២០០៩ Fact Sheet លេខ២១/Rev.១

[២] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស ប័ណ្ណព័ត៌មាន២១ សិទ្ធិមានលំនៅឋានសមរម្យ ខែវិច្ឆិកា ឆ្នាំ ២០០៩ Fact Sheet លេខ២១/Rev.១

# បញ្ជីពាក្យកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CEDAW | អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី |
| CMW | អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់ពលករចំណាកស្រុកគ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ |
| CRC | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| CRPD | អនុសញ្ញាស្តីពីសិទ្ធិជនពិការ |
| EDC | អគ្គិសនីកម្ពុជា |
| ICERD | អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ |
| ICESCR | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ |
| MFI | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬអ្នកផ្តល់កម្ចីខ្នាតតូច |
| MPP | សាលារាជធានីភ្នំពេញ |
| NHP | គោលនយោបាយជាតិស្តីពីលំនៅឋាន |
| OHCHR | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៅកម្ពុជា |
| PPWSA | រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| STT | អង្គការសមាគមធាងត្នោត |
| UDHR | សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស |
| UN | អង្គការសហប្រជាជាតិ |

## ១. សេចក្តីសង្ខេប

*"យើងរស់នៅដូចមនុស្សគ្មានផ្ទះសម្បែង"។*
*ប្រជាពលរដ្ឋដែលត្រូវបានគេបណ្តេញចេញទទួលបានតង់មួយ និងត្រូវបានគេនាំទៅនៅលើស្ពានច្បារ។*

ការបណ្តេញចេញ និងការផ្លាស់ប្តូរទីតាំងលំនៅថ្មី គឺជាបញ្ហារ៉ាំរ៉ៃដែលបានបង្កផលវិបាកដ៏ធ្ងន់ធ្ងរដល់សហគមន៍ក្រីក្រនៅក្នុងរាជធានីភ្នំពេញ។ សិទ្ធិទទួលបានលំនៅឋាន គឺជាសិទ្ធិមនុស្សជាមូលដ្ឋាន ហើយក៏ជាសិទ្ធិដែលជាញឹកញាប់ ត្រូវបានគេមិនខ្វាយខ្វល់ នៅក្នុងនីតិវិធីនៃការបណ្តេញចេញ និងផ្លាស់ប្តូរទីតាំងលំនៅឋាន។ ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០ នៅក្នុងរាជធានីភ្នំពេញ គេឃើញមានការបណ្តេញចេញ និងការផ្លាស់ប្តូរទីតាំងលំនៅថ្មីនៃសហគមន៍យ៉ាងតិចណាស់ចំនួន៥០ករណី ដែលស្មើនឹងប្រមាណ៩.៨៣២គ្រួសារ ឬច្រើនជាង៤០.០០០នាក់ដែលភាគច្រើនបាន និងបន្តទទួលរងផលវិបាកពីការបណ្តេញចេញ និងការផ្លាស់ប្តូរទីតាំងលំនៅថ្មី។ ការជំពាក់បំណុលការបាត់បង់ជីវភាព ការរងរបួសលើរាងកាយ កង្វះសេវាគាំពារសុខភាព និងសេវាអប់រំគ្រាន់តែជាឧទាហរណ៍មួយ ចំនួនប៉ុណ្ណោះ ដែលគ្រួសាររងផលប៉ះពាល់ជួបប្រទះនៅក្នុងការតស៊ូការពារសិទ្ធិមានលំនៅឋានរបស់ពួកគេ។ ការសិក្សាស្រាវជ្រាវនេះមានគោលបំណងបង្ហាញពីរឿងរ៉ាវរបស់អ្នកទាំងនោះលើកឡើងពីបញ្ហារំលោភសិទ្ធិមនុស្ស និងផ្តល់អនុសាសន៍ ដើម្បីធ្វើឱ្យប្រសើរឡើងនូវនីតិវិធីនៃការបណ្តេញចេញ និងការផ្លាស់ប្តូរទីតាំងលំនៅថ្មីនាថ្ងៃអនាគត។

និន្នាការនៃការបណ្តេញចេញចាប់ពីចុងទសវត្សរ៍ឆ្នាំ១៩៩០ បង្ហាញឱ្យឃើញជាទូទៅថា ការបណ្តេញចេញកើតមានតិចតួចនៅក្នុងឆ្នាំបោះឆ្នោត។ ការបង្កើតច្បាប់ភូមិបាលកាលពីឆ្នាំ២០០១ ក៏បានផ្តល់នូវទម្ងន់ផ្នែកច្បាប់ដល់ការបណ្តេញចេញសហគមន៍ជាច្រើន ដោយលើកមូលហេតុថាសហគមន៍ទាំងនោះបានកាន់កាប់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។ ការកាន់កាប់ទ្រព្យសម្បត្តិសាធារណៈគឺជាមូលហេតុចម្បងនៃការបណ្តេញចេញជាង៧០% ដែលបានផ្តល់បទសម្ភាស។ ទោះជាមានការទទួលស្គាល់ និងការការពារសិទ្ធិទទួលបានលំនៅឋាន និងសិទ្ធិកាន់កាប់ដីធ្លីដោយរដ្ឋធម្មនុញ្ញក៏ដោយ ក៏អាជ្ញាធរនៅតែបរាជ័យក្នុងការផ្តល់លំនៅឋានសមរម្យនៅទីតាំងថ្មី ហើយក៏មានសមាជិកសហគមន៍ខ្លះទទួលបានតែតង់ ខ្លះទៀតមិនទទួលបានអ្វីសោះនៅពេលពួកគេមកដល់ទីតាំងថ្មីនោះ។ នៅក្នុងការបណ្តេញចេញ និងការផ្លាស់ទៅទីតាំងថ្មី ចំនួន៥០ករណី ដែលបានសិក្សាមិនមានករណីណាមួយទទួលបានការផ្តល់លំនៅឋានសមរម្យ បន្ទាប់ពីសហគមន៍ទៅដល់ទីតាំងថ្មីនោះទេ។[៣]

ដំណើរការនៃការបណ្តេញចេញត្រូវបានសង្កេតឃើញថា ជាទូទៅគឺជាបទពិសោធន៍ដ៏តក់ស្លុតសម្រាប់អ្នកផ្តល់បទសម្ភាសជាច្រើន ដែលត្រូវបានគេបណ្តេញចេញ ហើយអាជ្ញាធរហាក់ដូចជាមិនបានគិតគូរពីគោលការណ៍សិទ្ធិមនុស្សនៅពេលផ្តល់ការអនុញ្ញាតឱ្យធ្វើការបណ្តេញចេញទាំងនោះ។ នៅក្នុងករណីជាងពាក់កណ្តាលនៃការបណ្តេញចេញដែលបានសិក្សា ការជូនដំណឹងជាមុន (ដែលជាគោលការណ៍មួយអនុញ្ញាតឱ្យសហគមន៍មានពេលវេលាគ្រប់គ្រាន់ដើម្បីត្រៀមខ្លួនតតាំងផ្នែកច្បាប់ រៀបចំ និងចូលរួមក្នុងការប្រឹក្សាយោបល់) មិនត្រូវបានផ្តល់ឱ្យអ្នកផ្តល់បទសម្ភាសឱ្យបានឆាប់រហ័សដើម្បីទុកពេលវេលាគ្រប់គ្រាន់ឱ្យពួកគេរៀបចំខ្លួននោះទេ។ ក្នុងករណីចំនួន០៩ នៃការបណ្តេញចេញត្រូវបានធ្វើឡើងដោយហិង្សាដោយមាននគរបាល ឬកងរាជអាវុធហត្ថប្រើប្រាស់ដំបងវាយ ឬគំរាមកំហែងទៅលើប្រជាពលរដ្ឋ ប្រសិនបើពួកគេមិនព្រមចាកចេញភ្លាមៗទេនោះ។ ការគ្រប់គ្រងប្រភពធនធានក៏ត្រូវបានប្រើប្រាស់ជាមធ្យោបាយសម្រាប់ប្រឆាំងនឹងសមាជិកសហគមន៍ ដែលមិនព្រមធ្វើតាមការទាមទាររបស់អាជ្ញាធរផងដែរ។ ជាក់ស្តែង នៅក្នុងករណីមួយ សហគមន៍មិនមានអគ្គិសនីប្រើប្រាស់ បន្ទាប់មកលែងមានទឹកប្រើប្រាស់មុនពេលត្រូវបានគេបណ្តេញចេញទាំងកណ្តាលយប់នៅពេលដែលមានអគ្គីភ័យ។

---

[៣] ការសិក្សាសរុបមានសំណាកចំនួនន ៦៨ករណីនៃការបណ្តេញចេញ និងការតាំងទីលំនៅថ្មី។ ប៉ុន្តែមានត្រឹមតែចំនួន ៥០ករណីប៉ុណ្ណោះដែលត្រូវបានបណ្តេញចេញ និងតាំងទីលំនៅថ្មី។

និន្នាការបច្ចុប្បន្ននេះ បង្ហាញថាអាជ្ញាធរបានប្រើប្រាស់វិធីសាស្ត្រមួយផ្សេងទៀត ដែលផ្តល់ផលទាំងវិជ្ជមាន និងអវិជ្ជមាន។ ផលវិជ្ជមាន គឺអាជ្ញាធរមិនបានប្រើប្រាស់ហិង្សាទៅលើសហគមន៍ក្នុងដំណើរការនៃការបណ្តេញចេញក្នុងរយៈពេល៥ឆ្នាំ ចុងក្រោយនេះ។ លើសពីនេះ "សហគមន៍នៅតាមផ្លូវរថភ្លើង" បានរាយការណ៍ថា សារាចរលេខ០៣ (ដែលជាសេចក្តីណែនាំដល់អាជ្ញាធរឱ្យអនុវត្តនីតិវិធីបណ្តេញចេញ និងផ្លាស់ប្តូរទីតាំងលំនៅថ្មី ស្របនឹងគោលការណ៍សិទ្ធិមនុស្សនានា) ត្រូវបានគេយកមកប្រើប្រាស់នៅក្នុងការបណ្តេញចេញ និងការផ្លាស់ទៅទីតាំងថ្មីរបស់ពួកគេ ដែលនេះជាករណីមួយក្នុងចំណោមករណីកម្រដែលសេចក្តីណែនាំត្រូវបានប្រើប្រាស់។ ចំណែកឯផលអវិជ្ជមាន គឺការអនុវត្តយុទ្ធសាស្ត្រ "ត្រូវតែផ្លាស់ទៅទីតាំងថ្មី ឬប្រើវិធីផ្សេងៗ" ដែលធ្វើឱ្យសហគមន៍ចាកចេញដោយខ្លួនឯង ព្រោះភ័យខ្លាចអាជ្ញាធរខឹង ប្រសិនបើពួកគេមិនស្តាប់តាមសេចក្តីបង្គាប់របស់អាជ្ញាធរ។ នៅក្នុងអំឡុងឆ្នាំ២០១៨ និងឆ្នាំ២០១៩ សហគមន៍មួយចំនួនដែលរស់នៅលើដីសាធារណៈរបស់រដ្ឋ ជារឿយៗត្រូវបានគេបណ្តេញចេញដោយមិនបានយល់ដឹងច្បាស់អំពីសិទ្ធិរបស់ពួកគេ ឬមិនបានជូនដំណឹងមុនរយៈពេល ៩០ថ្ងៃ។

ទីតាំងលំនៅថ្មី ដែលបានផ្តល់ដល់សហគមន៍ថ្មីៗនេះក៏ហាក់ដូចជាស្របនឹងគោលការណ៍សិទ្ធិមនុស្សជាងទីតាំងដែលបានផ្តល់ដល់សហគមន៍ក្នុងអំឡុងពេល២៥ឆ្នាំ កន្លងមកនេះ។ ប៉ុន្តែ ក្តីបារម្ភចម្បងរបស់សមាជិកសហគមន៍ដែលរើលំនៅឋាន គឺចម្ងាយឆ្ងាយពីទីតាំងថ្មីទៅកណ្តាលរាជធានីភ្នំពេញ ឬចម្ងាយឆ្ងាយពីកន្លែងដែលពួកគេធ្លាប់រស់នៅទៅទីតាំងថ្មី។ នាពេលបច្ចុប្បន្ននេះ "សហគមន៍នៅតាមផ្លូវរថភ្លើង" និង "សហគមន៍នៅតាមដងប្រឡាយ" ត្រូវបានផ្តល់ទីតាំងលំនៅថ្មីដែលនៅក្បែរតំបន់ពួកគេរស់នៅបច្ចុប្បន្ន។ នេះ គឺជាការវិវឌ្ឍវិជ្ជមានមួយយោងតាមការលើកឡើងរបស់សហគមន៍ដែលមើលឃើញតំបន់ថ្មី ថាមានលក្ខណៈអំណោយផលដល់ការស្វែងរកការងារធ្វើ និងនៅក្បែរសាលារៀន ដែលមានគុណភាពខ្ពស់សម្រាប់កូនៗរបស់ពួកគេ។ ផ្ទុយទៅវិញ តំបន់តាំងទីលំនៅថ្មីផ្សេងទៀតដែលបានសិក្សាមានចង្ងាយយ៉ាងតិច ១០គីឡូម៉ែត្រ ពីកណ្តាលរាជធានីភ្នំពេញ។

ផលប៉ះពាល់ផ្នែកយេនឌ័រក៏ជាការរកឃើញដ៏សំខាន់មួយនៅក្នុងការអនុវត្តនីតិវិធីនៃការបណ្តេញចេញ និងការប្តូរទីតាំងលំនៅថ្មី ដោយសមាជិកសហគមន៍មួយចំនួនបានរាយការណ៍ថា ស្ត្រីមិនទទួលបានឱកាសចូលរួមបានគ្រប់គ្រាន់នៅក្នុងនីតិវិធីនោះទេ ហើយរងការលំបាកនៅទីតាំងថ្មី ព្រោះតែតួនាទីយេនឌ័រ និងហេដ្ឋារចនាសម្ព័ន្ធមិនល្អ និងការផ្គត់ផ្គង់តម្រូវការមិនគ្រប់គ្រាន់។ អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ (CEDAW) ដែលកម្ពុជាបានផ្តល់សច្ចាប័នក្នុងឆ្នាំ១៩៩២ បានលើកឡើងពីសារៈសំខាន់នៃការទទួលបានលំនៅឋានសមរម្យសម្រាប់ស្ត្រីនៅប្រទេសកម្ពុជា ប៉ុន្តែស្ត្រីជាច្រើនមានអារម្មណ៍ថា ត្រូវបានគេផាត់ចេញពីនីតិវិធីនៃការបណ្តេញចេញ និងការផ្លាស់ប្តូរទីតាំងលំនៅថ្មី។ លើសពីនេះ តំបន់តាំងទីលំនៅថ្មី តែងតែមិនមានបង្គោលភ្លើងបំភ្លឺផ្លូវសាធារណៈ ហើយសមាជិកសហគមន៍មួយចំនួន បានប្រាប់ពីការភ័យខ្លាចនូវអំពើហិង្សា ជាពិសេសអំពើហិង្សាផ្អែកលើភេទដូចជាការរំលោភសេពសន្ថវៈ ឬបទល្មើសពាក់ព័ន្ធនឹងគ្រឿងញៀន ក្នុងតំបន់តាំងទីលំនៅថ្មីរបស់ពួកគេ។

សហគមន៍ជាច្រើនបានផ្តល់ជាមតិត្រឡប់ ដើម្បីធ្វើឱ្យដំណើរការបណ្តេញចេញ និងផ្លាស់ប្តូរទីតាំងលំនៅថ្មីកាន់តែប្រសើរឡើង ដោយស្នើសុំឱ្យមានការចូលរួមសម្រេចចិត្តពីសមាជិកសហគមន៍កាន់តែច្រើននៅក្នុងនីតិវិធីទាំងនោះ និងអំពាវនាវឱ្យមានការពិភាក្សាឱ្យបានច្រើន ការជួបប្រជុំឱ្យបានច្រើន និងការចូលរួមពីភាគីពាក់ព័ន្ធផ្សេងៗឱ្យបានច្រើន ដើម្បីឱ្យសហគមន៍ទាំងនោះអាចសម្តែងនូវក្តីបារម្ភរបស់ពួកគេ។ លើសពីនេះ សមាជិកសហគមន៍ជាច្រើនមានអារម្មណ៍មិនសប្បាយចិត្តចំពោះសកម្មភាពដែលបានធ្វើមកលើពួកគេនៅរាល់ដំណាក់កាលនៃការបណ្តេញចេញ និងការផ្លាស់ទីតាំងលំនៅថ្មីដោយនិយាយថា នីតិវិធីទាំងនោះត្រូវបានធ្វើឡើងដោយ "អសុទ្ធិចិត្ត"។

របាយការណ៍នេះនឹងបញ្ចប់ជាមួយនឹងការផ្តល់អនុសាសន៍មួយចំនួន ជូនដល់រាជរដ្ឋាភិបាលដើម្បីធ្វើឱ្យប្រសើរឡើងនូវនីតិវិធីនៃការបណ្តេញចេញ និងធានាឱ្យបាននូវការចូលរួមកាន់តែច្រើនពីសហគមន៍ ហើយនិងអនុវត្តកាតព្វកិច្ចអន្តរជាតិស្របតាមច្បាប់សិទ្ធិមនុស្សរបស់រាជរដ្ឋាភិបាល។ ការបណ្តេញចេញ និងការផ្លាស់ទៅទីតាំងលំនៅថ្មីត្រូវបានគេប៉ាន់ស្មានថានឹងកើតមានច្រើនទៀតនៅក្នុងឆ្នាំខាងមុខ ដូចនេះវាមានសារសំខាន់ណាស់ដែលការរកឃើញទាំងនេះ គួរតែយកប្រើប្រាស់ ហើយភាគីពាក់ព័ន្ធទាំងអស់គួរចាត់វិធានការណ៍ ដើម្បីធានានូវលទ្ធផលកាន់តែប្រសើរដល់សហគមន៍ក្រីក្រនៅក្នុងទីក្រុង ក៏ដូចជាទីក្រុងទាំងមូល។

## ករណីសិក្សា៖ សហគមន៍ ស្មសាន

*"យើងបារម្ភពីផ្ទះរបស់យើង បាក់ធ្លាក់ចូលទៅក្នុងទន្លេ និងលង់ទឹកនៅពេលយប់"*

ពលរដ្ឋមកពីជំរុំជនភៀសខ្លួន ផ្ទះឆេះ ជីវភាពក្រីក្រ ឬដោយសារកត្តាផ្សេងៗទៀត និងប្រជាពលរដ្ឋស្ថិតក្នុងការគំរាមកំហែងបានមករស់នៅក្នុងសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញ។ ពលរដ្ឋរស់នៅសហគមន៍ ស្មសាន ខ្លះ ពួកគាត់មករស់នៅក្នុងសហគមន៍នេះដោយសារផ្ទះរបស់ពួកគាត់រស់នៅតាមមាត់ទន្លេ ហើយបារម្ភខ្លាចបាក់ចូលទៅក្នុងទន្លេ ដោយសារមានការបូមខ្សាច់នៅក្បែរនោះ។ មានគ្រួសារខ្លះបានផ្លាស់មកពីផ្សារច្បារអំពៅ។ សហគមន៍ស្មសាន បច្ចុប្បន្នរស់នៅលាយឡំជាមួយផ្នូរខ្មោច (ប្រហែលជាង៣០០ផ្នូរ) និងព្រះវិហារដ៏ចំណាស់មួយ។

*" ពេលយើងមករស់នៅទីនេះដំបូងយើងមានការភ័យខ្លាច និងមិនសុខស្រួល"*

ប៉ុន្តែនៅពេលសួរថា ហេតុអ្វីបានជាពួកគាត់មករស់នៅជាមួយផ្នូរខ្មោចតាំងពីពាក់កណ្ដាលទសវត្សរ៍ ឆ្នាំ១៩៩០ ពួកគាត់បានប្រាប់ថា ដោយសារតែពួកមិនដឹងថាទៅរស់នៅឯណា។ សម្រាប់ប្រជាពលរដ្ឋដែលទទួលរងពីការបាក់ច្រាំងទន្លេ គឺរស់នៅជាមួយផ្នូរខ្មោច ឬរស់នៅដោយលំបាកវេទនា។ ពួកគេធ្លាប់បានជួបប្រទះបញ្ហាការដួលរលំរវត្តចូលទៅក្នុងទន្លេ ប៉ុន្តែប្រាថ្នាមិនចង់មានវាសនាបែបនោះទេ។ សហគមន៍ស្មសាន មិនដែលទទួលបានលិខិតបណ្ដេញចេញនោះទេ តែពួកគេជឿជាក់ថាពួកគេនឹងត្រូវគេបណ្ដេញចេញ។ កាលពីឆ្នាំ២០១៦ ឯកឧត្តម ឃួង ស្រេង អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ បានផ្ដល់ទីតាំងលំនៅថ្មីដែលមានចម្ងាយ១០គីឡូម៉ែត្រពីសហគមន៍ សម្រាប់ពួកគេចាកចេញទៅរស់នៅ។



ផ្នូរខ្មោចនៅក្នុងសហគមន៍ (ថតដោយអង្គការសមាគមធាងត្នោត ឆ្នាំ២០១៩)

*" ពួកយើងបានទៅឃើញទីតាំងលំនៅថ្មីនោះ និងរំភើបមែនទែនតាមរយៈការជិះឡានក្រុង។ ប៉ុន្តែពេលដែលត្រឡប់មកវិញម្នាក់ៗនៅស្ងៀម ដោយឃើញផ្ទះនៅទីនៅមានទំហំតូច និងមិនអាចទទួលបានប្លង់កម្មសិទ្ធិក្រោយពេលនៅអស់រយៈពេល៥ឆ្នាំ ប្រសិនបើយើងព្រមទទួលយកទីតាំងនោះ "*

ផ្ទះដែលគេគម្រោងផ្ដល់ជូនមានទំហំ ៤ x ៥ ម៉ែត្រ ទំហំតូចពេក ហើយវាមានទំហំតូចជាងពីផ្ទះ ដែលពួកគាត់កំពុងរស់នៅសព្វថ្ងៃ។ គ្រួសារចំនួន៩៧ ក្នុងចំណោម១១៣គ្រួសារ ស្មើនឹង៨៥ភាគរយ ពួកគេមានដី ឬផ្ទះមានទំហំធំជាង ៤ x ៥ ម៉ែត្រ ទៅទៀត មានន័យថាទីតាំងថ្មីមានភាពខុសគ្នា។

ឯកឧត្តម ឃួង ស្រេង អភិបាលរាជធានីភ្នំពេញ បានលើកឡើងថា នេះមិនមែនជាការបង្ខិតបង្ខំទេ តែវាជាផ្ដល់ទីតាំងលំនៅថ្មីប៉ុណ្ណោះ។[៤] ចាប់តាំងពេលនោះមក ប្រជាសហគមន៍មិនដែលឮព័ត៌មានណាមួយពាក់ព័ន្ធនឹងស្ថានភាពដីរបស់ពួកគាត់នោះទេ។ ប្រជាសហគមន៍ បានជួបប្រជុំគ្នាមិនតិចជាង១០ដងនោះទេ ក្នុងរយៈពេល២ឆ្នាំចុងក្រោយនេះ ដើម្បីពិភាក្សាគ្នាអំពីស្ថានភាពផ្ទះរបស់ពួកគាត់ និងលទ្ធភាពក្នុងការចាកចេញ។ បើទោះបីជាមានផ្ដល់ទីតាំងថ្មីពីឯកឧត្តមអភិបាលរាជធានីភ្នំពេញក៏ដោយ រាជរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានពុំដែលលើកឡើនៅក្នុងផែនការគោលនយោបាយ ដើម្បីដោះស្រាយបញ្ហាទំនាស់ដីធ្លីជាមួយសហគមន៍នោះទេ ហើយអាជ្ញាធរទាំងនោះក៏មិនដែលផ្ដល់នូវឯកសារស្របច្បាប់ ឬព័ត៌មានផ្លូវការអំពីសុវត្ថិភាពដីធ្លីរបស់ពួកគេនោះដែរ។

អាជ្ញាធរសង្កាត់បានធ្វើកិច្ចព្រមព្រៀងជាលាយលក្ខអក្សរ ជាមួយប្រជាសហគមន៍តាំងពីពួកគាត់បានមករស់នៅក្នុងសហគមន៍ថា ពួកគាត់រស់នៅទីនេះ គឺជាលក្ខណៈបណ្ដោះអាសន្ន ហើយអាជ្ញាធរអាចឱ្យពួកគាត់ផ្លាស់ប្ដូរទីតាំងក្នុងពេលណាមួយ។ កិច្ចព្រមព្រៀងនោះ អាជ្ញាធរសង្កាត់មិនបានថតចម្លងជូនប្រជាសហគមន៍នោះទេ ហើយពួកគេព្យាយាមស្នើសុំឯកសារនោះ ប៉ុន្តែអាជ្ញាធរសង្កាត់មិនផ្ដល់ជូន។

នៅពេលគេសួរថា ហេតុអ្វីពួកគាត់នៅតែបន្តចង់រស់នៅក្នុងសហគមន៍ បើទោះបីជាមានផ្នូរខ្មោចក៏ដោយពួកគាត់បានឆ្លើយថា ពីព្រោះទីតាំងនេះនៅក្បែរសាលារៀន មណ្ឌលសុខភាព និងរោងចក្រដែលធ្វើឱ្យប្រជាសហគមន៍អាចប្រកបការងារបានស្រួល ហើយវាល្អបំផុតដល់ប្រជាសហគមន៍ទាំងមូល។

*"យើងមានចំណុចល្អ និងចំណុចអាក្រក់ ចំណុចល្អគឺមានសាលារៀនសម្រាប់ក្មេងៗ មានឱកាសការងារ មានមណ្ឌលសុខភាពនៅក្បែរ និងមានសហគមន៍ផងដែរ"*

នៅពេលដែលយើងសួរថា ពួកគាត់មានទុក្ខលំបាកអ្វីក្នុងការរស់នៅទីនេះ ឬធ្លាប់ការភ័យខ្លាចខ្មោចដែរឬទេ ពួកគាត់មិនបានផ្ដល់ចម្លើយណាមួយនោះទេ តែបែរជាពួកគាត់បានប្រាប់វិញថា សាច់ញាតិអ្នកដែលបានស្លាប់ទៅមានការអាណិតអាសូរពួកគាត់ខ្លាំងណាស់ហើយបានស្នើសុំពួកគាត់ឱ្យគោរពនិងជួយថែរក្សាព្រមទាំងសម្អាតផ្នូរទាំងនោះផង។ ប្រជាសហគមន៍ទាំងនោះបានរស់នៅជាមួយផ្នូរខ្មោចអស់រយៈពេលជាយូរយារមកហើយ ហើយពួកគាត់មិនដែលមានអារម្មណ៍ភ័យខ្លាចឡើយ។ ទីស្មសាន ជាកន្លែងល្អសមរម្យសម្រាប់ប្រជាសហគមន៍ ហើយវាមិនមែនជាកន្លែងអាក្រក់នោះឡើយ។

*"រឿងអាក្រក់សម្រាប់យើងនោះ គឺការបណ្ដេញពួកយើងចេញពីទីនេះ"*

[៤] Pech, S, ២០១៨. 'រស់នៅក្បែរខ្មោច'. កាសែតខ្មែរថាម ដំណភ្ជាប់៖ < https://www.khmertimeskh.com/503615/living-alongside-ghosts/>.

## ២. វិធីសាស្ត្រស្រាវជ្រាវ

### ២.១. គោលបំណង

របាយការណ៍នេះត្រូវបានធ្វើឡើង ដើម្បីវាយតម្លៃអំពីនីតិវិធីនៃការបណ្តេញចេញ និងការផ្លាស់ប្តូរទីតាំងលំនៅថ្មីនៅក្នុងរាជធានីភ្នំពេញ ដោយប្រើប្រាស់វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស ដែលត្រូវបានបង្កើតឡើងស្របនឹងច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សនានា ដូចជាសេចក្តីអត្ថាធិប្បាយរបស់អង្គការសហប្រជាជាតិ គោលការណ៍ណែនាំស្តីពីការបណ្តេញចេញ និងការតាំងទីលំនៅថ្មី និងដើម្បីផ្តល់ជាអនុសាសន៍នានាដោយយោងតាមការរកឃើញ។

ដើម្បីផលិតនូវរបាយការណ៍នេះ ករណីចំនួន៦៨ នៃការបណ្តេញចេញ ការផ្លាស់ប្តូរទីតាំងលំនៅថ្មី ការតាំងទីលំនៅថ្មី ឬទាំងបីនេះត្រូវបានជ្រើសរើសយកមកសិក្សា។ តារាងទី១ សង្ខេបនូវការចាត់ថ្នាក់សហគមន៍នានា ដែលត្រូវបានលើកឡើងនៅក្នុងរបាយការណ៍នេះ។

**តារាងទី ១៖** សហគមន៍ដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវ

| ប្រភេទនៃបញ្ហាដែលសហគមន៍ជួបប្រទះ | ចំនួនសហគមន៍ | ភាគរយ |
|---|---|---|
| សហគមន៍ដែលត្រូវបានបណ្តេញចេញ និងផ្លាស់ទីតាំងលំនៅឋាន | ៥០ | ៧៣ |
| សហគមន៍ដែលតាំងទីលំនៅថ្មីដោយខ្លួនឯង<br>(សហគមន៍ដែលសម្រេចចិត្តតាំងទីលំនៅថ្មីដោយខ្លួនឯង) | ៦ | ៩ |
| សហគមន៍ដែលត្រូវបានបណ្តេញចេញ<br>(ដោយមិនមានការផ្លាស់ទីតាំងលំនៅថ្មី ប៉ុន្តែអាចទទួលបានសំណង) | ៤ | ៦ |
| សហគមន៍ដែលស្ថិតក្នុងដំណើរការនៃការបណ្តេញចេញ* | ៨ | ១២ |
| **ចំនួនសរុប** | **៦៨** | **១០០** |

**នៅពេលដែលចេញផ្សាយរបាយការណ៍នេះ មានសហគមន៍ចំនួន៨កន្លែង ស្ថិតក្នុងដំណើរការនៃការបណ្តេញចេញ។*

### ២.២. ទំហំ និងលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស

សហគមន៍ត្រូវបានជ្រើសរើស ដោយផ្អែកលើការសិក្សារបស់អង្គការសមាគមជាងត្នោតឆ្នាំ២០០៧ និងឆ្នាំ២០១២ អំពីតំបន់តាំងទីលំនៅថ្មីក្នុងរាជធានីភ្នំពេញ និងរបាយការណ៍អង្កេតផ្សេងៗទៀតរបស់អង្គការសមាគមជាងត្នោត។ កាលពីដំបូងទីតាំងជាង ១០០កន្លែងត្រូវបានកំណត់ដែលភាគច្រើនជាទីតាំងនៃការបណ្តេញចេញដោយមិនមានការផ្តល់នូវទីតាំងថ្មីនោះទេ។ ភាគច្រើននៃសហគមន៍ក្នុងទីតាំងទាំងនេះ មិនត្រូវបានដាក់បញ្ចូលនៅក្នុងការសិក្សានោះទេ ព្រោះអ្នកស្រាវជ្រាវមិនអាចទាក់ទងសមាជិកសហគមន៍បាន ឬព្រោះសមាជិកសហគមន៍មិនចង់ពិភាក្សាអំពីការបណ្តេញចេញរបស់ពួកគេ។ នេះជាមូលហេតុធ្វើឱ្យអ្នកស្រាវជ្រាវអាចសម្ភាសបានតែចំនួន ៦៨សហគមន៍ ដោយមានសហគមន៍មួយចំនួន បានទៅដល់ហើយធ្វើសម្ភាសប្រសិនបើគាត់ចង់ចូលរួមក្នុងការស្រាវជ្រាវ ឬទាក់ទងសហគមន៍ដែលបានស្គាល់ និងប្រមូលផ្តុំជាក្រុមតូចសម្រាប់សម្ភាស។

បច្ចុប្បន្នសហគមន៍ចំនួន៨ កំពុងស្ថិតនៅក្នុងដំណើរការនៃការបណ្តេញចេញ ហើយត្រូវបានដាក់បញ្ចូលនៅក្នុងការសិក្សានេះ ដើម្បីធានាថាការរកឃើញអំពីដំណើរការនៃការបណ្តេញចេញមានបច្ចុប្បន្នភាព និងទិន្នន័យចុងក្រោយបំផុត។ មិនមានសហគមន៍ក្រៅរាជធានីភ្នំពេញ ត្រូវបានរាប់បញ្ចូលនោះទេ លើកលែងតែសហគមន៍ទាំងនោះ ពីមុនធ្លាប់រស់នៅក្នុងទីក្រុង ហើយត្រូវបានផ្លាស់ប្តូរទៅតាំងទីលំនៅថ្មីនៅក្រៅទីក្រុង។

ជាចុងក្រោយ មានករណីសិក្សាមួយបានបង្ហាញថាមានអំពើឃោរឃៅបានកើតឡើងក្នុងសហគមន៍របស់ពួកគាត់។ ឈ្មោះរបស់សហគមន៍ត្រូវបានរក្សាជាការសម្ងាត់។

## ២.៣. ការប្រមូលព័ត៌មាន

ការប្រមូលទិន្នន័យត្រូវបានធ្វើឡើងតាមរយៈកម្រងសំណួរចំនួនពីរ។ កម្រងសំណួរទី១ ផ្តោតទៅលើដំណើរការនៃការបណ្តេញចេញ និងផ្លាស់ទីលំនៅថ្មី ហើយកម្រងសំណួរទី២ ផ្តោតទៅលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនៅតំបន់តាំងទីលំនៅថ្មី។ កម្រងសំណួរទី១ត្រូវបានប្រើប្រាស់ដោយអ្នកស្រាវជ្រាវ២នាក់ ដើម្បីធ្វើការប្រមូលទិន្នន័យពីសមាជិកសហគមន៍។ ការបញ្ជាក់ទិន្នន័យត្រូវបានធ្វើឡើង បន្ទាប់ពីបានធ្វើការត្រួតពិនិត្យ និងវិភាគទិន្នន័យរួច។

ក្នុងពេលប្រមូលទិន្នន័យជាទូទៅមានសមាជិកសហគមន៍ ២ទៅ ៨នាក់ ចូលរួមបញ្ជាក់ ឬបដិសេធមិនយល់ស្របនឹងចម្លើយដែលបានផ្តល់ក្នុងអំឡុងពេលប្រមូលទិន្នន័យ។ នៅក្នុងករណីដែលមិនយល់ស្រប ឬមានភាពមិនច្បាស់លាស់ចម្លើយនោះមិនត្រូវបានបញ្ចូលក្នុងទិន្នន័យនោះទេ។ តារាងទី២ បង្ហាញពីទិន្នន័យពីអ្នកសម្ភាសមុនដំបូងអំឡុងពេលការប្រមូលទិន្នន័យ ដោយមានអ្នកផ្តល់បទសម្ភាសម្នាក់ដឹកនាំក្នុងការផ្តល់ចម្លើយ និងឆ្លើយតបទៅកាន់ក្រុមអ្នកស្រាវជ្រាវ។

កម្រងសំណួរទី២ ត្រូវបានបំពេញដោយប្រើប្រាស់វិធីដើរកាត់សហគមន៍ ហើយសង្កេតមើលរចនាសម្ព័ន្ធរូបវ័ន្តដែលមាននៅក្នុងសហគមន៍នោះ និងតាមរយៈការបញ្ជាក់អំពីការរកឃើញជាមួយប្រជាសហគមន៍។ កម្រងសំណួរទី២ត្រូវបានប្រើប្រាស់តែនៅក្នុងតំបន់តាំងទីលំនៅថ្មីប៉ុណ្ណោះ ដោយមិនបានប្រើប្រាស់សម្រាប់សហគមន៍ដែលកំពុងស្ថិតនៅក្នុងដំណើរការនៃការផ្លាស់ទីតាំងលំនៅថ្មី ឬដែលមិនទាន់ត្រូវបានឱ្យទៅនៅតំបន់ថ្មីដោយអាជ្ញាធរ ឬក្រុមហ៊ុននោះទេ។ ដូចនេះ សហគមន៍ដែលតាំងទីលំនៅថ្មីដោយខ្លួនឯង ក៏មិនត្រូវបានរាប់បញ្ចូលក្នុងការប្រមូលទិន្នន័យរបស់កម្រងសំណួរទី២ នេះដែរ។

ការប្រមូលទិន្នន័យទាំងអស់ត្រូវបានធ្វើ និងបញ្ចប់ក្នុងចន្លោះខែមិថុនា និងខែសីហា ឆ្នាំ២០១៩។

**តារាងទី ២៖** អ្នកចូលរួមផ្តល់បទសម្ភាសក្នុងការស្រាវជ្រាវ*

| អ្នកចូលរួមផ្តល់បទសម្ភាស | ចំនួន |
|---|---|
| មេភូមិ | ៤ |
| អ្នកដឹកនាំសហគមន៍ (អតីត និងបច្ចុប្បន្ន) | ៣៨ |
| សមាជិកសហគមន៍ | ២៦ |
| **ចំនួនសរុប** | **៦៨** |

**មានចំនួន២៩១នាក់ គឺមានអ្នកផ្តល់បទសម្ភាស ការសម្ភាសជាមួយបុគ្គលសំខាន់ៗ និងការពិភាក្សាក្រុម។*

លើសពីនេះ នៅខែតុលា អង្គការសមាគមធាងត្នោតបានរៀបចំការពិភាក្សាក្រុមជាមួយសមាជិកសហគមន៍ចំនួន១៩នាក់ ដែលមកពីសហគមន៍ចំនួន៧ ដើម្បីពិភាក្សាទៅលើការរកឃើញសំខាន់ៗនៅក្នុងរបាយការណ៍នេះ។ ដំណើរការនេះ រួមទាំងការពិនិត្យឡើងវិញនូវការរកឃើញសំខាន់ៗ ដើម្បីបញ្ជាក់ជាមួយសហគមន៍ថា ការរកឃើញទាំងនេះមានភាពច្បាស់លាស់ និងដើម្បីឈ្វេងយល់ថែមទៀតអំពីរបៀបដែលអ្នកស្រាវជ្រាវបង្ហាញនូវចម្លើយរបស់ពួកគេ។ អ្នកចូលរួមទាំងអស់បានឯកភាពនូវអ្វីដែលបានរកឃើញនៅក្នុងរបាយការណ៍នេះ។

ជាចុងក្រោយ ការពិនិត្យមើលទៅលើគោលនយោបាយ ច្បាប់ និងឯកសារពាក់ព័ន្ធនឹងការផ្លាស់ប្តូរទីតាំងលំនៅថ្មី និងការបណ្តេញចេញនៅក្នុងប្រទេសកម្ពុជាត្រូវបានធ្វើឡើង។

## ២.៤. យេនឌ័រ

ដោយសារការបណ្តេញចេញ និងការផ្លាស់ប្តូរទីតាំងលំនៅថ្មីអាចផ្តល់ផលប៉ះពាល់ផ្សេងគ្នា ដល់ប្រជាពលរដ្ឋផ្អែកលើយេនឌ័រ ការសិក្សានេះបានរៀបចំនូវសំណួរមួយចំនួនដើម្បីស្វែងរកថាតើមានផលប៉ះពាល់ខុសគ្នាឬទេរវាងយេនឌ័រ។ បន្ថែមពីនេះ អ្នកស្រាវជ្រាវបានអនុវត្តយន្តការមួយដើម្បីតាមដានជាមួយស្ត្រីនៅក្នុងសហគមន៍ក្នុងករណីដែលអ្នកទាំងនោះមិនបានចូលរួមផ្ទាល់ក្នុងការប្រមូលទិន្នន័យ។ ដូចដែលបានលើកឡើងនៅក្នុងតារាងទី៣ ខាងក្រោម ប្រហែល៣៨ភាគរយ នៃអ្នកត្រូវបានសម្ភាសដំបូងជាស្ត្រី និងប្រហែល៦០ភាគរយ នៃក្រុមពិភាក្សាក៏ជាស្ត្រី។ យន្តការនេះ ត្រូវបានអនុវត្តក្នុងករណីចំនួន ៦២ភាគរយ ដែលអ្នកផ្តល់បទសម្ភាសមិនមែនជាស្ត្រី ដើម្បីទទួលបានព័ត៌មានបន្ថែមអំពីផលប៉ះពាល់ផ្អែកយេនឌ័រនៃការបណ្តេញចេញ និងការផ្លាស់ប្តូរទីតាំងលំនៅថ្មី។

**តារាងទី ៣៖** ភេទរបស់អ្នកចូលរួមផ្តល់បទសម្ភាស

| ភេទ | ចំនួន |
|---|---|
| ស្ត្រី | ២៦ |
| បុរស | ៤២ |
| **ចំនួនសរុប** | **៦៨** |

## ២.៥. ដែនកំណត់

ការសិក្សានេះ ធ្វើការស្រាវជ្រាវជាមួយតែសហគមន៍ដែលត្រូវបានកំណត់តាមរយៈការសិក្សាពីមុន ឬការប្រតិបត្តិការងារទូទៅរបស់អង្គការសមាគមធាងត្នោតតែប៉ុណ្ណោះ។ ទិន្នន័យនៃរបាយការណ៍នេះត្រូវបានធ្វើឡើងផ្អែកលើសហគមន៍ចំនួន៦៨ ដូចបានកំណត់។ មានសហគមន៍ច្រើនជាងនេះដែលទទួលរងនូវការបណ្តេញចេញ និងការឱ្យផ្លាស់ប្តូរទីតាំងលំនៅ និងមានបទពិសោធន៍ខុសពីសហគមន៍ដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ។ គួរកត់សំគាល់ផងដែរថា ការបណ្តេញចេញជាង១០០ករណី ត្រូវបានកំណត់ដោយអង្គការសមាគមធាងត្នោត ប៉ុន្តែមានតែ៦៨ ប៉ុណ្ណោះ ដែលបានដាក់បញ្ចូលក្នុងការស្រាវជ្រាវនេះ។

របាយការណ៍នេះមិនបានសម្ភាសតាមខ្នងផ្ទះទេ ដោយសារតែខ្វះពេលវេលា និងធនធាន។ ដូច្នេះ ការស្រាវជ្រាវធ្វើតែចំពោះសមាជិកសហគមន៍ចំនួន ២ទៅ៣នាក់ប៉ុណ្ណោះ នៅក្នុងសហគមន៍នីមួយៗ។ អ្នកស្រាវជ្រាវបានពឹងផ្អែកយ៉ាងខ្លាំងទៅលើចម្លើយរបស់អ្នកផ្តល់បទសម្ភាស ដើម្បីធ្វើជាទិន្នន័យសម្រាប់របាយការណ៍។ ដូចនេះ របាយការណ៍នេះ ឆ្លុះបញ្ចាំងពីស្ថានភាពពិតរបស់អ្នកផ្តល់បទសម្ភាសដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។

ការសិក្សាស្រាវជ្រាវនេះ មិនតំណាងឱ្យចំនួននៃការបណ្តេញចេញ និងការតាំងទីលំនៅថ្មីទាំងអស់នៅក្នុងរាជធានីភ្នំពេញ ឬប្រទេសកម្ពុជានោះទេ ដោយសារការសិក្សានេះមិនបានធ្វើការស្ទង់មតិផ្អែកលើគ្រួសារនោះទេ ផ្ទុយទៅវិញវិធីសាស្ត្របែបសន្និដ្ឋានទូទៅត្រូវបានប្រើប្រាស់ ដើម្បីសិក្សាពីការបណ្តេញចេញនៅក្នុងកម្រិតសហគមន៍។ ដូចនេះ ការសិក្សានេះគួរយកមកប្រើប្រាស់ ដើម្បីបង្ហាញពីនិន្នាការសំខាន់ៗនៅក្នុងដំណើរការនៃការបណ្តេញចេញ និងការតាំងទីលំនៅថ្មីទាំងនោះ ហើយអ្នកស្រាវជ្រាវទទួលស្គាល់ថា ប្រជាពលរដ្ឋដែលមិនបានចូលរួមសម្ភាសមកពីសហគមន៍ ដែលត្រូវបានសិក្សាអាចនឹងមិនយល់ស្របនឹងការរកឃើញមួយចំនួនដោយផ្អែកលើបទពិសោធន៍ផ្សេងៗរបស់ពួកគេ ។



ស្រះទឹកនៅក្បែរសហគមន៍ (ថតដោយអង្គការសមាគមធាងត្នោត ឆ្នាំ២០១៩)

## ៣. សាវតានៃការបណ្តេញចេញ និងការផ្លាស់ប្តូរទីតាំងលំនៅថ្មីក្នុងរាជធានីភ្នំពេញ និងប្រទេសកម្ពុជា

### ៣.១ បរិបទប្រវត្តិសាស្ត្រ

ក្រោយពីការដួលរលំនៃរបបខ្មែរក្រហម រាជធានីភ្នំពេញទាំងមូលបានក្លាយជាតំបន់តាំងទីលំនៅថ្មី ដោយសារអ្នកធ្លាប់រស់នៅពីមុន ជនចំណាកស្រុក និងប្រជាពលរដ្ឋដទៃទៀតបានមករស់នៅក្នុងទីក្រុង។ មានប្រជាពលរដ្ឋជាច្រើន ដែលមិនមានផ្ទះនៅទីក្រុង ឬផ្ទះដែលខ្លួនធ្លាប់រស់នៅពីមុនត្រូវបានបាត់បង់។ ក្នុងករណីខ្លះ ស្ថានភាពនេះធ្វើឱ្យប្រជាពលរដ្ឋជាច្រើនគ្រួសារ ស្វែងរកតំបន់ផ្សេងៗក្នុងទីក្រុងដែលមានដីនៅទំនេរ ដើម្បីសាងសង់លំនៅឋាន។ ភាគច្រើននៃតំបន់ទាំងនោះ តែងតែនៅជិតតំបន់ទឹក ឬដីដែលទំនេរដែលអាចនឹងត្រូវបានកំណត់ជាដីសាធាណៈរបស់រដ្ឋនៅពេលក្រោយ។ សម្រាប់សហគមន៍ភាគច្រើនដែលបានសិក្សា ការកាន់កាប់ដីសាធារណៈរបស់រដ្ឋគឺជាមូលហេតុចម្បងដែលរាជរដ្ឋាភិបាលបានប្រើដើម្បីបណ្តេញសហគមន៍ចេញពីលំនៅឋានរបស់ពួកគេ។

ការបំផ្លាញប្លង់កម្មសិទ្ធិក្នុងរបបខ្មែរក្រហមរួមទាំងច្បាប់ភូមិបាលថ្មីឆ្នាំ២០០១ ដែលបានចែងថាការគ្រប់គ្រងកម្មសិទ្ធិដែលមានមុនរបបខ្មែរក្រហមមិនត្រូវបានទទួលស្គាល់ស្របច្បាប់ឡើយ មានន័យថាដីនៅក្នុងរាជធានីភ្នំពេញ និងនៅទូទាំងប្រទេសមិនមានម្ចាស់កម្មសិទ្ធិនោះទេ[៥]។ក្នុងចន្លោះពីទសវត្សរ៍ឆ្នាំ១៩៨០ មកដល់សព្វថ្ងៃតំបន់ជាច្រើនក្នុងរាជធានីភ្នំពេញមានប្លង់កម្មសិទ្ធិ ប៉ុន្តែតំបន់មួយចំនួនទៀត នៅមិនទាន់មានប្លង់កម្មសិទ្ធិនៅឡើយ។ រហូតមកដល់សព្វថ្ងៃ ការគ្រប់គ្រងដីធ្លីគឺជាបញ្ហាអាទិភាពមួយសម្រាប់កម្ពុជា និងម្ចាស់ជំនួយអន្តរជាតិជាច្រើន។ បញ្ហាចម្បងនោះគឺការអនុវត្តប្រព័ន្ធចុះបញ្ជីប្លង់កម្មសិទ្ធិដីធ្លីស្របតាមច្បាប់ភូមិបាលឆ្នាំ២០០១ ជាពិសេសនៅតំបន់ណាដែលច្បាប់កំណត់ថាអាចកាន់កាប់ដោយឯកជន និងតំបន់ដែលមិនអាចកាន់កាប់ដោយឯកជនបាន។ បញ្ហាមួយទៀត គឺរាជធានីភ្នំពេញជាទីក្រុងធំបំផុតក្នុងប្រទេស ដែលមានជនចំណាកស្រុកជាច្រើនចូលមករស់នៅធ្វើឱ្យចំនួនប្រជាជនកើនឡើងទ្វេដងក្នុងចន្លោះឆ្នាំ១៩៩៦ ដល់ឆ្នាំ២០០៨[៦] ដោយសារភាគច្រើនជនភៀសខ្លួនពីសង្គ្រាមត្រឡប់ពីជំរំតាមព្រំដែនមករស់នៅក្នុងទីក្រុងវិញ។ សព្វថ្ងៃនេះ ទោះជាមានការខិតខំអស់រយៈពេលជិត២ទសវត្សរ៍ក្នុងការផ្តល់ប្លង់កម្មសិទ្ធិដីធ្លីក្នុងរាជធានីភ្នំពេញក៏ដោយ យ៉ាងហោចណាស់សហគមន៍ចំនួន២០០ នៅតែបន្តខ្វះខាតសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លីដែលធ្វើឱ្យអ្នកទាំងនោះភ័យខ្លាចពីការបណ្តេញចេញ។[៧] អ្នកទាំងនេះសុទ្ធតែជាប្រជាពលរដ្ឋក្រីក្រ ដែលតែងតែខ្វះខាតផ្ទះសម្បែងត្រឹមត្រូវ និងសេវាកម្មជាមូលដ្ឋានហើយរស់នៅដោយការភ័យខ្លាចពីការបណ្តេញចេញថ្ងៃអនាគត។[៨] ដោយមូលហេតុនេះ ទើបរបាយការណ៍នេះ មានគោលបំណងលើកបង្ហាញអំពីដំណើរការនៃការបណ្តេញចេញ និងផ្លាស់ប្តូរទីតាំងលំនៅឋាននៅកម្ពុជា ដើម្បីឱ្យមានការផ្លាស់ប្តូរ និងធានានូវលទ្ធផលជាវិជ្ជមានសម្រាប់ប្រជាពលរដ្ឋ ក្នុងរាជធានីភ្នំពេញទាំងមូល។

### ៣.២. ក្របខ័ណ្ឌគតិយុត្តិ

#### ច្បាប់សិទ្ធិមនុស្សអន្តរជាតិ

មាត្រា២៥ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចែងថាមនុស្សគ្រប់រូបមានសិទ្ធិទទួលបានលំនៅឋាន។[៩] សិទ្ធិនេះ ត្រូវបានបញ្ជាក់បន្ថែមនៅក្នុងកតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ដែលបានចែងក្នុងមាត្រា១១ ថារាជរដ្ឋាភិបាលត្រូវ "ចាត់វិធានការសមរម្យ" ដើម្បីធានាថា ប្រជាពលរដ្ឋទទួលបានសិទ្ធិនេះ។[១០] ប៉ុន្តែវិធានការ និងរបៀបនៃការបណ្តេញចេញ ឬការតាំងលំនៅថ្មីក្នុងបរិបទសិទ្ធិមនុស្សទាំងនេះ មិនត្រូវបានរៀបរាប់នោះទេ។ ដោយសារ

---

[៥] មាត្រា ៧ នៃច្បាប់ភូមិបាល ឆ្នាំ២០០១

[៦] ក្រសួងផែនការ៖ រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១២ "ការចំណាកស្រុកនៅកម្ពុជា"

[៧] អង្គការសមាគមធាងត្នោត ឆ្នាំ២០១៨ "ការស្ទង់មតិនៅក្នុងរាជធានីភ្នំពេញ ឆ្នាំ២០១៨"

[៨] អង្គការសមាគមធាងត្នោត ឆ្នាំ២០១៨ "ការស្ទង់មតិនៅក្នុងរាជធានីភ្នំពេញ ឆ្នាំ២០១៨"

[៩] អង្គការសហប្រជាជាតិ ឆ្នាំ ១៩៤៨ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា ២៥

[១០] មាត្រា ១១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ឆ្នាំ ១៩៦៦

សិទ្ធិទទួលបានលំនៅឋានមានសារៈសំខាន់ជាមូលដ្ឋានសម្រាប់មនុស្ស សិទ្ធិនេះត្រូវបានគេកំណត់នៅក្នុងអនុសញ្ញាសំខាន់ៗនានា ដែលកម្ពុជាបានផ្តល់សច្ចាប័ន ដូចជាអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍(ICERD)[១១] អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងនឹងស្ត្រីភេទ(CEDAW)[១២] អនុសញ្ញាស្តីពីសិទ្ធិកុមារ(CRC)[១៣] អនុសញ្ញាស្តីពីសិទ្ធិជនពិការ(CRPD)[១៤] ក៏ដូចជាអនុសញ្ញាស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេ(CMW)[១៥] ហើយកម្ពុជាជាប្រទេសហត្ថលេខីមួយលើអនុសញ្ញាទាំងនេះ។ការផ្តល់សច្ចាប័នរបស់កម្ពុជាលើអនុសញ្ញាដែលទទួលស្គាល់សិទ្ធិទទួលបានលំនៅឋានទាំងប្រាំនេះ គឺជាការការពារផ្នែកច្បាប់ដ៏សំខាន់មួយពីការបណ្តេញចេញដែលមិនមានសំណងសមរម្យ ដូចជាការផ្តល់ផ្ទះសម្បែងនៅទីតាំងថ្មី។

**ច្បាប់ជាតិ**

មាត្រា៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ទទួលស្គាល់ និងគោរពសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋគ្រប់រូបដូចដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។[១៦] ពាក់ព័ន្ធនឹងការបណ្តេញចេញ និងការតាំងទីលំនៅថ្មី មាត្រា៤៤ បានលើកឡើងនូវសិទ្ធិជាម្ចាស់កម្មសិទ្ធិ ដោយចែងថាប្រជាពលរដ្ឋគ្រប់រូប មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ប៉ុន្តែមានតែប្រជាពលរដ្ឋខ្មែរប៉ុណ្ណោះ ដែលមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។[១៧] ខណៈដែលបុរេលក្ខខណ្ឌនេះ ហាក់ដូចជាមានលក្ខណៈច្បាស់លាស់ វាក៏បង្កជាបញ្ហាផងដែរ ដូចជាសហគមន៍ជនជាតិដើមជាច្រើន អាចប្រឈមមុខនឹងបញ្ហាវិបាកក្នុងការបញ្ជាក់ថា តើខ្លួនជាប្រជាពលរដ្ឋខ្មែរ ប្រសិនបើមិនមានលិខិតគតិយុត្តិបញ្ជាក់។ ជាឧទាហរណ៍ យុទ្ធនាការបង្ក្រាបឯកសារខុសច្បាប់ថ្មីៗនេះបានដាក់គោលដៅទៅលើជនជាតិភាគតិចវៀតណាមដែលរស់នៅក្នុងរាជធានីភ្នំពេញ។[១៨] លើសពីនេះ សិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លីមិនបានផ្តល់ការការពារលើសិទ្ធិទទួលបានលំនៅឋានដល់សហគមន៍ដែលរស់នៅក្នុងផ្ទះបណ្តែតទឹក និងផ្ទះសម្បែងដែលមិនមែនជាអចលនទ្រព្យតាមបណ្តោយដងទន្លេ ឬបឹងនោះទេ។ មាត្រា៤៤ បានចែងថា ភាពជាម្ចាស់កម្មសិទ្ធិស្របច្បាប់ត្រូវបានការពារដោយច្បាប់ ហើយការដកហូតអាចធ្វើទៅបាន លុះត្រាតែធ្វើឡើងដោយស្របច្បាប់ដើម្បីបម្រើប្រយោជន៍សាធារណៈ ដូចមានចែងក្នុងច្បាប់ ហើយតម្រូវឱ្យផ្តល់សំណងឱ្យបានសមរម្យ និងយុត្តិធម៌។[១៩]

ក្រៅពីរដ្ឋធម្មនុញ្ញ ច្បាប់ភូមិបាលឆ្នាំ២០០១ ក៏ផ្តល់នូវការការពារ និងធានានូវសំណង នៅពេលដែលរដ្ឋដកហូតដីធ្លីពីប្រជាពលរដ្ឋឯកជន ដោយបញ្ជាក់កាន់តែច្បាស់ថា ការដកហូតដីធ្លីអាចធ្វើបានក្នុងគោលបំណងបម្រើប្រយោជន៍សាធារណៈតែប៉ុណ្ណោះ ហើយត្រូវផ្តល់សំណងឱ្យបានសមរម្យ និងយុត្តិធម៌។[២០] ច្បាប់ស្តីពីអស្សាមិករណ៍ហាក់ដូចជាសំដៅសំណងសមរម្យថាជាសំណងស្មើនឹងតម្លៃទីផ្សារ ឬតម្លៃជំនួសដែលកំណត់ដោយគណៈកម្មាធិការ និងភ្នាក់ងារឯករាជ្យ។[២១] សហគមន៍ជាច្រើនដែលបានចូលរួមក្នុងការសិក្សានេះ ត្រូវបានគេបណ្តេញចេញដោយហេតុផលថាអ្នកទាំងនោះរស់នៅលើទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋដែលមិនអាចកាន់កាប់បានដោយបុគ្គលឯកជនឡើយ។

---

[១១] អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ឆ្នាំ ១៩៦៩ មាត្រា ៥ (ង) (៣)
[១២] អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ ឆ្នាំ ១៩៧៩ មាត្រា ១៤.២
[១៣] អនុសញ្ញាស្តីពីសិទ្ធិកុមារ ឆ្នាំ ១៩៨៩ មាត្រា ២៧.៣
[១៤] អនុសញ្ញាស្តីពីសិទ្ធិជនពិការ ឆ្នាំ ២០០៨ មាត្រា ៩.១ (ក) មាត្រា ២៨.១ និងមាត្រា ២៨.២ (ឃ)
[១៥] អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកក្រុមគ្រួសាររបស់ពួកគេ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ ១៩៩០ មាត្រា ៤៣.១ (ឃ)
[១៦] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ មាត្រា ៣១
[១៧] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ មាត្រា ៤៤
[១៨] ដាវ៉ា M & A Nachmenson ឆ្នាំ ២០១៧ "ជនជាតិភាគតិចវៀតណាមនៅទីក្រុងភ្នំពេញ ព្រមឱ្យដកហូតឯកសារ" អាចទាញយកបានតាមរៈ < https://www.phnompen hpost.com/national/ethnic-vietnamese-phnom-penh-resigned-document-purge>.
[១៩] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ មាត្រា ៤៤
[២០] ច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ ២០១០ មាត្រា ៥
[២១] ច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ ២០១០ មាត្រា ២២

មាត្រា៤៣ ចែងថាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនអាចកាន់កាប់ដោយបុគ្គលនោះទេ។[២២] គេនៅមិនទាន់ដឹងច្បាស់ថាអ្វីខ្លះជាទ្រព្យសម្បត្តិសាធារណៈនៅឡើយ។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋត្រូវបានគេឱ្យនិយមន័យយ៉ាងទូលាយនៅក្នុងមាត្រា១៥ ដែលបានកំណត់ទ្រព្យសម្បត្តិធំៗជាច្រើនថាជាទ្រព្យសម្បត្តិសាធារណៈ ប៉ុន្តែមិនបានផ្តល់នូវបញ្ជីរាយទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋឱ្យបានជាក់លាក់នោះទេ។ ទោះជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋជាក់លាក់មួយចំនួនដូចជាបឹងត្រូវបានកំណត់ក្តី ក៏ទ្រព្យទាំងនោះមិនត្រូវបានគេផ្តល់និយមន័យឱ្យបានច្បាស់លាស់នោះទេ។ ឧទារហណ៍ ប្រសិនបើគេកំណត់តំបន់បឹងថាស្មើត្រឹមផ្ទៃទឹក នោះទំហំតំបន់បឹងនឹងបន្ថយតូចខ្លាំង។ ប៉ុន្តែប្រសិនបើរួមបញ្ចូលទាំងមាត់ច្រាំង និងខឿនទប់ទឹក ឬតំបន់ទ្រនាប់ នោះទំហំបឹង នឹងកាន់តែធំ។ អនុក្រឹត្យស្តីពីកាគ្រប់គ្រងអាងទន្លេឆ្នាំ២០១៥ ដែលមានបំណងបញ្ជាក់ឱ្យបានច្បាស់ពីសមាសភាពនៃទន្លេបឹងបួនៅតែមិនអាចផ្តល់នូវភាពច្បាស់លាស់លើបញ្ហានេះដដែល។ មាត្រា៤ បានចែងថា "បឹង" សំដៅទៅលើ "ផ្ទៃទឹកធំល្វឹងល្វើយកើតពីទីជម្រាល ឬជម្រៅធម្មជាតិ ដែលអាចមានទឹក ឬគ្មានទឹកទៅតាមរដូវកាល និងមានប្រភពទឹកមកពីទន្លេ ស្ទឹង ព្រែក ឬពីតំបន់ផ្ទៃរងទឹកភ្លៀង"។[២៣] បញ្ហាដែលកាន់តែស្មុគស្មាញ គឺតំបន់ទ្រនាប់ដែលនៅចន្លោះព្រំប្រទល់បឹង និងតំបន់ដែលអាចកាន់កាប់ដោយឯកជន នៅមិនទាន់បានកំណត់នៅឡើយទេ ក្នុងរាជធានីភ្នំពេញ។ ដោយសារកង្វះភាពច្បាស់លាស់នេះ សហគមន៍ជាច្រើនរស់នៅក្នុងស្ថានភាពងាយរងគ្រោះ ដោយមិនអាចទទួលបានប្លង់កម្មសិទ្ធិកាន់កាប់ផ្ទះសម្បែង និងដីស្របច្បាប់របស់ពួកគេ។ លើសពីនេះ តំបន់ដែលសហគមន៍ត្រូវបានគេបណ្តេញចេញក្រោមហេតុផលថា រស់នៅលើដីសាធារណៈរបស់រដ្ឋនោះ ជារឿយៗត្រូវបានដាក់ជួលឱ្យក្រុមហ៊ុនឯកជន បន្ទាប់ពីធ្វើអនុប្រយោគដីនោះពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។[២៤] ការខកចិត្តមានកាន់តែច្រើន នៅពេលដែលសហគមន៍ទាំងនោះ ត្រូវបានជូនដំណឹងដោយអាជ្ញាធរថាពួកគេកាន់កាប់ដីខុសច្បាប់ប៉ុន្តែករណីលើកលែងត្រូវបានធ្វើឡើងសម្រាប់ទ្រព្យសម្បត្តិក្រុមដទៃទៀតដែលរស់នៅក្បែរនោះ។

ច្បាប់ភូមិបាលបញ្ជាក់ច្បាស់ថាអ្នកកាន់កាប់ខុសច្បាប់គឺតម្រូវឱ្យចាកចេញទាំងបង្ខំ និងប្រឈមមុខនឹងទណ្ឌកម្មថែមទៀតផង។[២៥] លើសពីនេះ ច្បាប់ភូមិបាលបានចែងថាអ្នកកាន់កាប់ខុសច្បាប់នឹងមិនទទួលបានសំណងជាលំនៅឋាន ឬសំណងផ្សេងៗសម្រាប់សមិទ្ធផលដែលអ្នកទាំងនោះបានធ្វើអំឡុងពេលកាន់កាប់ទ្រព្យសម្បត្តិនោះទេ។[២៦]

យោងតាមអនុក្រឹត្យលេខ១២៩ដែលកំណត់គោលការណ៍យុទ្ធសាស្ត្រ និងនីតិវិធីសម្រាប់ការរៀបចំ និងចាត់ចែងទ្រព្យសម្បត្តិរបស់រដ្ឋ[២៧] អាជ្ញាធរដែលមានតួនាទីតាមដាន និងធ្វើរបាយការណ៍ស្តីពីស្ថានភាពទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋក្នុងការបម្រើប្រយោជន៍សាធារណៈគឺអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។[២៨] អាជ្ញាធរទាំងនេះអាចធ្វើអនុប្រយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋឱ្យទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ ប៉ុន្តែ អាជ្ញាធរទាំងនេះកម្រនឹងចេញរបាយករណ៍ បង្ហាញពីរបៀបដែលខ្លួនបានកំណត់ទ្រព្យណាមួយដើម្បីធ្វើអនុប្រយោគណាស់។ កង្វះតម្លាភាពបែបនេះធ្វើឱ្យសហគមន៍ជាច្រើនមានការខកចិត្ត និងមិនប្រាកដថាហេតុអ្វីពួកគេមិនអាចកាន់កាប់ទ្រព្យសម្បត្តិស្របច្បាប់បាន ប៉ុន្តែក្រោយពេលត្រូវបានបណ្តេញចេញ ទ្រព្យនោះបែរជាអាចជួល ឬកាន់កាប់ដោយក្រុមដែលមានអំណាចដទៃទៀតបាន។ លើសពីនេះ ប្រព័ន្ធទិន្នន័យដែលផ្តល់ព័ត៌មានអំពីបញ្ជីទ្រព្យសាធារណៈរបស់រដ្ឋក្នុងរាជធានីភ្នំពេញមិនងាយនឹងអាចរកបាននោះឡើយ មានន័យថា សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលមិនអាចទទួលបានព័ត៌មានដែលអាចជួយបញ្ចៀសពីជម្លោះនាថ្ងៃអនាគត។

នៅក្នុងករណីខ្លះ សហគមន៍ដឹងច្បាស់ និងសុខចិត្តកាន់កាប់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដោយសារពួកគេមិនដឹងទៅរស់នៅទីណា ឬកត្តាសេដ្ឋកិច្ចបង្ខំឱ្យអ្នកទាំងនោះចាកចេញពីស្រុកមករស់នៅរាជធានីភ្នំពេញខណៈដែលលំនៅឋានក្នុងទីក្រុងមានតម្លៃខ្ពស់ខ្លាំង។

---

[២២] ច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា ៤៣

[២៣] អនុក្រឹត្យស្តីពី "ការគ្រប់គ្រងអាងទន្លេ" ឆ្នាំ ២០១៥ មាត្រា ៤ លេខ ៩០

[២៤] ច្បាប់ភូមិបាល ឆ្នាំ ២០០១ មាត្រា ១៦

[២៥] ច្បាប់ភូមិបាល ឆ្នាំ ២០០១ មាត្រា ២៥៩

[២៦] ច្បាប់ភូមិបាល ឆ្នាំ ២០០១ មាត្រា ៤៣

[២៧] អនុក្រឹត្យលេខ ១២៩ ដែលបានកំណត់គោលការណ៍ យុទ្ធសាស្ត្រ និងនីតិវិធីសម្រាប់ការរៀបចំ និងចាត់ចែងទ្រព្យសម្បត្តិរបស់រដ្ឋ មាត្រា ១

[២៨] អនុក្រឹត្យលេខ ១២៩ ដែលបានកំណត់គោលការណ៍ យុទ្ធសាស្ត្រ និងនីតិវិធីសម្រាប់ការរៀបចំ និងចាត់ចែងទ្រព្យសម្បត្តិរបស់រដ្ឋ ជំពូក ៦ មាត្រា ៤១

ក្នុងករណីការបណ្តេញចេញមានពាក់ព័ន្ធនឹងគម្រោងដែលទទួលបានហិរញ្ញប្បទានពីខាងក្រៅ អនុក្រឹត្យលេខ២២ បានប្រកាសឱ្យប្រើប្រាស់នីតិវិធីប្រតិបត្តិការស្តង់ដារ ដើម្បីធានាថាដំណើរការផ្លាស់ប្តូរទីតាំងថ្មីមានលក្ខណៈស្តង់ដារ។[២៩] នីតិវិធីនេះគ្រាន់តែជាគោលការណ៍ណែនាំ ព្រោះគម្រោងធំៗដែលទទួលបានហិរញ្ញប្បទានពីខាងក្រៅភាគច្រើនតែងតែមាននីតិវិធីជាច្រើនសមស្រប ដើម្បីត្រួតពិនិត្យមើលដំណើរការបណ្តេញចេញ និងការតាំងទីលំនៅថ្មី។

គិតចាប់ពីច្បាប់ភូមិបាលចូលជាធរមាននៅឆ្នាំ២០០១ កម្មសិទ្ធិឯកជន ត្រូវបានទទួលស្គាល់ស្របច្បាប់នៅពេលដែលការកាន់កាប់ដីធ្លី (លើកលែងតែដីជាទ្រព្យសាធារណៈ) ឬផ្ទះសម្បែងប្រកបដោយសន្តិវិធី និងមិនមានការតវ៉ាកាន់កាប់លើសពី៥ឆ្នាំ គិតមុនឆ្នាំ២០០១។[៣០] លើសពីនេះ យោងតាមមាត្រា៣១ ប្រជាពលរដ្ឋខ្មែរគ្រប់រូបអាចធ្វើជាម្ចាស់កម្មសិទ្ធិដីបាន ប្រសិនបើពួកគេកាន់កាប់ដីនោះមុនឆ្នាំ២០០១ និងបន្តកាន់កាប់លើសពី៥ឆ្នាំ ដោយមានការអនុញ្ញាតពីអាជ្ញាធរពាក់ព័ន្ធ។[៣១]

ដីធ្លីក៏អាចត្រូវបានផ្តល់ទៅក្រុមគ្រួសារជាអំណោយផងដែរ យោងតាមច្បាប់ភូមិបាល ដែលរាជរដ្ឋាភិបាលកម្ពុជាអាចផ្តល់ឱ្យគ្រួសារក្រីក្រ ជាផ្ទះ ឬដីសម្រាប់ស្នាក់នៅ និងឬដាំដំណាំបន្តិចបន្តួច។[៣២] មាត្រា៨៣ បានចែងថាដីអាចត្រូវបានធ្វើប្រទានកម្មតែក្នុងករណីហេតុផលសង្គមកិច្ចប៉ុណ្ណោះ ដោយបញ្ជាក់ថាតម្លៃនៃដីត្រូវកំណត់សមស្របទៅនឹងគោលដៅណាមួយដែលចង់បាន និងមិនអនុញ្ញាតឱ្យកេងយកកំរៃ ឬធ្វើមានបានមិនស្របទៅនឹងកម្រិតជីវភាពសង្គមនៃអ្នកទទួល។[៣៣] យន្តការនេះមានសារៈសំខាន់ ប្រសិនជាប្រើប្រាស់បានត្រឹមត្រូវ ព្រោះវាអនុញ្ញាតឱ្យរាជរដ្ឋាភិបាលកម្ពុជាធ្វើការបែងចែកដីធ្លីសម្រាប់គ្រួសារក្រីក្រ ប៉ុន្តែយន្តការនេះតែងតែពិបាកក្នុងការអនុវត្ត និងមិនអាចអនុវត្តបាននៅឡើយក្នុងបរិបទនៃរាជធានីភ្នំពេញបច្ចុប្បន្ន។ គិតត្រឹមពេលផ្សព្វផ្សាយរបាយការណ៍នេះ អ្នកស្រាវជ្រាវមិនដឹងថាមានការបែងចែកដីធ្លី ឬអត់សម្រាប់ក្រុមគ្រួសារដែលត្រូវបានគេបណ្តេញចេញពីរាជធានីភ្នំពេញនោះទេ។

## គោលនយោបាយ

មួយផ្នែកគឺដោយសារការកើនឡើងនៃការបណ្តេញចេញចន្លោះពីឆ្នាំ២០០១ ដល់ឆ្នាំ២០១០ ដែលភាគច្រើននៃការបណ្តេញចេញ ធ្វើឡើងក្រោមមូលហេតុថា សហគមន៍បានកាន់កាប់ដីសាធារណៈរបស់រដ្ឋដោយខុសច្បាប់ យោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ ដែលទើបតែចូលជាធរមានទើប "សារាចរស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជន"[៣៤] ដែលជាទូទៅគេហៅថាសារាចរលេខ០៣ ត្រូវបានចុះហត្ថលេខាកាលពីឆ្នាំ២០១០។ សារាចរលេខ០៣ នេះ បានលើកឡើងនូវយន្តការដោះស្រាយជម្លោះសម្រាប់សហគមន៍ដែលកាន់កាប់ដីរបស់រដ្ឋ និងសម្រាប់អាជ្ញាធរពាក់ព័ន្ធ ដើម្បីអនុវត្តដោះស្រាយជម្លោះ។

សារាចរលេខ០៣ នេះ មានសក្តានុពល ប៉ុន្តែមិនត្រូវបានគេយកទៅអនុវត្តនៅក្នុងរាជធានីភ្នំពេញនោះទេ ព្រោះថាវាគ្រាន់តែជាសេចក្តីពន្យល់មិនមែនជាច្បាប់នោះទេ។ ហេតុផលមួយទៀត គឺរាជរដ្ឋាភិបាលមិនទាន់បានផ្សព្វផ្សាយសារាចរលេខ០៣ នេះឱ្យបានគ្រប់គ្រាន់ទៅដល់អាជ្ញាធរមូលដ្ឋានដែលទទួលខុសត្រូវក្នុងការអនុវត្តនៅឡើយទេ។ ក្នុងអំឡុងពេលសិក្សាស្រាវជ្រាវនេះ មានចំនួនពីរលើកផ្សេងគ្នាដែលអ្នកផ្តល់បទសម្ភាសបាននិយាយថាអាជ្ញាធរមិនធ្លាប់ឮអំពីសារាចរលេខ ០៣នេះទេ។ ខណៈពេលដែលយន្តការនេះ មានមធ្យោបាយដែលមានប្រយោជន៍ សម្រាប់ដោះស្រាយបញ្ហាច្បាប់ពាក់ព័ន្ធនឹងការកាន់កាប់ដីធ្លីខុសច្បាប់ យន្តការនេះក៏បានធ្វើការសន្និដ្ឋានថា សហគមន៍ដែលកាន់

[២៩] អនុក្រឹត្យស្តីពី "ការដាក់ឱ្យប្រើប្រាស់ស្តង់ដារនីតិវិធីប្រតិបត្តិសម្រាប់ការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ដែលទទួលបានហិរញ្ញប្បទានពីដៃគូរអភិវឌ្ឍន៍ ក្នុងព្រះរាជាណាចក្រកម្ពុជា" ឆ្នាំ ២០១៨ លេខ ២២ អនក្រ.បក

[៣០] ច្បាប់ភូមិបាល ឆ្នាំ ២០០១ មាត្រា ៣០

[៣១] ច្បាប់ភូមិបាល ឆ្នាំ ២០០១ មាត្រា ៣១

[៣២] ច្បាប់ភូមិបាល ឆ្នាំ ២០០១ មាត្រា ៥១

[៣៣] ច្បាប់ភូមិបាល ឆ្នាំ ២០០១ មាត្រា ៨៣

[៣៤] សារាចរស្តីពីការណោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់ដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមធានីភ្នំពេញ ទីក្រុង និងទីប្រជុំជនឆ្នាំ ២០១០

កាប់ដីរដ្ឋគឺខុសច្បាប់ ដែលធ្វើឱ្យអាជ្ញាធរកាន់តែមានទម្ងន់ផ្លូវច្បាប់ ប្រឆាំងនឹងការតវ៉ាទាមទារសិទ្ធិកាន់កាប់ដីធ្លី និងសិទ្ធិទទួលបានលំនៅឋានរបស់សហគមន៍។ នៅក្នុងករណីជាច្រើនការប្រើប្រាស់សារាចរលេខ០៣នៅក្នុងដំណើរការនៃការបណ្តេញចេញអាចមានសារៈប្រយោជន៍ ប៉ុន្តែវាក៏អាចបដិសេធ ឬច្រានចោលនូវការតវ៉ារបស់សហគមន៍ដែលអាចមានសិទ្ធិកាន់កាប់ដីដែលខ្លួនរស់នៅដោយផ្អែកលើច្បាប់ភូមិបាលផងដែរ។ ដំណើរការនៃការផ្លាស់ទីតាំងលំនៅថ្មីដែលមានរៀបរាប់នៅក្នុងសារាចរលេខ០៣ តម្រូវឱ្យការកាន់កាប់នៅតំបន់តាំងលំនៅថ្មីនោះ មានរយៈពេល ១០ឆ្នាំ មុនពេលទទួលបានប្លង់កម្មសិទ្ធិដីធ្លី ដែលនេះត្រូវបានគេរិះគន់ថាជារយៈពេលយូរ ដើម្បីទទួលបានសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី។[៣៥] ការសិក្សាស្រាវជ្រាវបានបង្ហាញថា ចាប់តាំងពីឆ្នាំ២០១០ ក្នុងចំណោមសហគមន៍ចំនួន ១៥ ដែលត្រូវបានបណ្តេញចេញ ឬកំពុងត្រូវបានបណ្តេញចេញមានតែសហគមន៍ពីរប៉ុណ្ណោះ ដែលបានរាយការណ៍ថាសារាចរលេខ០៣ ត្រូវបានប្រើប្រាស់អំឡុងពេលបណ្តេញចេញ ក្នុងនោះមានមួយសហគមន៍ជ្រើសរើសមិនប្រើប្រាស់សារាចរនេះនៅពេលដែលអាជ្ញាធរផ្តល់វាជាជម្រើសមួយដល់សហគមន៍។ សហគមន៍នេះ បានសម្រេចចិត្តអនុវត្តទៅតាមដំណើរការនានា ដែលមានក្នុងគម្រោងទទួលបានហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី ជាជាងប្រើប្រាស់សារាចរលេខ០៣។

ជំហានបន្ទាប់ក្នុងការអនុវត្តសិទ្ធិទទួលបានលំនៅឋានសម្រាប់ប្រជាពលរដ្ឋកម្ពុជា ត្រូវបានអនុម័តដោយ រាជរដ្ឋាភិបាលកម្ពុជាតាមរយៈគោលនយោបាយជាតិស្តីពីលំនៅឋានឆ្នាំ២០១៤។[៣៦] ដោយមិនគិតបញ្ចូលឱនភាពបច្ចុប្បន្នក្នុងការផ្គត់ផ្គង់លំនៅឋាន គោលនយោបាយនេះបានកំណត់ថាកម្ពុជាអាចត្រូវការលំនៅឋានថ្មី ជាង១,១ លានខ្នងនៅត្រឹមឆ្នាំ២០៣០។[៣៧] ដោយទទួលស្គាល់សិទ្ធិទទួលបានលំនៅឋានថាជាសិទ្ធិមនុស្ស គោលនយោបាយនេះក៏អនុវត្តផែនការសកម្មភាពមួយដែលតម្រូវឱ្យមាន៖

*ការចូលរួមសម្រេចពីសហគមន៍មូលដ្ឋាន ការផ្តល់ហិរញ្ញប្បទានសម្រាប់ជួសជុល ឬសាងសង់លំនៅឋាន ការសាងសង់លំនៅឋានថ្មីដើម្បីដោះស្រាយតម្រូវការចំពោះមុខ ការកំណត់មូលដ្ឋានសម្រាប់រៀបចំប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដីនៅទីក្រុង ទីប្រជុំជន និងជនបទ ការរៀបចំប្រភេទផ្សេងៗ នៃលំនៅឋាន ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ និងការកំណត់តម្លៃសេវានៃការអនុញ្ញាតសាងសង់។*[៣៨]

ជាចុងក្រោយ គោលនយោបាយស្តីពីការលើកទឹកចិត្ត និងការបង្កើតកម្មវិធីថ្នាក់ជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ[៣៩] បានលើកឡើងនូវដំណាក់កាលចំនួនពីរសម្រាប់អនុវត្តគោលដៅរបស់ខ្លួនក្នុងការផ្តល់នូវលំនៅឋានតម្លៃសមរម្យដល់ប្រជាពលរដ្ឋកម្ពុជា។ ដំណាក់កាលទីមួយមានគោលដៅលើកទឹកចិត្តដល់ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តឱ្យស្របនឹងផែនការរបស់រាជរដ្ឋាភិបាលផ្សេងទៀត និងដំណាក់កាលទីពីរគឺបង្កើតកម្មវិធីថ្នាក់ជាតិ ដើម្បីគាំទ្រដល់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ។[៤០] គោលនយោបាយនេះពឹងផ្អែកយ៉ាងខ្លាំងទៅលើការវិនិយោគក្នុងវិស័យឯកជន និងផ្តោតខ្លាំងទៅលើបទបញ្ញត្តិ[៤១] ប៉ុន្តែមិនបានផ្តល់ឱ្យដឹងអំពីការគ្រប់គ្រងការជួលលំនៅឋាន ឬចំនួនផ្ទះដែលអាចផ្តល់ឱ្យក្រុមប្រជាពលរដ្ឋក្រីក្រឡើយ។ បន្ថែមពីនេះ គោលនយោបាយនេះត្រូវបានរៀបចំឡើងជាមួយនឹងការបង្កើតនូវគណៈកម្មាធិការអន្តរក្រសួងមួយដែលគ្រប់គ្រង និងត្រួតពិនិត្យមើលគម្រោងសំណើនានារវាងវិស័យឯកជន និងរាជរដ្ឋាភិបាល។[៤២]

---

៣៥ អង្គការសមាគមធាងត្នោត ឆ្នាំ ២០១៣ "គោលនយោបាយសម្រាប់ប្រជាពលរដ្ឋក្រីក្រ?"
៣៦ គោលនយោបាយជាតិស្តីពីលំនៅឋាន ឆ្នាំ ២០១៤
៣៧ គោលនយោបាយជាតិស្តីពីលំនៅឋាន ឆ្នាំ ២០១៤
៣៨ គោលនយោបាយជាតិស្តីពីលំនៅឋាន ឆ្នាំ ២០១៤
៣៩ គោលនយោបាយស្តីពីការលើកទឹកចិត្ត និងការបង្កើតកម្មវិធីជាតិសម្រាប់អភិវឌ្ឍលំនៅឋានតម្លៃសមរម្យ ឆ្នាំ២០១៧
៤០ គោលនយោបាយស្តីពីការលើកទឹកចិត្ត និងការបង្កើតកម្មវិធីជាតិសម្រាប់អភិវឌ្ឍលំនៅឋានតម្លៃសមរម្យ ឆ្នាំ២០១៧
៤១ គោលនយោបាយស្តីពីការលើកទឹកចិត្ត និងការបង្កើតកម្មវិធីជាតិសម្រាប់អភិវឌ្ឍលំនៅឋានតម្លៃសមរម្យ ឆ្នាំ ២០១៧
៤២ អនុក្រឹត្យលេខ ០៤២ ស្តីពី ការបង្កើតគណៈកម្មាធិការអន្តរក្រសួងសម្រាប់គម្រោងអភិវឌ្ឍន៍លំនៅឋានតម្លៃសមរម្យ ឆ្នាំ២០១៨

## គោលការណ៍ណែនាំ

"សេចក្តីអត្ថាធិប្បាយរបស់អង្គការសហប្រជាជាតិគោលការណ៍ណែនាំស្តីពីការបណ្តេញចេញ និងការតាំងទីលំនៅថ្មី"[៤៣] ដែលត្រូវបានចេញផ្សាយដោយការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា (OHCHR) បានលើកឡើងពីសិទ្ធិរបស់បុគ្គលដែលត្រូវតែគោរពនៅក្នុងការបណ្តេញចេញ និងការតាំងទីលំនៅថ្មី។ ទោះជាមិនមានទម្ងន់ផ្នែកច្បាប់ និងមិនដឹងច្បាស់ថាអាជ្ញាធរណាខ្លះបានដឹងអំពីសេចក្តីអត្ថាធិប្បាយ និងគោលការណ៍ណែនាំនេះក៏ដោយ ក៏វានៅតែជាឧបករណ៍មានសារៈសំខាន់ដែលជួយបង្ហាញនូវគោលការណ៍សំខាន់ៗដែលត្រូវតែអនុវត្ត ដើម្បីគោរពច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សក្នុងអំឡុងពេលនៃការបណ្តេញចេញ និងការតាំងទីលំនៅថ្មី។




[៤៣] ការិយាល័យនៃឧត្តមស្នងការជាន់ខ្ពស់ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា (OHCHR) ឆ្នាំ ២០០៩ "សេចក្តីអត្ថាធិប្បាយ និងគោលការណ៍ណែនាំស្តីពីសិទ្ធិមនុស្សស្តីពីការបណ្តេញចេញ និងការតាំងទីលំនៅថ្មី"

### ៣.៣. ការពិនិត្យមើលឯកសារពាក់ព័ន្ធផ្សេងៗ

មានការសិក្សាស្រាវជ្រាវ ឬរបាយការណ៍ពីមុនជាច្រើនដែលសរសេរអំពីការបណ្តេញចេញ និងការតាំងទីលំនៅថ្មីនៅរាជធានីភ្នំពេញ។ អង្គការសមាគមធាងត្នោតពីមុនក៏ធ្លាប់បានសិក្សាស្រាវជ្រាវពីតំបន់តាំងទីលំនៅថ្មីនៅឆ្នាំ២០០៧ ក្នុងរបាយការណ៍ដែលមានចំណងជើងថា៖ "តំបន់តាំងទីលំនៅថ្មីក្នុងរាជធានីភ្នំពេញ"[៤៤] និងនៅឆ្នាំ២០១២ ក្នុងរបាយការណ៍ការពិត និងតួលេខទី២១ ដែលមានចំណងជើងថា៖ "ការតាំងទីលំនៅថ្មីនៅរាជធានីភ្នំពេញ៖ ៥៤កន្លែង និងមានកន្លែងផ្សេងទៀត?"[៤៥]។ ការសិក្សានៅឆ្នាំ២០០៧ បានផ្តល់នូវទិន្នន័យសំខាន់ៗពីតំបន់តាំងទីលំនៅថ្មីនៅ ៤១កន្លែងក្នុង និងជុំវិញរាជធានីភ្នំពេញ និងចងក្រងទុកនូវទំហំដី ក្រុមផ្តល់ការគាំទ្រ ចំនួនគ្រួសារដែលរងផលប៉ះពាល់ និងទីតាំងលំនៅថ្មីក៏ដូចជាទីតាំងលំនៅឋានពីមុន។ ការសិក្សាឆ្នាំ២០១២ ត្រូវបានធ្វើឡើងដោយប្រើប្រាស់ការសិក្សាឆ្នាំ២០០៧ ជាមូលដ្ឋាននិងមានបន្ថែមនូវសូចនាករផ្សេងទៀត វិភាគលើតំបន់បន្ថែមចំនួន១៤កន្លែងទៀត និងផ្តល់នូវសេចក្តីអត្ថាធិប្បាយ និងការវិភាគតារាងនៃសូចនាករសំខាន់ៗពីតំបន់តាំងទីលំនៅថ្មី។ ការសិក្សាទាំងពីរនេះ រួមជាមួយនឹងការអង្កេតជាប្រចាំ និងការងាររបស់អង្គការសមាគមធាងត្នោតនៅក្នុងសហគមន៍ក្រីក្រនៅទីក្រុងសុទ្ធតែមានសារៈសំខាន់ក្នុងការកំណត់តំបន់ពាក់ព័ន្ធដែលត្រូវបានធ្វើការស្រាវជ្រាវសម្រាប់ការសិក្សានេះ។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (OHCHR) បានចេញផ្សាយនូវការសិក្សាស្រាវជ្រាវនៅក្នុងឆ្នាំ២០១២ ដែលមានចំណងជើងថា៖ "ការបណ្តេញចេញ និងការតាំងទីលំនៅថ្មីនៅក្នុងប្រទេសកម្ពុជា៖ ទំហំនៃផលប៉ះពាល់ជាអវិជ្ជមានចំពោះមនុស្សឥទ្ធិពល និងដំណោះស្រាយ"[៤៦] ដែលជារបាយការណ៍យ៉ាងទូលំទូលាយបំផុតអំពីការបណ្តេញចេញ និងការតាំងទីលំនៅថ្មីនៅប្រទេសកម្ពុជា។ ការសិក្សាស្រាវជ្រាវរួមបញ្ចូលសហគមន៍នៅក្នុងរាជធានីភ្នំពេញ និងទូទាំងប្រទេស ហើយផ្តល់នូវការវិភាគពីដំណើរការនៃការបណ្តេញចេញ និងការតាំងទីលំនៅថ្មី។ ការរកឃើញមួយក្នុងចំណោមការរកឃើញសំខាន់ៗគឺកង្វះខាតនៃការចរចារឱ្យបានល្អិតល្អន់ជាមួយសហគមន៍ជាច្រើន។ របាយការណ៍មួយនេះ បានសន្និដ្ឋានថាមានតែករណីមួយប៉ុណ្ណោះដែលបានបង្ហាញនូវគំរូល្អសម្រាប់យកទៅអនុវត្តតាម ហើយការចូលរួមរបស់សហគមន៍ដែលត្រូវផ្លាស់ទីតាំងលំនៅថ្មីគឺមានភាពចាំបាច់នៅរាល់ដំណើរការនៃការបណ្តេញចេញ និងការតាំងទីលំនៅថ្មី។ របាយការណ៍នេះបានផ្តល់អនុសាសន៍ថា គោលការណ៍ណែនាំស្តីពីការបណ្តេញចេញ និងការតាំងទីលំនៅថ្មីគឺមានសារៈសំខាន់សម្រាប់ធ្វើឱ្យប្រសើរឡើងនូវដំណើរការនោះ។ រហូតមកដល់ពេលនេះ មានតែសេចក្តីអត្ថាធិប្បាយរបស់អង្គការសហប្រជាជាតិ គោលការណ៍ណែនាំស្តីពីការបណ្តេញចេញ និងការតាំងទីលំនៅថ្មីរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (OHCHR) ប៉ុណ្ណោះ ដែលត្រូវបានបោះពុម្ពផ្សាយ។ រាជរដ្ឋាភិបាលកម្ពុជា នៅមិនទាន់បានចេញគោលនយោបាយស្តីពីការតាំងទីលំនៅថ្មី ឬគោលនយោបាយផ្សេងៗទៀតក្រៅពីសារាចរលេខ០៣ នោះទេ។

ជាក់លាក់ជាងនេះទៅទៀត នៅក្នុងវិសាលភាពរបស់ពួកគេអ្នកស្រាវជ្រាវជាច្រើនបានពិនិត្យមើលការបណ្តេញចេញតាមរយៈកែវភ្នែកបែបមនោគមវិជ្ជា និងចិត្តសាស្ត្រ។ បើតាមរីឆាដស៊ុន(Richardson et al) (២០១៤) បានរកឃើញពីផលប៉ះពាល់ដ៏ធ្ងន់ធ្ងរនៃការបណ្តេញចេញមកលើសុខភាពផ្លូវចិត្តរបស់ស្ត្រីកម្ពុជា ដោយកត់សម្គាល់ពីការកើនឡើងនូវភាពទុក្ខព្រួយបញ្ហាជាមួយនឹងការគេង និងអារម្មណ៍។[៤៧] ទូច និងនីហ្វ (Touch and Neef) (២០១៥) វិភាគភាពធន់នឹងការបណ្តេញចេញនៅខេត្តកោះកុង និងខេត្តក្រចេះដោយពិភាក្សាអំពីវិធីសាស្ត្រតស៊ូមតិជាច្រើនដែលត្រូវបានប្រើដើម្បីឆ្លើយតបទៅនឹងការបណ្តេញចេញនៅក្នុងស្ថានភាពផ្សេងៗគ្នា។[៤៨] ជាចុងក្រោយការ

[៤៤] អង្គការសមាគមធាងត្នោត ឆ្នាំ ២០០៧ "តំបន់តាំងលំនៅថ្មី ក្នុងរាជធានីភ្នំពេញ"
[៤៥] អង្គការសមាគមធាងត្នោត ឆ្នាំ ២០១២ "ការតាំងទីលំនៅថ្មីនៅក្នុងរាជធានីភ្នំពេញ៖ ៥៤ ទីតាំង និងនៅមានកន្លែងផ្សេងទៀត?" ការពិត និងតួលេខ ទី ២១
[៤៦] ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា (OHCHR) ឆ្នាំ ២០១២ "ការបណ្តេញចេញ និងការតាំងទីលំនៅថ្មីនៅក្នុងប្រទេសកម្ពុជា៖ តម្លៃនៃផលប៉ះពាល់ជាអវិជ្ជមានចំពោះមនុស្ស ឥទ្ធិពល និងដំណោះស្រាយ"
[៤៧] Richardson et al ២០១៤ 'ផលប៉ះពាល់សុខភាពផ្លូវចិត្តនៃការបណ្តេញចេញដោយបង្ខំលើស្ត្រីនៅកម្ពុជា'។ ទិនានុប្បវត្តិអភិវឌ្ឍន៍អន្តរជាតិ។
[៤៨] ភាពធន់នឹងការដណ្តើមយកដីធ្លីនិងការផ្លាស់ទីលំនៅនៅតាមជនបទនៃប្រទេសកម្ពុជា។ ការរំលោភយកដីធ្លីទំនាស់និងបំរែបំរួលបរិស្ថានកសិកម្ម៖ ទស្សនវិស័យពីអាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍សាកលវិទ្យាល័យឈៀងម៉ៃ ៥-៦ មិថុនា ២០១៥ សន្និសីទលេខ ១៦ ។

ស្រាវជ្រាវរបស់អាស៊ានហៅស៍ ក្រោមចំណងជើងថា “ការអភិវឌ្ឍន៍ដែលធ្វើឱ្យបាត់បង់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ”ក្នុងឆ្នាំ២០១៨ ដែលសិក្សាពីអនាគតសហគមន៍ដែលរស់នៅជុំវិញបឹងទំពុនជាតំបន់ដែលបានគ្រោងទុកសម្រាប់ការអភិវឌ្ឍន៍ និងអាចប្រឈមការបណ្តេញចេញ។[៤៩]

ជាចុងក្រោយ សៀវភៅបង្ហាញពីទិដ្ឋភាពវិជ្ជមានអំពីការផ្លាស់ប្តូរទីតាំងលំនៅថ្មីសម្រាប់ប្រជាពលរដ្ឋក្រីក្រត្រូវបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ២០០១ ដោយអ្នកកាសែតឈ្មោះ ប៉ែន ខន ដែលមានចំណងជើងថា៖ “សម្តេច ហ៊ុន សែន និងការតាំងទីលំនៅថ្មីរបស់ប្រជាពលរដ្ឋក្រីក្រ”។[៥០] សៀវភៅនេះ មើលទៅលើភាពក្រីក្រ និងកត្តាផ្សេងទៀត ក្នុងដំណើរការនៃការបណ្តេញចេញ និងតាំងទីលំនៅថ្មីតាមរយៈកញ្ចក់ឆ្លុះនៃការ“អភិវឌ្ឍ”។ សៀវភៅនេះឈរលើទស្សនៈថា ភាពក្រីក្រគឺជាកត្តាជំរុញឱ្យសហគមន៍ផ្លាស់ទីតាំងលំនៅឋានរបស់ពួកគេពីជនបទមករាជធានីភ្នំពេញ។ សៀវភៅនេះក៏បានលើកឡើងពីមូលនិធិអភិវឌ្ឍន៍ប្រជាពលរដ្ឋក្រីក្រនៅទីក្រុងដែលសម្តេច ហ៊ុន សែន ធ្លាប់បាន ឧបត្ថម្ភមូលនិធិផ្ទាល់ខ្លួន ដើម្បីជួយដល់ការបង្កើតនូវប្រព័ន្ធកម្ចីសម្រាបឱ្យសហគមន៍ក្រីក្រនៅក្នុងទីក្រុងខ្ចីលុយដើម្បីសាងសង់ផ្ទះ ឬវិនិយោគផ្នែកសេដ្ឋកិច្ច។

---

[៤៩] Asienhaus ២០១៨ “ ការអភិវឌ្ឍដោយការចំណាយរបស់ប្រជាពលរដ្ឋក្នុងតំបន់។ ករណីសិក្សាពីបឹងទំពុនក្នុងរាជធានីភ្នំពេញ (កម្ពុជា) ឆ្នាំ ២០១៨” តំណភ្ជាប់៖ < https://www.asienhaus.de/nc/publikationen/detail/development-at-the-expense-of-the-local-population-a-case-study-from-boeung-tumpun-lake- phnom-penh/>

[៥០] Khon, P ឆ្នាំ ២០០១ “សម្តេច ហ៊ុន សែន និងការតាំងលំនៅថ្មីរបស់ប្រជាពលរដ្ឋក្រីក្រ” ឧបត្ថម្ភមួយផ្នែកដោយសាលារាជធានីភ្នំពេញ គ្រឹះស្ថានបោះពុម្ព SVA (JRSC)

## ករណីសិក្សា៖ ការបាត់បង់មុខរបរនេសាទត្រី

*កាលពីខែកុម្ភៈ ឆ្នាំ២០១៩ នៅតាមមាត់បឹងតាមោក ដែលជាបឹងដ៏ធំរបស់រាជធានីភ្នំពេញ មានប្រជាពលរដ្ឋរស់នៅចំនួន១៨គ្រួសារត្រូវបានបណ្តេញចេញ ដោយសារពួកគាត់មករស់នៅមិនស្របច្បាប់លើដីសាធារណៈរបស់រដ្ឋ។ អាជ្ញាធរបានអះអាងថា ការមករស់នៅលើដីសាធារណៈរដ្ឋមិនអាចយកធ្វើជាកម្មសិទ្ធិបានទេ។ ប៉ុន្តែមានគ្រួសារដែលមានផ្ទះធំៗមួយចំនួនដែលកំពុងរស់នៅមានព្រំប្រទល់ជាប់បឹងនោះមិនត្រូវបានបណ្តេញចេញទេ។ ជាង៥០គ្រួសារបានទទួលសេចក្តីជូនដំណឹងពីការបណ្តេញចេញពីអាជ្ញាធរមូលដ្ឋាន ប៉ុន្តែមិនបានបញ្ជាក់ច្បាស់ថា តើពួកគេត្រូវបានបណ្តេញចេញនៅពេលណានោះទេ។*

*" យើងមករស់នៅទីនេះជាង៨ឆ្នាំមកហើយ ហើយមានគ្រួសារខ្លះតិចជាង ប៉ុន្តែមានខ្លះ ៥ឆ្នាំ និង៦ឆ្នាំ។ យើងរស់នៅទីនេះអាស្រ័យផលដោយការប្រកបមុខរបរចិញ្ចឹមត្រី និងនេសាទត្រី" ។*

*នៅខែកុម្ភៈ ឆ្នាំ២០១៦ រាជរដ្ឋាភិបាលបានកំណត់ផ្ទៃបឹងតាមោកជាទ្រព្យសម្បត្តិរដ្ឋ។[៥១] ផ្ទៃកមួយចំនួននៃផ្ទៃបឹងនេះត្រូវបានធ្វើអនុប្រយោគ ហើយប្រគល់ជូនក្រុមហ៊ុនឯកជនដើម្បីអភិវឌ្ឍន៍។[៥២] ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ មានប្រជាពលរដ្ឋជាង៦០គ្រួសារដែលបានមករស់នៅជាប់បឹង ឬមាត់បឹង បានទទួលលិខិតជូនដំណឹងពីអាជ្ញាធរដោយឱ្យពួកគេចេញក្នុងរយៈពេល ៧ថ្ងៃ។ នៅពេលចុះទៅអនុវត្តសេចក្តីជូនដំណឹងនោះ នគរបាលបានប្រាប់ប្រជាពលរដ្ឋថា ពួកគេគួរតែចេញដោយខ្លួនឯងប្រសើរជាងអាជ្ញាធរប្រើប្រាស់វិធានការរដ្ឋបាល។*

*" យើងនឹងមិនទទួលខុសត្រូវចំពោះការបាត់ ការខូចខាតនៃទ្រព្យសម្បត្តិណាមួយពីការបណ្តេញចេញនោះទេ[៥៣] " សម្តីរបស់នគរបាលទៅកាន់ប្រជាសហគមន៍។*

*គ្រួសារមួយបានប្រាប់អ្នកស្រាវជ្រាវថា អាជ្ញាធរហាមគេមិនឱ្យទៅរកអង្គការ ឬប្រព័ន្ធផ្សព្វផ្សាយណាមួយជួយទេ។ គ្រួសារដែលមានកូនតូចៗបាននិយាយថា អាជ្ញាធរបានប្រាប់ថាពួកគេអាចបន្តរស់នៅទីនេះបាន ប៉ុន្តែការរស់នៅនៅទីនេះគឺខុសច្បាប់ ហើយមិនអាចធ្វើលំនៅឋានបានឡើយ។ គ្រួសារមួយបានរស់នៅក្រោមម្លប់តង់ដែលធ្វើពីកំណាត់អស់ជាច្រើនសប្តាហ៍ ក្រោយពីការបណ្តេញចេញ។*

*សម្រាប់គ្រួសារមួយចំនួនទៀត ដែលកំពុងរកចំណូលបានតាមរយៈនេសាទត្រី ហើយពួកគេខ្លះក៏បានប្រើប្រាក់កម្ចីដើម្បីទិញសំណាញ់រកត្រីនៅក្នុងបឹង។ មានគ្រួសារមួយចំនួនមិនបារម្ភពីការបាត់សិទ្ធិក្នុងការរស់នៅក្នុងបឹងនោះទេ ប៉ុន្តែពួកគេបារម្ភពីការបាត់បង់សិទ្ធិក្នុងការនេសាទត្រី។*

*ប្រជាពលរដ្ឋដែលកំពុងរស់នៅទីនោះ ពុំដែលបានទទួលបានព័ត៌មានជាផ្លូវការណាមួយស្តីពីសិទ្ធិក្នុងការប្រើប្រាស់បឹង ឬសិទ្ធិក្នុងការរស់នៅក្នុងបឹងនោះឡើយ។ ដោយសារប្រជាពលរដ្ឋទាំងនោះគ្មានមេធាវីការពារក្តីដូច្នេះពួកគាត់មានការភ័យខ្លាចក្នុងការតតាំងការពារក្តីនៅតុលាការទាក់ទងនឹងការបណ្តេញចេញនេះ។ បច្ចុប្បន្ននេះមានចំនួន១៨គ្រួសារ ប៉ុណ្ណោះដែលចាកចេញដោយខ្លួនឯង ចំណែកឯគ្រួសារជាច្រើន និងគ្រួសារដែលមានផ្ទះធំៗនៅតែអនុញ្ញាតបន្តរស់នៅទីនោះ។*

---

៥១ អនុក្រឹត្យលេខ២០ ស្តីពីការបោះបង្គោលព្រំដែនបឹងតាមោកជាទ្រព្យសម្បត្តិរដ្ឋ ឆ្នាំ២០១៦។

៥២ អនុក្រឹត្យលេខ១៣២ ស្តីពីការពិនិត្យឡើងវិញនៃបឹងតាមោកឆ្នាំ ២០១៨។

៥៣ មិនយូរប៉ុន្មានគាត់ក៏ត្រូវបានអភិបាលស្រុកនិយាយទៅកាន់ប្រព័ន្ធផ្សព្វផ្សាយ។ មើល Khuon ឆ្នាំ២០១៩ ។ 'ការបណ្តេញចេញអ្នកភូមិបឹងតាមោក' ។ កាសែតខ្មែរថាមស៍ តំណភ្ជាប់៖ <https://www.khmertimeskh.com/50573899/evictions-for-boeng-tamok-villagers>



**ផ្ទះរបស់អ្នកនេសាទត្រីនៅក្នុងបឹង (ថតដោយអង្គការសមាគមជាងត្នោត ឆ្នាំ២០១៩)**

*នៅលើជញ្ជាំងម្ខាងបុរសនេសាទត្រីបានសរសេរថា តើអាជ្ញាធរអនុញ្ញាតឱ្យគាត់នេសាទត្រីនៅតំបន់នេះទៀតដែរឬទេ? ដោយជួល ពីរ ឬបីកន្លែងនៅក្នុង ហើយគ្មានផ្ទះជួលនៅជិតបុរសនេសាទត្រី គ្រួសាររបស់គាត់ និងគ្រួសារជាច្រើនផ្សេងទៀតដែលនេសាទត្រីបានចាកចេញពីតំបន់នោះ ឬរស់នៅក្នុងតង់ដែលងាយរងគ្រោះដោយការបណ្តេញចេញនៅពេលខាងមុខ។*

## ៤. ការរកឃើញសំខាន់ៗ

### ៤.១. ការបណ្ដេញចេញ និងការផ្លាស់ប្ដូរទីតាំងលំនៅថ្មី

តារាងទី ៤៖ ការបណ្ដេញចេញតាមឆ្នាំ

| | សហគមន៍ដែលត្រូវគេបណ្ដេញចេញ និងត្រូវបានផ្លាស់ប្ដូរទីតាំងថ្មី | សហគមន៍ដែលតាំងទីលំនៅថ្មីដោយខ្លួនឯង | សហគមន៍ដែលចេញ (តែគ្មានការផ្លាស់ប្ដូរទីតាំងថ្មី)ត្រូវគេបណ្ដេញចេញ | សហគមន៍ស្ថិតក្នុងដំណើរការនៃការបណ្ដេញចេញ | សរុប |
|---|---|---|---|---|---|
| មុនឆ្នាំ ១៩៩៩ | ៤ | ០ | ០ | ០ | ៤ |
| ឆ្នាំ២០០០ ដល់ ឆ្នាំ២០១០ | ៣៩ | ៦ | ០ | ០ | ៤៥ |
| ឆ្នាំ២០១១ ដល់ ឆ្នាំ២០១៦ | ៥ | ០ | ៤ | ០ | ៩ |
| ឆ្នាំ២០១៦ ដល់ ឆ្នាំ២០១៩ | ២ | ០ | ០ | ៨ | ១០ |
| សរុប | ៥០ | ៦ | ៤ | ៨ | ៦៨ |

ជាង៦០ភាគរយ នៃសហគមន៍ដែលត្រូវគេបណ្ដេញចេញ និងត្រូវផ្លាស់ទីតាំងលំនៅថ្មី ឬកំពុងស្ថិតក្នុងដំណើរការនៃការបណ្ដេញចេញ បានរងផលប៉ះពាល់ពីការបណ្ដេញចេញនេះ នៅចន្លោះឆ្នាំ២០០០ និងឆ្នាំ២០១០។ ច្បាប់ភូមិបាលឆ្នាំ២០០១ មានប្រសិទ្ធភាពតិចតួចបំផុតក្នុងការការពារសិទ្ធិរបស់សហគមន៍ក្នុងការកាន់កាប់ដីធ្លី និងនៅក្នុងរយៈពេលប៉ុន្មានឆ្នាំក្រោយពីច្បាប់នេះបានចូលជាធរមាន គេសង្កេតឃើញថាច្បាប់នេះបានផ្ដល់ទម្ងន់ផ្លូវច្បាប់ទៅលើដំណើរការនៃការបណ្ដេញប្រជាពលរដ្ឋ។ ការបណ្ដេញចេញភាគច្រើនកើតឡើងបន្ទាប់ពីច្បាប់នេះ បានចូលជាធរមាន និងដោយសំអាងលើហេតុផលថាសហគមន៍ទាំងនេះ បានកាន់កាប់ទ្រព្យសម្បត្តិសាធារណៈដោយខុសច្បាប់ដូចដែលមានចែងនៅក្នុងច្បាប់នេះ។[៥៤] លើសពីនេះទៅទៀត វត្តមានរបស់សារាចរណែនាំលេខ០៣ មិនបានធ្វើឱ្យការបណ្ដេញប្រជាពលរដ្ឋចេញថមថយ ឬពុំបានផ្ដល់ទីតាំងលំនៅថ្មីដល់ពួកគេដែលប្រសើរជាងមុននោះឡើយបន្ទាប់ពីសារាចរនេះត្រូវបានចេញផ្សាយនៅក្នុងឆ្នាំ២០១០។ ចាប់តាំងពីសារាចរនេះត្រូវបានអនុម័តមក យ៉ាងហោចណាស់មានសហគមន៍ចំនួន១៩ ដែលត្រូវគេបណ្ដេញចេញ ឬកំពុងរងផលប៉ះពាល់ពីការបណ្ដេញចេញនេះ ហើយមានតែសហគមន៍ចំនួន៣ ប៉ុណ្ណោះ រាយការណ៍ថាអាជ្ញាធរត្រៀមប្រើប្រាស់ ឬបានប្រើប្រាស់សារាចរណែនាំលេខ០៣នេះ។

ការស្រាវជ្រាវនេះ បានបង្ហាញឱ្យដឹងថាមិនមានទំនាក់ទំនងខ្លាំងរវាងការបង្កើតច្បាប់បញ្ញត្តិ និងគោលនយោបាយស្ដីពីសិទ្ធិកាន់កាប់ដីធ្លី ជាមួយនឹងលទ្ធផលជាវិជ្ជមាននៃការបណ្ដេញចេញ និងការផ្លាស់ទីលំនៅថ្មីនៅក្នុងរាជធានីភ្នំពេញឡើយ។ សម្រាប់ច្បាប់ភូមិបាលវិញ វាមិនអាចទប់ស្កាត់ទៅនឹងការបណ្ដេញចេញបានទេ។ សារាចរណែនាំលេខ០៣ ត្រូវគេបង្កើតឡើង ដើម្បីដោះស្រាយបញ្ហានៃការកាន់កាប់ទ្រព្យសម្បត្តិសាធារណៈដោយផ្ដល់ឱកាសឱ្យភាគីពាក់ព័ន្ធពិភាក្សា ដើម្បីស្វែងរកដំណោះស្រាយដ៏សមរម្យមួយសម្រាប់សហគមន៍ក្រីក្រ និងអាជ្ញាធរ។ ផ្ទុយទៅវិញ បើតាមភស្តុតាងដែលមានសារាចរលេខ០៣ ពុំត្រូវបានគេយកមកប្រើប្រាស់ឱ្យអស់ពីលទ្ធភាពនោះទេ។

[៥៤] ច្បាប់ភូមិន្ទបាល ឆ្នាំ២០០១ មាត្រា ៤៣



ស្ថានភាពផ្លូវ និងផ្ទះរបស់សហគមន៍ (ថតដោយអង្គការសមាគមធាងត្នោត ឆ្នាំ២០១៩)

ក្រាហ្វិចទី ១៖ ការបណ្តេញចេញក្នុងរយៈពេលកន្លងមក (ឆ្នាំ១៩៨០ ដល់ឆ្នាំ២០១៩)



ទិន្នន័យនៅក្នុងឆ្នាំបោះឆ្នោតបង្ហាញឱ្យដឹងថាអាចមាននិន្នាការសម្រាប់ពេលវេលានៃការបណ្តេញចេញ។ នៅពេលមានការរៀបចំបោះឆ្នោតជាតិ (ឆ្នាំ១៩៩៨ ឆ្នាំ២០០៣ ឆ្នាំ២០០៨ ឆ្នាំ២០១៣ និងឆ្នាំ២០១៨) ជាមធ្យមមានការបណ្តេញចេញចំនួនមួយករណីក្នុងមួយឆ្នាំ ដោយនៅក្នុងឆ្នាំបោះឆ្នោត២០០៣ មានការបណ្តេញចេញចំនួនបីករណី ហើយនៅក្នុងឆ្នាំបោះឆ្នោត២០១៨ មិនមានករណីបណ្តេញចេញនោះទេ។ ប្រមាណជា៩០ភាគរយ នៃការបណ្តេញចេញដែលត្រូវបានសិក្សាកើតឡើងនៅក្នុងឆ្នាំដែលគ្មានការបោះឆ្នោត។ នេះអាចបង្ហាញថា អាជ្ញាធរមានការបារម្ភចំពោះការបណ្តេញប្រជាពលរដ្ឋចេញ នៅក្នុងរយៈពេលបោះឆ្នោត ឬអាចនិយាយបានថាជាយុទ្ធសាស្ត្ររបស់អាជ្ញាធរ នៅក្នុងការគ្រប់គ្រងការបណ្តេញចេញដើម្បីកាត់បន្ថយភាពតានតឹងនៅក្នុងសហគមន៍។ អាចនិយាយបានម្យ៉ាងទៀតថានៅក្នុងអំឡុង ពេលបោះឆ្នោត អាជ្ញាធរប្រហែលជាជាប់រវល់ធ្វើកិច្ចការផ្សេងៗ នៅមុនពេលការបោះឆ្នោតមកដល់។ គេក៏សម្គាល់ឃើញដែរថា នៅក្នុងរយៈពេល ៦ខែមុនពេលបោះឆ្នោតពុំមានសហគមន៍ណាមួយត្រូវគេបណ្តេញចេញនោះទេ ដែលនេះត្រូវបានគេយល់ឃើញជារឿងវិជ្ជមានថាព្រោះដំណើរការនៃការបណ្តេញចេញអាចប៉ះពាល់ដល់សិទ្ធិបោះឆ្នោតរបស់ប្រជាពលរដ្ឋដែលត្រូវបានបណ្តេញចេញពីទីលំនៅឋាន។ ទោះជាយ៉ាងនេះក្តី និន្នាការនេះនៅតែបង្ហាញថាអាជ្ញាធរទំនងនឹងធ្វើការបណ្តេញប្រជាពលរដ្ឋចេញនៅក្នុងរយៈពេលដែលគ្មានការបោះឆ្នោត។ ប៉ុន្តែគេនៅតែមិនអាចកំណត់បាននៅឡើយថាវាគឺជាចេតនារបស់អាជ្ញាធរឬយ៉ាងណា ហើយបើសិនជាមានចេតនាពិតនោះ តើដើម្បីបញ្ចៀសផលប៉ះពាល់ជា អវិជ្ជមានលើប្រជាពលរដ្ឋដែលត្រូវបានគេបណ្តេញចេញ ឬលើអ្នកដែលធ្វើការបណ្តេញចេញ ឬក៏ដោយសារតែអាជ្ញាធរជាប់រវល់បំពេញកិច្ចការអាទិភាពផ្សេងទៀតក្នុងអំឡុងពេលទាំងនោះ។

## ៤.២. ដំណើរការនៃការបណ្តេញចេញ

---

*"យើងរស់នៅទីនេះតាំងពីឆ្នាំ១៩៩០មកម្លេះ។"*

*-សម្តីរបស់សមាជិកសហគមន៍ដែលកំពុងប្រឈមនឹងការបណ្តេញចេញពីលំនៅឋាន។*

---

### ៤.២.១. មូលហេតុនៃការបណ្តេញចេញ

យោងតាមបទសម្ភាសជាមួយនឹងសមាជិកសហគមន៍។ ហេតុផលទូទៅ សម្រាប់ការបណ្តេញប្រជាពលរដ្ឋសហគមន៍ចេញពីលំនៅឋានគឺដោយសារតែប្រជាពលរដ្ឋទាំងនោះ កាន់កាប់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋដោយខុសច្បាប់។ នេះជាហេតុផលសំអាងសម្រាប់ការបណ្តេញចេញនៃសហគមន៍ជាង៧០ភាគរយ ហើយនេះក៏ជាហេតុផលចម្បង ដែលសហគមន៍មួយចំនួនកំពុងប្រឈមនឹងការបណ្តេញចេញ។

សហគមន៍ដែលត្រូវបានគេបណ្តេញចេញដោយសារកាន់កាប់ទ្រព្យសម្បត្តិសាធារណៈជាធម្មតាគឺជាសហគមន៍ដែលត្រូវបានបណ្តេញចេញដោយក្រុមហ៊ុនអភិវឌ្ឍន៍។ នៅពេលមានការពាក់ព័ន្ធពីក្រុមហ៊ុនឯកជន ភាគីក្រុមហ៊ុនជាទូទៅទទួលបានសិទ្ធិអភិវឌ្ឍលើដីដែលពីមុនជាដីសាធារណៈរបស់រដ្ឋ ហើយប្រជាសហគមន៍នៅទីនោះ ត្រូវបានគេប្រាប់ថាពួកគេគ្មានសិទ្ធិកាន់កាប់ដីនោះទេ ឬពេលខ្លះនៅក្នុងដំណើរការនៃការបណ្តេញចេញ ក្រុមហ៊ុនបានទទួលសិទ្ធិជួលនិងអភិវឌ្ឍដីដែលសមាជិកសហគមន៍ត្រូវបានបណ្តេញចេញ។ មានប្រជាពលរដ្ឋមួយចំនួនមិនពេញចិត្តនៅពេលខ្លួនគ្មានសិទ្ធិកាន់កាប់ដីដែលខ្លួនរស់នៅ ប៉ុន្តែបែរជាក្រុមហ៊ុនឯកជនមានសិទ្ធិកាន់កាប់ទៅវិញ។

**តារាងទី ៥៖** ហេតុផលសម្រាប់ការបណ្តេញចេញ ឬការផ្លាស់ទីតាំងលំនៅថ្មី*

| មូលហេតុផ្លូវការ (ឬមូលហេតុផ្តល់ឱ្យសហគមន៍) | សហគមន៍ដែលត្រូវបានបណ្តេញចេញ និងផ្លាស់ទីតាំងថ្មី | សហគមន៍ដែលត្រូវបានបណ្តេញចេញ (គ្មានការផ្លាស់ទីតាំងថ្មី) | សហគមន៍ស្ថិតក្នុងដំណើរការនៃការបណ្តេញចេញ | សរុប |
|---|---|---|---|---|
| ក្រុមហ៊ុនអភិវឌ្ឍន៍ | ៨ | ១ | ០ | ៩ |
| អគ្គីភ័យ | ៥ | ០ | ០ | ៥ |
| ដីកម្មសិទ្ធិឯកជន | ២ | ០ | ០ | ២ |
| ដីសាធារណៈរបស់រដ្ឋ | ៣៥ | ៣ | ៨ | ៤៦ |
| **សរុប** | ៥០ | ៤ | ៨ | ៦២ |

**សហគមន៍ចំនួន៦ ត្រូវបានដកចេញពីតារាងនេះ ដោយសារតែពួកគេបានចាកចេញដោយខ្លួនឯង។ ដូច្នេះ ហេតុផលនៃការចាកចេញនោះ និងមិនពាក់ព័ន្ធនឹងដំណើរការនៃការបណ្តេញចេញជាផ្លូវការនោះទេ។*

ជាចុងក្រោយ អគ្គីភ័យគឺជាមូលហេតុដែលធ្វើឱ្យសហគន៍ចំនួន៥ ត្រូវបង្ខំចិត្តតាំងទីលំនៅថ្មី ហើយអគ្គីភ័យនេះ នៅតែជាបញ្ហាប្រឈមចម្បងដែលសហគមន៍ក្រីក្រនៅទីក្រុងបន្តជួបប្រទះ។ ការរួមផ្សំគ្នានៃសម្ភារៈដែលងាយឆាបឆេះ ដូចជាឈើ ប្លាស្ទីក បូករួមនឹងភាពចង្អៀតណែនតាន់តាប់ ភាពមិនប្រក្រតីនៃប្រព័ន្ធអគ្គិសនី ភ្លើងសម្រាប់ចម្អិនអាហារ និងសេវាគ្រប់គ្រងសំរាមដែលគ្មានគុណភាពធ្វើឱ្យសហគមន៍ក្រីក្រទាំងអស់នេះងាយរងគ្រោះថ្នាក់បណ្តាលមកពីអគ្គីភ័យដែលអាចបំផ្លាញសហគមន៍ទាំងមូលបានដោយងាយ។ ចំពោះសហគមន៍ដែលរងប៉ះពាល់ដោយអគ្គីភ័យ អាជ្ញាធរបានបញ្ជាក់ជំហរយ៉ាងច្បាស់លាស់ថាពួកគេមិនអាចកសាងទីលំនៅសារជាថ្មីនៅទីតាំងដែលបានបំផ្លាញដោយអគ្គីភ័យបានទេ។ ការហាមឃាត់នេះ បង្ហាញឱ្យឃើញថា ពួកគេត្រូវអាជ្ញាធរបណ្តេញចេញពីទីលំនៅរបស់ខ្លួនដោយប្រយោល។

### ៤.២.២. ការយល់ព្រម ការបង្ខិតបង្ខំ និងការរួបរួមគ្នារបស់សហគមន៍

មានតែសមាជិកសហគមន៍មួយប៉ុណ្ណោះ ដែលយល់ព្រមចាកចេញ ឬព្រមតាំងទីលំនៅថ្មី។ ប្រជាពលរដ្ឋភាគច្រើនដែលបានផ្តល់បទសម្ភាស បានលើកឡើងថាពួកគេយល់ព្រមចាកចេញដោយសារការភ័យខ្លាចថាអាជ្ញាធរនឹងប្រើអំពើហិង្សាក្នុងការបណ្តេញពួកគេចេញពីលំនៅឋាន ឬបំផ្លាញទ្រព្យសម្បត្តិរបស់ពួកគេដោយគ្មានការទូទាត់សំណងនៅក្នុងដំណើរការនៃការបណ្តេញចេញ។ នៅក្នុងករណីខ្លះ ប្រជាពលរដ្ឋត្រូវបង្ខំចិត្តចាកចេញជាជាងត្រូវប្រឈមមុខនឹងការបណ្តេញចេញដោយបង្ខំ។ភាពខុសគ្នារវាងការចាកចេញដោយស្ម័គ្រចិត្តនិងការចាកចេញដោយបង្ខំ បើយោងតាមបរិបទនៅក្នុងរាជធានីភ្នំពេញគឺស្ថិតនៅត្រង់ថា តើការបណ្តេញចេញនោះ មានពាក់ព័ន្ធនឹងការគំរាមកំហែងក្នុងទម្រង់ណាមួយដែរឬអត់។

សមាជិកសហគមន៍មួយ បានបង្ហាញពីឆន្ទៈខ្ពស់ក្នុងការចាកចេញពីសហគមន៍របស់ខ្លួនដោយសារពួកគេទទួលបានសំណងយ៉ាងសមរម្យ។ សហគមន៍នេះ មានទស្សនៈវិជ្ជមានចំពោះដំណើរការនៃការបណ្តេញចេញ និងការផ្លាស់ទីតាំងលំនៅថ្មី ដែលគេសម្គាល់ឃើញថាពួកគេទទួលបានសំណងជាដីសម្រាប់តាំងលំនៅជាថ្មីក្នុងទំហំធំ និងមានទំនាក់ទំនងល្អជាមួយអាជ្ញាធរ។

ប៉ុន្តែនៅក្នុងករណីខ្លះ មានការខ្វែងគំនិតគ្នារវាងសមាជិកនៅក្នុងសហគមន៍ជុំវិញបញ្ហាថាតើការចាកចេញរបស់ពួកគេគឺធ្វើឡើងដោយឆន្ទៈ ឬដោយការបង្ខិតបង្ខំ។ ការស្រាវជ្រាវនេះ មិនបានសាកសួរគ្រប់ក្រុមគ្រួសារ

នៅក្នុងសហគមន៍នោះទេ ប៉ុន្តែគេសង្កេតឃើញថា ប្រជាពលរដ្ឋភាគច្រើន មានទស្សនៈខុសៗគ្នាជុំវិញដំណើរការនៃការបណ្តេញចេញនេះ។ ប្រជាពលរដ្ឋខ្លះយល់ថា ពួកគេមិនដែលយល់ព្រមចាកចេញ និងមិនដែលទទួលបានឱកាសចូលរួមក្នុងកិច្ចពិភាក្សារបស់សហគមន៍អំពីការចាកចេញនេះទេ។

### ៤.២.៣. ការជូនដំណឹងមុនពេលបណ្តេញចេញ

បទដ្ឋានស្តីពីសិទ្ធិមនុស្សបានកំណត់ថា មុនពេលប្រជាពលរដ្ឋត្រូវបានបណ្តេញចេញពីលំនៅឋានរបស់ខ្លួន ពួកគេត្រូវទទួលបានដំណឹងពីការបណ្តេញចេញនេះយ៉ាងហោចណាស់ឱ្យបាន៩០ថ្ងៃមុន។[៥៥] ការទទួលដំណឹងក្នុងរយៈពេលមិនសមស្រប សហគមន៍ពុំអាចត្រៀមខ្លួនរួចរាល់សម្រាប់ការចាកចេញទៅតាំងទីលំនៅថ្មី និងដើម្បីកាត់បន្ថយផលប៉ះពាល់ដែលកើតឡើងដោយសារការបណ្តេញចេញនេះឡើយ។ នៅក្នុងករណីមួយ ដែលកើតឡើងក្នុងឆ្នាំ២០១៩ ប្រជាពលរដ្ឋត្រូវគេជូនដំណឹងពីការបណ្តេញចេញក្នុងរយៈពេលមិនដល់ ២ខែផង បើទោះបីពួកគេភាគច្រើនរស់នៅក្នុងសហគមន៍នេះអស់រយៈពេលជាង ១៥ឆ្នាំក៏ដោយ។ គ្រួសារមួយដែលជាជនរងគ្រោះពីការបណ្តេញចេញនេះ បានរៀបរាប់ពីទុក្ខលំបាកនៅពេលពួកគេគ្មានសល់អ្វីសោះ ដោយត្រូវគេបង្ខំឱ្យរុះរើផ្ទះរបស់ខ្លួន និងរស់នៅក្រោមដំបូលតង់កៅស៊ូនៅក្រោមកំដៅថ្ងៃដ៏ក្តៅបំផុត។ការបណ្តេញចេញដែលធ្វើឡើងក្នុងរយៈពេលខ្លីធ្វើឱ្យពួកគេគ្មានពេលវេលាគ្រប់គ្រាន់ ក្នុងការរៀបចំផ្ទះសម្បែងថ្មី និងជាលទ្ធផលកុមារតូចៗត្រូវរស់នៅដោយរងទុក្ខដោយសារកំដៅព្រះអាទិត្យ រស់នៅហាលភ្លៀងហាលខ្យល់ និងរស់ក្នុងធូលីដីដោយសារគ្មានជម្រកសមរម្យ និងការការពារគ្រប់គ្រាន់។


រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៣ សរ
សារាចរ
ស្តីពី
ការដោះស្រាយសំណង់បណ្តោះអាសន្ន
លើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់
ដោយខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជន

[៥៥] ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា ឆ្នាំ២០០៩ 'សេចក្តីអត្ថាធិប្បាយ និងគោលការណ៍ណែនាំសិទ្ធិមនុស្ស ស្តីពីការបណ្តេញចេញ និងការតាំងទីលំនៅថ្មី'

តារាងទី ៦៖ ការជូនដំណឹងមុនពេលបណ្តេញចេញ

| ការជូនដំណឹង | សហគមន៍ដែលត្រូវបានបណ្តេញចេញ និងផ្លាស់ប្តូរទីលំនៅថ្មី | សហគមន៍ដែលគេបណ្តេញចេញ (គ្មានការផ្លាស់ប្តូរទីលំនៅថ្មី) | សហគមន៍ស្ថិតក្នុងដំណើរការនៃការបណ្តេញចេញ | សរុប |
|---|---|---|---|---|
| តិចជាង ១ ថ្ងៃ | ១ | 0 | 0 | ១[៥៦] |
| តិចជាង ១ សប្តាហ៍ | ៦ | 0 | 0 | ៦[៥៧] |
| តិចជាង ៣0 ថ្ងៃ | ១៣ | ១ | 0 | ១៤[៥៨] |
| តិចជាង ៩0 ថ្ងៃ | ៦ | ២ | 0 | ៨[៥៩] |
| លើសពី ៩0 ថ្ងៃ | ១២ | 0 | ៨* | ១២ (២0)[៦0] |
| គ្មានពេលវេលាច្បាស់លាស់ | ១២ | ១ | 0 | ១៣[៦១] |
| **ចំនួនសរុប** | **៥0** | **៤** | **៨** | **៦២** |

** សហគមន៍ស្ថិតក្នុងដំណើរការនៃការបណ្តេញចេញ ដែលដំណើរការនេះអូសបន្លាយរហូតដល់ជាង ៩0ថ្ងៃ ប៉ុន្តែ គេពុំឃើញមានការប៉ុនប៉ងបណ្តេញប្រជាពលរដ្ឋចេញជាផ្លូវការណាមួយកើតឡើងនៅក្នុងរយៈពេលដែលបានកំណត់នោះឡើយ។*

សមាជិកសហគមន៍ដែលត្រូវគេបណ្តេញចេញចំនួន២៩សហគមន៍ត្រូវគេផ្តល់ដំណឹងពីការបណ្តេញចេញក្នុងរយៈពេលតិចជាង ៩0ថ្ងៃ។ សម្ពាធពីការបណ្តេញចេញដោយបង្ខំនេះ រួមផ្សំនឹងរយៈពេលខ្លីក្នុងការរៀបចំការតាំងទីលំនៅជាថ្មី និងការស្វែងរកជំនួយធ្វើឱ្យសហគមន៍យល់ថាអាជ្ញាធរគ្មានបំណងនឹងមានការចរចារណាមួយសមរម្យជាមួយពួកគេនោះទេ។ សមាជិកសហគមន៍ចំនួន៧ មិនត្រូវបានគេផ្តល់ដំណឹងពីការបណ្តេញចេញដោយបង្ខំមុនថ្ងៃដែលត្រូវគេចុះមកបណ្តេញចេញនោះទេ ហើយជាលទ្ធផល ធ្វើឱ្យពួកគេស្ថិតក្នុងស្ថានភាពលំបាកខ្លាំង។ នៅក្នុងករណីខ្លះ បុរស ស្ត្រី និងកុមារតូចៗត្រូវគេបណ្តេញចេញពីលំនៅឋាន និងចាប់ដាក់រថយន្តដើម្បីដឹកទៅតំបន់ដែលគេផ្តល់សម្រាប់តាំងទីលំនៅថ្មី ដោយពុំមានការជូនដំណឹងជាមុន។

ក្រុម និងសហគមន៍ទាំងឡាយដែលប្រឈមនឹងការបណ្តេញចេញដោយបំពាន ។

(ង) ត្រូវធានាថា សិទ្ធិបុគ្គល ក្រុម ឬសហគមន៍រងផលប៉ះពាល់មានសិទ្ធិបានដឹង និងបានយល់ព្រមទាំងស្រុងជាមុនអំពីការតាំងទីលំនៅថ្មី។ រដ្ឋត្រូវផ្តល់ភាពគាប់ចិត្តគ្រប់បែបយ៉ាងដែលចាំបាច់ សេវា និងឱកាសសេដ្ឋកិច្ចនៅទីតាំងដែលបានស្នើឡើង ។

(ច) ពេលវេលា និងការចំណាយថវិកាចាំបាច់សំរាប់ការធ្វើដំណើរទៅ និងមកកន្លែងធ្វើការ ឬការទទួលបាន សេវាសារវ័ន្តផ្សេងៗ មិនត្រូវឲ្យគ្រួសារដែលមានប្រាក់ចំណូលទាបចំណាយប្រាក់កាសច្រើនហួសហេតុលើសេវាទាំងនេះឡើយ ។

... អ្នកគ្មានដីធ្លី ស្ត្រី និងកុមារមានអ្នកតំណាង និងបានរាប់បញ្ចូលក្នុងកិច្ចដំណើរការនេះ ។

(ឈ) ដំណើរការទាំងមូលនៃការតាំងទីលំនៅថ្មី ត្រូវតែបានអនុវត្តដោយមានការចូលរួមទាំងស្រុងពី និងជាមួយ បុគ្គល ក្រុម ឬសហគមន៍ដែលរងផលប៉ះពាល់ ។ ជាពិសេស រដ្ឋគួរតែគិតគូរអំពីរាល់គំរោងផ្សេងទៀត ដែលបុគ្គល ក្រុម ឬសហគមន៍រងផលប៉ះពាល់បានស្នើឡើង ។

(ញ) ប្រសិនជា បន្ទាប់ពីមានសវនាការសាធារណៈមួយត្រឹមត្រូវ និងពេញលេញហើយៗបានរកឃើញថា នៅតែមានសេចក្តីត្រូវការបន្តធ្វើការតាំងលំនៅថ្មី ដូច្នេះបុគ្គល ក្រុម ឬសហគមន៍ដែលរងផលប៉ះពាល់ត្រូវតែបានជូនដំណឹងជាមុនរយៈពេលយ៉ាងតិច ៩0ថ្ងៃ មុន

---

៥៦ ការបណ្តេញចេញបានកើតឡើងក្នុង ឆ្នាំ២00១។

៥៧ ការបណ្តេញចេញបានកើតឡើងក្នុងឆ្នាំ៖ ១៩៩២ ២000 ២00១ (សហគមន៍ពីរ) ២00៥ ២00៦។

៥៨ ការបណ្តេញចេញបានកើតឡើងក្នុងឆ្នាំ៖ ១៩៩១ ២000 (សហគមន៍ពីរ) ២00១ ២00២ ២00៣ ២00៤ (សហគមន៍ពីរ) ២00៦ (សហគមន៍ ៤) ២00៩ ២0១៦។

៥៩ ការបណ្តេញចេញបានកើតឡើងក្នុងឆ្នាំ៖ ១៩៨២ ២000 (សហគមន៍ពីរ) ២00២ ២0១២ ២0១៦ ២0១៧។

៦0 ការបណ្តេញចេញបានកើតឡើងក្នុង៖ ១៩៩៨ ២000 ២00១ ២00២ ២00៤ ២00៤ ២00៥ ២00៦ (សហគមន៍ ៣) ២0១៣ ២0១៧។

៦១ ការបណ្តេញចេញបានកើតឡើងក្នុងឆ្នាំ៖ ២000 ២00១ (សហគមន៍ចំនួន៤) ២00៣ ២00៦ ២00៧ ២00៩ ២0១២ (សហគមន៍ពីរ) ឆ្នាំ២0១៦។

## ករណីសិក្សា៖ សហគមន៍សាមគ្គីរុងរឿង

*"យើងរស់នៅទីនេះតាំងពី ឆ្នាំ១៩៩០ រហូតដល់ឆ្នាំ២០១៩ ចាប់តាំងពីឆ្នាំ ២០០៥មក ហើយយើងក៏មិនដែលមានបញ្ហានៅកន្លែងដែលយើងរស់នៅដែរ។"*

សហគមន៍សាមគ្គីរុងរឿង មានទីតាំងស្ថិតនៅតាមបណ្តោយ "ប្រឡាយខ្មៅ" ដែលជាប្រឡាយស្តុកទឹកស្អុយក្នុងរាជធានីភ្នំពេញ និងជំនន់ទឹកភ្លៀង។ នៅឆ្នាំ២០០៥សហគមន៍នេះ ត្រូវគេផ្តល់ដំណឹងមិនផ្លូវការមកថាពួកគេនឹងត្រូវគេបណ្តេញចេញពីទីនោះនាពេលខាងមុខ។ ជិត១៥ឆ្នាំហើយ សហគមន៍រស់នៅក្នុងភាពស្រពេចស្រពិលដោយមិនច្បាស់លាស់ពីថ្ងៃអនាគត។

*"នៅក្នុងឆ្នាំ២០០៥ អាជ្ញាធរ និងមន្ត្រីរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់បានចុះមកបាញ់ថ្នាំធ្វើជាលេខសម្គាល់នៅលើជញ្ជាំងផ្ទះរបស់ប្រជាពលរដ្ឋ។ ចាប់ពីពេលនោះមកយើងដឹងថាគេនឹងចុះមករុះរើផ្ទះយើងហើយ។"*

អស់រយៈពេលជាច្រើនឆ្នាំ ក្រោយពីដឹងខ្លួនថានឹងត្រូវគេបណ្តេញចេញពីលំនៅឋានរបស់ខ្លួន សហគមន៍បានសិក្សាពីច្បាប់ និងគោលការណ៍ទាំងឡាយដែលទាក់ទងនឹងការបណ្តេញចេញ តែគួរឱ្យសោកស្តាយពួកគេនៅមិនទាន់មានការប្រជុំ ដែលផ្តល់ដំណឹងផ្លូវការពីផែនការណ៍របស់អាជ្ញាធរសម្រាប់ទីតាំងរបស់ពួកគេ។ ដោយពុំមានសេចក្តីជូនដំណឹងសហគមន៍មិនអាចធ្វើការសាកសួរផ្នែកច្បាប់ ឬធ្វើការសម្រេចចិត្តសម្រាប់អនាគតរបស់ពួកគេបានឡើយ។

*"នៅក្នុងឆ្នាំ២០១៨ អាជ្ញាធរខណ្ឌចុះមកអញ្ជើញប្រជាពលរដ្ឋប្រាំនាក់ទៅជួប។ ជំនួបរវាងប្រជាពលរដ្ឋទាំង៥នាក់នោះ ជាមួយនឹងអាជ្ញាធរចំណាយពេលអស់ប្រមាណជា១០នាទី។ មន្ត្រីទាំងនោះនិយាយថាប្រជាពលរដ្ឋ ដែលត្រូវគេបណ្តេញចេញ គឺគ្រាន់តែផ្លាស់ចេញពីភូមិមួយទៅភូមិមួយទៀតប៉ុណ្ណោះ។ រហូតមកដល់ពេលនេះគេពុំឃើញមានលិខិត ឬព័ត៌មានផ្លូវការណាមួយស្តីពីការផ្លាស់ប្តូរទីតាំងថ្មីនោះទេ។"*

ប្រធានសហគមន៍ម្នាក់បានសួរនាំអាជ្ញាធរពីសារាចរលេខ០៣ ប៉ុន្តែអាជ្ញាធរប្រាប់គាត់ថា ពួកគេមិនដឹងថាគួរប្រើប្រាស់សារាចរលេខ០៣ នេះយ៉ាងដូចម្តេចនោះទេ។

*"ពួកយើងមិនដែលទទួលបានឯកសារ ឬលិខិតណាមួយស្តីពីការបណ្តេញសហគមន៍យើងនោះទេ ពួកយើងព្រួយបារម្ភពីការមិនផ្តល់ដំណឹងនេះ។ យើងមិនចង់ផ្លាស់ទីលំនៅទៅតំបន់ណាផ្សេង ដោយគ្មានឯកសារផ្លូវច្បាប់ដែលចេញពីក្រសួងនោះទេ។"*

## ៤. ៣. អំឡុងពេលបណ្តេញចេញ

### ៤.៣.១. ការពិគ្រោះយោបល់ និងការចូលរួមពីភាគីពាក់ព័ន្ធ

ការពិគ្រោះយោបល់គឺជាសិទ្ធិមូលដ្ឋានដែលប្រជាពលរដ្ឋគួរទទួលបាននៅក្នុងដំណើរការនៃការបណ្តេញចេញ។ ប៉ុន្តែយ៉ាងហោចណាស់មាន ១៧ករណី ដែលប្រជាពលរដ្ឋមិនទទួលបានការពិគ្រោះយោបល់ ឬ(មានសហគមន៍ចំនួន២) ពុំទាន់ទទួលបានការពិគ្រោះយោបល់រវាងអាជ្ញាធរ និងសមាជិកសហគមន៍។ កង្វះកិច្ចសន្ទនាអាចមានផលជាអវិជ្ជមានខ្លាំងដល់សហគមន៍ដែលអាចងាយរងគ្រោះដោយសារស្ថានភាពផ្ទះសម្បែងមិនសមរម្យ និងសេដ្ឋកិច្ចទន់ខ្សោយ។ ចម្លើយទូទៅជាងគេ ក្នុងចំណោមចម្លើយភាគច្រើនទាក់ទងនឹងរបៀបធ្វើឱ្យដំណើរការនៃការបណ្តេញចេញកាន់តែប្រសើរឡើងនោះគឺ "ការពិគ្រោះយោបល់កាន់តែទូលំទូលាយ" ។

ការពិគ្រោះយោបល់មិនគ្រាន់តែជាការទទួលខុសត្រូវរបស់អាជ្ញាធរប៉ុណ្ណោះទេ វាក៏ជាសេវាគាំទ្រជាពិសេសនៅក្នុងវិជ្ជាជីវៈច្បាប់។ នៅពេលសាកសួរទាក់ទងនឹងក្រុមដែលបានផ្តល់ប្រឹក្សាយោបល់ជាមួយហគមន៍ ក្នុងអំឡុងពេលដែលពួកគេត្រូវគេបណ្តេញចេញ សមាជិកដែលមកពីសហគមន៍ចំនួន១៨ បានឆ្លើយថាពួកគេបានទទួលការពិគ្រោះយោបល់។ សហគមន៍ទាំង ១៨ នេះបានទទួលការពិគ្រោះយោបល់ពីអង្គការមិនមែនរដ្ឋាភិបាល ហើយជាងពាក់កណ្តាលនៃអង្គការទាំងនេះគឺជាអង្គការផ្តល់ជំនួយខាងផ្លូវច្បាប់ ឬការតស៊ូមតិលើបញ្ហាសិទ្ធិដីធ្លី។

មានតែសមាជិកសហគមន៍ចំនួន២ ប៉ុណ្ណោះ ដែលហ៊ានតស៊ូក្តីនៅក្នុងតុលាការទាក់ទងនឹងរឿងបណ្តេញពួកគេចេញពីសហគមន៍ដែលគេរស់នៅ។ មូលហេតុផ្សេងៗ ដែលជំរុញឱ្យសហគមន៍សម្រេចមិនជ្រើសរើសការតស៊ូតាមផ្លូវច្បាប់ ដើម្បីប្រឆាំងនឹងការបណ្តេញចេញបើទោះជាបញ្ហានេះគឺជានីតិវិធីតាមផ្លូវច្បាប់ក្តី គឺដោយសារកង្វះការយល់ដឹងខាងផ្លូវច្បាប់ ឬការពុំមានជំនឿលើប្រព័ន្ធតុលាការ។

### ៤.៣.២. ពេលវេលានៃការបណ្តេញចេញ

ការបណ្តេញចេញនៃសមាជិកសហគមន៍ភាគច្រើន (៤៧សហគមន៍) កើតឡើងក្នុងរយៈពេលតែមួយថ្ងៃ គឺចន្លោះពីម៉ោង ៧:០០ ព្រឹក រហូតដល់ ម៉ោង ៥:០០ ល្ងាច នៅពេលមានអាកាសធាតុល្អ និងមិនចំពេលបោះឆ្នោត ឬការប្រឡងថ្នាក់ជាតិណាមួយ។ ប៉ុន្តែគេសង្កេតឃើញថា ការបណ្តេញចេញមួយចំនួនកើតឡើងនៅចំពេលមានអាកាសធាតុក្តៅខ្លាំង ឬនៅពេលយប់។ គួរកត់សម្គាល់ផងដែរថា ក្នុងករណីភាគច្រើនការបណ្តេញចេញដែលកើតឡើងចំពេលភ្លៀង ឬថ្ងៃក្តៅ មិនអាចចាត់ទុកជាការរំលោភបំពានដោយគ្រាន់តែផ្អែកលើកត្តាទាំងនេះបានឡើយ។

ក្នុងករណីខ្លះ សមាជិកសហគមន៍បានលើកឡើងថា ទឹកភ្លៀង និងកំដៅថ្ងៃក៏ជាផលប៉ះពាល់អវិជ្ជមាននៃការបណ្តេញចេញដែរ ព្រោះជាទូទៅពួកគេត្រូវប្រឈមនឹងកំដៅថ្ងៃខ្លាំង ឬសុខភាព និងទ្រព្យសម្បត្តិរបស់ពួកគេត្រូវបំផ្លាញដោយសារទឹកភ្លៀង។ នៅក្នុងករណីខ្លះទៀត កត្តាទាំងពីរនេះមិនមែនជាបញ្ហាប្រឈមខ្លាំងនោះទេ។

មានករណីចំនួន៣ ដែលការបណ្តេញចេញកើតឡើងនៅពេលយប់។ ក្នុងចំណោម ៣ករណីនេះ មាន ២ករណី ដែលកើតឡើងដោយសារអគ្គិភ័យ។[៦២] សមាជិកសហគមន៍មួយ ត្រូវបានគេបណ្តេញចេញដោយគ្មានការជូនដំណឹងដោយមន្ត្រីកងកម្លាំងមានសមត្ថកិច្ចចំនួនប្រហែល ៣,០០០នាក់ នៅវេលាម៉ោង ៣:០០ទៀបភ្លឺ។ ប្រជាពលរដ្ឋសហគមន៍ដឹងដោយសារសំឡេងនៃរថយន្តពេលដាក់មន្ត្រីប៉ូលីសចុះ។ អស់រយៈពេលមួយខែដែលប្រជាពលរដ្ឋត្រូវរស់នៅក្នុងតង់កៅស៊ូដែលពួកគេសង់ដោយខ្លួនឯង មុនពេលត្រូវគេបញ្ជូនទៅរស់នៅភ្នំបាតដែលមានចម្ងាយប្រមាណជា៤៤គីឡូម៉ែតនៃភាគខាងជើងនៃរាជធានីភ្នំពេញ។ បច្ចុប្បន្ន ពួកគេកំពុងបន្តរស់នៅទីនោះដោយគ្មានប័ណ្ណកម្មសិទ្ធិដីធ្លីស្របច្បាប់ឡើយ។

[៦២] គួរកត់សម្គាល់ថានេះមិនអាចចាត់ចូលក្នុងន័យបណ្តេញចេញនោះទេ ប៉ុន្តែសមាជិកសហគមន៍មិនត្រូវបានអនុញ្ញាតដោយអាជ្ញាធរឱ្យត្រឡប់មករស់នៅផ្ទះសម្បែងរបស់ពួកគេឡើយ ក្រោយពេលពីការឆេះ។

*"ខ្ញុំពិតជាតក់ស្លុត ពេលត្រូវគេដាស់ទាំងកណ្តាលយប់។ គ្រួសារខ្លះព្យាយាមប្រមូលទ្រព្យសម្បត្តិសំខាន់ៗ ប៉ុន្តែ គេមិនអនុញ្ញាត។ ប្រសិនបើយើងព្យាយាមប្រមូលទ្រព្យសម្បត្តិទាំងនោះដែរ នោះប៉ូលីសនឹងវាយដំភ្លាម"។*

នៅក្នុងករណីដែលសមាជិកសហគមន៍ត្រូវគេបណ្តេញចេញនៅក្នុងរដូវភ្លៀង ជាទូទៅការបណ្តេញចេញមិនធ្វើឡើងឡើយនៅពេលភ្លៀងខ្លាំង តែអាចធ្វើឡើងចំពេលមានភ្លៀង។ នៅក្នុង២១ករណី បានរាយការណ៍ថាមេឃភ្លៀងបានបង្កការលំបាកដល់សហគមន៍ក្នុងការតាំងលំនៅឋានថ្មីនៅទីតាំងថ្មី។ សមាជិកសហគមន៍ទាំងអស់នេះរាយការណ៍មកថា ផ្លូវលំបាកដោយសារមានភក់ច្រើន ធ្វើឱ្យកុមារពិបាកធ្វើដំណើរទៅសាលារៀន។ បញ្ហានេះធ្វើឱ្យកុមារដែលទើបផ្លាស់ទីលំនៅថ្មីខកខានការរៀនសូត្រ និងជួបការលំបាកផ្សេងៗ។ សហគមន៍ដែលបានផ្លាស់ទីលំនៅថ្មីចំនួន២សហគមន៍ បានឱ្យដឹងថាទីតាំងសម្រាប់តាំងលំនៅថ្មីមិនត្រូវបានគេរៀបចំបានល្អសម្រាប់គ្រប់គ្រងបញ្ហាទឹកភ្លៀងនោះទេ ដោយបង្កឱ្យសមាជិកសហគមន៍មួយចំនួនជួបនឹងបញ្ហាទឹកជំនន់លំបាកក្នុងការធ្វើដំណើរចេញចូល និងរស់នៅក្នុងតង់កៅស៊ូខណៈមានភ្លៀងខ្លាំង។ បញ្ហាសត្វល្អិត និងសត្វពស់បានបង្កជាកង្វល់មួយផ្សេងទៀតដល់សហគមន៍ ហើយសហគមន៍ខ្លះយល់ថា បើពួកគេអាចតាំងទីលំនៅថ្មីនៅចំពេលមានអាកាសធាតុល្អនោះពួកគេនឹងអាចរៀបចំលំនៅឋានថ្មីដែលអាចការពារទឹកភ្លៀងបានយ៉ាងល្អ។ សមាជិកសហគមន៍ផ្សេងទៀតលើកឡើងថាបញ្ហាធំមិនមែនស្ថិតនៅលើពេលវេលា ឬរដូវកាលនៃការបណ្តេញចេញនោះទេ គឺវាស្ថិតនៅលើការរៀបចំតំបន់ដែលសហគមន៍ត្រូវផ្លាស់ទៅទីតាំងថ្មី។

### ៤.៣.៣. អាជ្ញាធរទទួលខុសត្រូវចំពោះការបណ្តេញចេញ និងទំនាស់

ការបណ្តេញចេញគឺជាដំណើរការ ដែលជាទូទៅពាក់ព័ន្ធនឹងអាជ្ញាធរហើយកើតឡើងនៅពេលមន្ត្រីដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋអនុវត្តតាមវិធាននៃច្បាប់បណ្តេញប្រជាពលរដ្ឋចេញពីតំបន់ណាមួយតាមរយៈនីតិវិធីច្បាប់ និងស្របតាមច្បាប់នានា។ រាល់ករណីទាំងអស់ អាជ្ញាធរទូទៅ មន្ត្រីនគរបាល គឺជាអ្នកអនុវត្តការបណ្តេញប្រជាពលរដ្ឋ។ នៅក្នុងការបណ្តេញចេញ ៦ករណី គេសង្កេតឃើញមានមន្ត្រីកងរាជអាវុធហត្ថចូលរួមក្នុងដំណើរការនៃការបណ្តេញចេញទាំងនេះ[៦៣]។ ក្នុងករណីនេះ មាន៤ករណីដែលបានប្រើប្រាស់ហិង្សាដោយមន្ត្រីកងរាជអាវុធហត្ថទៅលើប្រជាសហគមន៍[៦៤]។ រាល់ការចូលរួមពីកងរាជអាវុធហត្ថក្នុងដំណើរការនៃការបណ្តេញចេញតែងត្រូវបានគេចោទសួរ ជាពិសេសនៅពេលមានយកកាំភ្លើងទៅទីតាំងបណ្តេញចេញដែលអាចចាត់ទុកថាជាការគំរាមកំហែង និងខុសពីគោលការណ៍សិទ្ធិមនុស្ស។ [៦៥]

### ៤.៣.៤. ការបណ្តេញចេញដោយហិង្សា

នៅក្នុង៩ករណីនៃការបណ្តេញចេញ គេសង្កេតឃើញថាមន្ត្រីនគរបាល ឬកងរាជអាវុធហត្ថបានប្រើអំពើហិង្សាទៅលើសមាជិកសហគមន៍នៅក្នុងពេលបណ្តេញពួកគេចេញពីលំនៅឋាន។ នៅក្នុងករណីចំនួន៧ក្នុងចំណោមករណីទាំង៩នេះ គេសង្កេតឃើញមានការប្រើអំពើហិង្សាទៅលើស្ត្រី និងកុមារ។ នៅក្នុងករណីខ្លះ មន្ត្រីនគរបាលដែលត្រូវបានគេចំណាំមុខបានថាជាមន្ត្រីនគរបាលបានស្លៀកពាក់ជាជនស៊ីវិលនៅពេលចុះមករុះរើផ្ទះរបស់ប្រជាពលរដ្ឋ។

[៦៣] ស្ថានភាពបានកើតឡើងក្នុងឆ្នាំ ២០០១ ២០០៤ (ពីរករណី) ២០០៦ (ពីរករណី) និងឆ្នាំ២០១២។

[៦៤] ករណីអំពើហិង្សាបានកើតឡើងក្នុងឆ្នាំ ២០០៤ (ពីរករណី) ឆ្នាំ២០០៦ និងឆ្នាំ២០១២។

[៦៥] ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា ឆ្នាំ២០០៩ 'សេចក្តីអត្ថាធិប្បាយ និងគោលការណ៍ណែនាំសិទ្ធិមនុស្សស្តីពីការបណ្តេញចេញ និងការតាំងទីលំនៅថ្មី'

ការប្រើប្រាស់អំពើហិង្សាក្នុងការបណ្តេញចេញ មិនអាស្រ័យនឹងពេលវេលានោះទេ ហើយអំពើហិង្សានេះត្រូវបានអនុវត្តដោយអាជ្ញាធរចាប់តាំងពីឆ្នាំ១៩៩២រហូតដល់ឆ្នាំ២០១២។ សហគមន៍ដែលធ្លាប់ត្រូវបានអាជ្ញាធរប្រើអំពើហិង្សាទៅលើភាគច្រើនបដិសេដមិនទទួលយកលក្ខខណ្ឌរបស់អាជ្ញាធរសម្រាប់ការផ្លាស់ទៅទីតាំងថ្មី ឬការបណ្តេញចេញ និងប្រឈមមុខជាមួយមន្ត្រីកងរាជអាវុធហត្ថជាជាងមន្ត្រីនគរបាល។ អំពើហិង្សា ឬការគំរាមកំហែងដោយប្រើអំពើហិង្សាកើតមានច្រើននៅពេលមានវត្តមានរបស់កងរាជអាវុធហត្ថ នៅក្នុងដំណើរការនៃការបណ្តេញចេញ។ នៅក្នុងចំណោមករណីបណ្តេញចេញចំនួន ៦ករណី ដែលមានវត្តមានរបស់កងរាជអាវុធហត្ថ គេសង្កេតឃើញថាមាន២ករណីដែលអាជ្ញាធរប្រើអំពើហិង្សាទៅលើប្រជាសហគមន៍ និងមាន៥ករណីផ្សេងទៀតដែលអាជ្ញាធរគំរាមប្រើហិង្សា និងគំរាមបំផ្លាញផ្ទះសម្បែង និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋប្រសិនបើពួកគេមិនព្រមរុះរើចេញ។

អំពើហិង្សាក៏អាចកើតមាននៅក្នុងដំណើរការនៃការបណ្តេញចេញដែលគ្មានការពិគ្រោះយោបល់រវាងអាជ្ញាធរ និងសហគមន៍ផងដែរ។ នៅក្នុងករណីចំនួន៦ ក្នុងចំណោមករណីសរុបចំនួន ៩សហគមន៍ត្រូវបានគេបដិសេធសិទ្ធិទទួលបានការពិគ្រោះយោបល់ហើយសហគមន៍ចំនួន៧ផ្សេងទៀត បានទទួលរងការគំរាមកំហែងដោយប្រើប្រាស់ហិង្សានៅមុនពេល និងក្នុងដំណើរការនៃការបណ្តេញចេញ។ ការរកឃើញនេះនឹងជម្រាបដល់រាជរដ្ឋាភិបាលកម្ពុជាឱ្យបានដឹងថាអំពើហិង្សាអាចកាត់បន្ថយបាន ប្រសិនបើមាននីតិវិធីពិគ្រោះយោបល់កាន់តែទូលំទូលាយ និងមានការចូលរួមយ៉ាងសកម្មពីភាគីពាក់ព័ន្ធនានាដើម្បីបង្កើតឱ្យមានវប្បធម៌សន្ទនា។

**៤.៣.៥. ការគំរាមកំហែង ឬការបំភិតបំភ័យ**

ការគំរាមកំហែង និងការបំភិតបំភ័យពីអាជ្ញាធរទៅលើអ្នកផ្តល់បទសម្ភាសត្រូវគេសង្កេតឃើញថាកើតមាននៅក្នុងការបណ្តេញចេញចំនួន ១៧សហគមន៍ ឬប្រហែល ១ភាគ៣ នៃការបណ្តេញចេញទាំងអស់។ មានការជាប់ទាក់ទិនខ្លាំងរវាងការមិនផ្តល់ដំណឹងពីការបណ្តេញចេញ និងករណីដែលសហគមន៍ត្រូវបានអាជ្ញាធរគំរាមកំហែង ដែលនេះអាចបង្ហាញថា ការគំរាមកំហែង និងការបំភិតបំភ័យត្រូវបានអាជ្ញាធរប្រើប្រាស់ជំនួសឱ្យការជូនដំណឹងជាផ្លូវការដើម្បីបណ្តេញប្រជាពលរដ្ឋ។ វិធីសាស្ត្រនេះ អាចត្រូវអាជ្ញាធរប្រើ ដើម្បីបញ្ចៀសសហគមន៍មិនឱ្យរៀបចំការប្រឆាំងនឹងការបណ្តេញចេញ ហើយវាក៏ស្របនឹងការរកឃើញដែលថាអាជ្ញាធរប្រហែលជាព្យាយាមបង្ខំឱ្យប្រជាពលរដ្ឋតាំងទីលំនៅថ្មីដោយខ្លួនឯង។

មានសហគមន៍ចំនួន៣ដែលធ្លាប់ទទួលរងការគំរាមប្រើហិង្សាដោយផ្ទាល់។ នៅក្នុងករណីមួយនោះ អាជ្ញាធរបានប្រាប់ពួកគេថា "យើងនឹងវាយអ្នកដោយដំបង ប្រសិនបើអ្នកនៅតែរឹងទទឹងមិនចេញ។" នៅក្នុងករណីផ្សេងមួយទៀត សហគមន៍ត្រូវបានគេគំរាមប្រើហិង្សាដោយប្រយោលដោយអាជ្ញាធរប្រាប់អ្នកផ្តល់បទសម្ភាសដែលមកពីសហគមន៍មួយថាគេនឹងផ្តាច់ទឹក-ភ្លើង ប្រសិនបើពួកគេមិនព្រមចាកចេញដោយខ្លួនឯង។ មួយរយៈក្រោយមកនៅពេលប្រជាពលរដ្ឋមិនព្រមចាកចេញទឹក-ភ្លើងក៏ត្រូវបានផ្តាច់ ហើយសហគមន៍បានរាយការណ៍ថាឃើញមានមន្ត្រីនគរបាលចុះមកសហគមន៍នៅពេលថ្ងៃ និងរៀបចំកន្លែងដេកនៅលើផ្លូវក្នុងសហគមន៍នៅយប់ថ្ងៃដដែលនោះ។

នៅក្នុងករណីខ្លះ សហគមន៍មិនត្រូវបានផ្តល់ព័ត៌មានជាផ្លូវការពីការបណ្តេញចេញនោះទេ ប៉ុន្តែត្រូវបានគេព្រមានជាមុនថា នៅពេលដែលអាជ្ញាធរចុះមកបណ្តេញពួកគេ ពួកគេនឹងមិនទទួលបានសំណងណាមួយចំពោះទ្រព្យសម្បត្តិដែលនឹងរងការខូចខាតដោយសារចំណាត់ការរបស់អាជ្ញាធរនោះឡើយ។ ចំណាត់ការនោះ អនុលោមទៅតាមច្បាប់ភូមិបាលឆ្នាំ២០០១ ដែលចែងថាគ្មានសំណងណាមួយនឹងផ្តល់ដល់បុគ្គលទាំងឡាយណាដែលកាន់កាប់ទ្រព្យសម្បត្តិសាធារណៈខុសច្បាប់[៦៦] ប៉ុន្តែការបំផ្លាញទ្រព្យសម្បត្តិគួរតែត្រូវបានជៀសវាងប្រសិនបើអាចធ្វើបាន។

នៅចន្លោះឆ្នាំ២០១៨ និងឆ្នាំ២០១៩ មានការកើនឡើងនូវចំនួនសហគមន៍ដែលបានរាយការណ៍ប្រាប់ថាពួកគេបានចាកចេញពីលំនៅឋានដោយខ្លួនឯង ដោយសារភ័យខ្លាចការបណ្តេញចេញ ដោយហិង្សា។ ការកើនឡើងនេះ អាចបង្ហាញថា អាជ្ញាធរប្រើយុទ្ធសាស្ត្រដែលមានគោលបំណងកាត់បន្ថយហិង្សា និងបាតុកម្មដែលនេះវាផ្ទុយ

[៦៦] ច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា ៤៣

ពីគោលការណ៍សិទ្ធិមនុស្សស្តីពីការបណ្តេញចេញដែលលើកឡើងថាប្រជាពលរដ្ឋមិនគួរត្រូវបានបង្ខំឱ្យបំផ្លាញផ្ទះសម្បែងរបស់ខ្លួនឡើយ។[៦៧] យ៉ាងហោចណាស់ក៏មាន៣ករណីដែរ ដែលសហគមន៍ត្រូវគេដាក់សម្ពាធឱ្យចាកចេញ និងរុះរើផ្ទះរបស់ខ្លួនដោយខ្លួនឯង ដោយសារការភ័យខ្លាចចំពោះការខូចខាតទ្រព្យសម្បត្តិ ប្រសិនបើមានអន្តរាគមន៍របស់អាជ្ញាធរចុះមករុះរើដោយផ្ទាល់។

### ៤.៣.៦. ការមិនទទួលបានការយកចិត្តទុកដាក់

នៅក្នុងករណីខ្លះ សេចក្តីជូនដំណឹងពីការបណ្តេញចេញត្រូវបានផ្តល់ដល់សហគមន៍ តែការបណ្តេញចេញនោះបានកើតឡើងក្រោយកាលបរិច្ឆេទកំណត់ជាច្រើនខែឆ្នាំ។ នៅពេលខ្លះ ការអូសបន្លាយពេលវេលាយូរបែបនេះគឺដោយសារអាជ្ញាធរមិនចង់ធ្វើឱ្យប៉ះពាល់ដល់សហគមន៍ខ្លាំង។ ជាង៥០ភាគរយ សហគមន៍ដែលបិតក្នុងដំណើរការនៃការបណ្តេញចេញ បានដឹងពីការបណ្តេញចេញរបស់ពួកគេយ៉ាងតិច ១២ខែ មុននឹងត្រូវបានបណ្តេញចេញ ក្នុងអំឡុងពេលនោះ មិនត្រូវធ្វើឱ្យមានបញ្ហាដល់សហគមន៍នោះទេ គឺវាស្របទៅនឹងគោលការណ៍ណែនាំសិទ្ធិមនុស្សផងដែរ[៦៨]។ ដោយឡែកសហគមន៍បានប្រាប់ថា នៅក្នុងអំឡុងពេលនោះ ពួកគេមិនត្រូវបានគេយកចិត្តទុកដាក់នោះឡើយ ដូចជាអាជ្ញាធរបដិសេធមិនព្រមជួបដើម្បីពិភាក្សាបញ្ហាផ្សេងៗ ទោះជាបញ្ហានោះមិនពាក់ព័ន្ធនឹងការបណ្តេញចេញក្តី ការមិនឈឺឆ្អាលទៅលើផលប៉ះពាល់នៃការអភិវឌ្ឍនៅក្បែរសហគមន៍ ដូចជាការចាក់បំពេញខ្សាច់ដែលប៉ះពាល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់សហគមន៍ឬសកម្មភាពសាងសង់ផ្សេងៗនៅក្បែរសហគមន៍ដែលធ្វើឱ្យទ្រង់ទ្រាយដីខូច និងផ្ទះសម្បែងបាក់បែកនិងការបដិសេធសំណើសុំសេវាសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ត្រូវប្រើរយៈពេលយូរ។ នៅក្នុងករណីខ្លះសហគមន៍មិនអាចសុំជួបអាជ្ញាធរដើម្បីសួរនាំពីស្ថានភាពផ្លូវច្បាប់នៃដីសហគមន៍ ឬពីរបៀបដែលពួកគេអាចទទួលបានសៀវភៅគ្រួសារសម្រាប់ដាក់ពាក្យស្នើសុំប្លង់កម្មសិទ្ធិ និងសម្រាប់តភ្ជាប់ប្រព័ន្ធទឹក-ភ្លើងបានឡើយ។

នៅក្នុងករណីមួយនោះ សមាជិកសហគមន៍ម្នាក់បានស្នើសុំអាជ្ញាធរដើម្បីសាងសង់បង្គន់អនាម័យ ដោយទទួលបានជំនួយពីអង្គការមិនមែនរដ្ឋាភិបាល។ អាជ្ញាធរបដិសេធសំណើរបស់គាត់ដោយសំអាងលើហេតុផលថាសហគមន៍នេះនឹងត្រូវគេបណ្តេញចេញនាពេលខាងមុខដ៏ខ្លី បើទោះបីជាមិនមានការបញ្ជាក់ពីពេលវេលាជាក់លាក់ក្តី។ សមាជិកសហគមន៍រូបនេះមានការអន់ចិត្តដោយសារគាត់ និងសហគមន៍រស់នៅដូចជាប់គុក និងជីវភាពរស់នៅក៏មិនប្រសើរឡើង ហើយថែមទាំងមិនដឹងថា តើពេលណាត្រូវបានគេបណ្តេញចេញ និងត្រូវគេបណ្តេញដោយរបៀបណា។ ការមិនយកចិត្តទុកដាក់ អាចផ្តល់ផលប៉ះពាល់យ៉ាងខ្លាំង និងអាចជំរុញឱ្យសហគមន៍សម្រេចចាកចេញដោយខ្លួនឯង ឬជ្រើសរើសយកសំណងជាថ្នូរនឹងការផ្លាស់ទីលំនៅថ្មី ដែលពួកគេធ្លាប់បដិសេធ។

### ៤.៣.៧. សំណង

ក្នុងចំណោមសហគមន៍ដែលត្រូវបានបណ្តេញចេញ និងផ្លាស់ទីលំនៅថ្មីទាំងអស់ មានសមាជិកសហគមន៍ដែលមកពីសហគមន៍ចំនួន៤៧ ទទួលបានដីជាសំណង និងសហគមន៍ចំនួន២ផ្សេងទៀតទទួលយកសំណងជាប្រាក់ជំនួសការផ្តល់ទីតាំងថ្មី។ ដីដែលផ្តល់ជូនសហគមន៍នីមួយៗ មានទំហំខុសគ្នាខ្លាំង។ សហគមន៍មួយចំនួនរអ៊ូរទាំថាសហគមន៍ផ្សេងទទួល បានសំណងច្រើនជាងពួកគេ ហើយដីដែលផ្តល់ឱ្យពួកគេគឺមិនសាកសមនឹងតម្លៃផ្ទះរបស់ពួកគេបច្ចុប្បន្ន ឬមិនស្ថិតនៅតំបន់មានសក្តានុពលផ្នែកសេដ្ឋកិច្ចសម្រាប់ពួកគេ។ លើសពីនេះទៅទៀត ពុំមានការកើនឡើងក្នុងការសង ឬផ្តល់ជាសំណងនោះឡើយ បើទោះបីជាសំណងសងទៅតាមតម្លៃផ្ទះ ឬដីក៏ដោយ ពីព្រោះពួកគេរស់នៅលើដីសាធារណៈរបស់រដ្ឋឡើយ។

---

[៦៧] ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា ឆ្នាំ២០០៩ 'សេចក្តីអត្ថាធិប្បាយ និងគោលការណ៍ណែនាំសិទ្ធិមនុស្សស្តីពីការបណ្តេញចេញ និងការតាំងទីលំនៅថ្មី'

[៦៨] ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា ឆ្នាំ២០០៩ 'សេចក្តីអត្ថាធិប្បាយ និងគោលការណ៍ណែនាំសិទ្ធិមនុស្សស្តីពីការបណ្តេញចេញ និងការតាំងទីលំនៅថ្មី'

**ក្រាហ្វិចទី ២៖** ក្បាលដីដែលផ្តល់ជាសំណង (ទំហំគិតជា ម៉ែត្រការ៉េ)




*ចំនួនក្នុងក្រាហ្វិចខាងលើបង្ហាញពីទំហំដែលជាសំណងដល់សហគមន៍ដែលបានបណ្តេញចេញ ទំហំនេះគិតជាម៉ែត្រការេ ហើយសណ្ឋាននេះវាមិនបង្ហាញពីសណ្ឋានទំហំដីជាក់ស្តែងទេ*

ទំហំក្បាលដីមិនមែនជាសូចនាករមានប្រយោជន៍សម្រាប់បង្ហាញឱ្យដឹងពីភាពសាកសមនៃសំណងនោះទេ។ ភាពខុសគ្នានៃទំហំដីទើបជាចំនុចសំខាន់សម្រាប់ឱ្យការអនុវត្តអនុលោមតាមច្បាប់មួយចំនួន ឬប្លង់ដែលគេអនុវត្តជាទូទៅដើម្បីធានានូវភាពដូចគ្នានិងទំនុកចិត្តសម្រាប់ការផ្លាស់ប្តូរទីតាំងលំនៅថ្មី។ផ្ទុយទៅវិញគេឃើញមានភស្តុតាងតិចតួចណាស់ដែលបញ្ជាក់ថាទំហំក្បាលដីមានតម្លៃសាកសមទៅនឹងតម្លៃដីរបស់សហគមន៍ពីមុន ឬការអនុវត្តដោយអាជ្ញាធរមានភាពដូចគ្នារវាងសហគមន៍មួយទៅសហគមន៍មួយ។ យោងទៅតាមក្រាហ្វិចខាងលើក្បាលដីនីមួយៗមានទំហំខុសគ្នាខ្លាំង ហើយទំនងជាកំណត់ទៅតាមការយល់ឃើញរបស់អាជ្ញាធរជាជាងតាមរយៈការវាយតម្លៃប្រកបដោយតម្លាភាពដោយអាជ្ញាកណ្តាល និងអ្នកវាយតម្លៃឯករាជ្យ។ សហគមន៍ដែលទទួលបានដីធំបានប្រាប់ថា ពួកគេ "សប្បាយចិត្តនឹងការផ្លាស់ទីតាំងលំនៅថ្មី" ព្រោះទទួលបានដីធំ។ សម្រាប់សហគមន៍ផ្សេងទៀត ពួកគេទទួលស្គាល់ថាដីដែលគេទទួលបានជាសំណង មិនសាកសមនឹងតម្លៃដីដែលពួកគេរស់នៅបច្ចុប្បន្នឡើយ ប៉ុន្តែទោះជាយ៉ាងនេះក្តីពួកគេនៅតែសប្បាយចិត្ត ព្រោះដីថ្មីអាចផ្តល់នូវសក្តានុពលផ្នែកសេដ្ឋកិច្ចនៅថ្ងៃខាងមុខ។

ទម្រង់ផ្សេងទៀតនៃសំណងក្រៅពីសំណងជាដី រួមមានការផ្តល់ប្រាក់មួយចំនួន ( សហគមន៍ចំនួន១១) ការផ្តល់តង់ (សហគមន៍ចំនួន២) ការផ្តល់សម្ភារៈសាងសង់ផ្ទះ(សហគមន៍ចំនួន២) និងការផ្តល់គ្រឿងឧបភោគបរិភោគ (សហគមន៍ចំនួន៦)។ ពុំមានការបកស្រាយណាមួយឱ្យបានច្បាស់លាស់អំពីមូលហេតុដែលសហគមន៍ខ្លះទទួលបានសំណងបន្ថែម ហើយសហគមន៍ខ្លះមិនទទួលបាននោះទេ។



ផ្លូវដីក្នុងសហគមន៍ក្នុងរាជធានីភ្នំពេញ (ថតដោយអង្គការសមាគមធាងត្នោត ឆ្នាំ២០១៩)

## ៤.៤. ដំណើរការនៃការតាំងទីលំនៅថ្មី

### ៤.៤.១. មូលហេតុនៃការតាំងទីលំនៅថ្មី

សហគមន៍ភាគច្រើនមិនត្រូវបានគេផ្តល់សំណងជាទឹកប្រាក់នោះទេ ហើយថែមទាំងត្រូវបានគេបង្ខំឱ្យទទួលយកទីតាំងលំនៅថ្មី ឬមិនទទួលបានសំណងអ្វីសោះ។ ដូច្នេះហើយ បញ្ហានេះនៅតែមិនដឹងពីមូលហេតុច្បាស់លាស់នោះទេ។

### ៤.៤.២. ការរៀបចំតំបន់តាំងទីលំនៅថ្មី

បើយោងតាមបទដ្ឋានសិទ្ធិមនុស្ស ការរៀបចំតំបន់តាំងទីលំនៅថ្មីមិនមានលក្ខណៈល្អគ្រាប់គ្រាន់នៅឡើយទេ។ ជាទូទៅ តំបន់តាំងទីលំនៅថ្មីគឺមានតែដី មិនមានការផ្តល់ប្រព័ន្ធទឹក និងភ្លើង ផ្ទះសម្បែង បន្ទប់ទឹក និងប្រព័ន្ធលូនោះទេ ហើយសម្រាប់អ្នកផ្តល់បទសម្ភាសភាគច្រើន ទីតាំងតំបន់គឺជាបញ្ហាដ៏ធំសម្រាប់ពួកគេ។

### ៤.៤.៣. ការរៀបចំ ឬភាពអាចរស់នៅបាននៅពេលទៅដល់ទីតាំងលំនៅថ្មី

**តារាងទី ៧៖** ការផ្ដល់លក្ខណៈសំខាន់ៗដល់តំបន់តាំងទីលំនៅថ្មី

| ការផ្ដល់ជូន (អាចប្រើប្រាស់បាននៅពេលមករស់នៅ) | ចំនួនសហគមន៍ | ភាគរយ |
|---|---|---|
| លំនៅឋាន | ៨ | ១៦% |
| កម្មសិទ្ធិ | ២៨ | ៥៦% |
| ទឹកស្អាតបរិភោគ | ៥ | ១០% |
| ប្រព័ន្ធលូទឹកស្អុយ | ៣ | ៦% |
| ប្រភពថាមពលសម្រាប់ចម្អិនអាហារ | ២ | ៤% |
| ប្រព័ន្ធកំដៅ និងបំភ្លឺ | ០ | ០% |
| កន្លែងសម្រាប់អនាម័យ (មិនរាប់បន្ទប់ទឹក) | ១ | ២% |
| កន្លែងសម្រាប់ស្ដុកអាហារ | ០ | ០% |
| ទីតាំងចោលសំរាម | ១ | ២% |
| សេវាសុខភាព (ក្នុងចម្ងាយសមរម្យ) | ៩ | ១៨% |
| សាលារៀន (ក្នុងចម្ងាយសមរម្យ) | ១៣ | ២៦% |
| ភ្លើងបំភ្លឺដងផ្លូវ | ៤ | ៨% |
| ប្រព័ន្ធទឹកស្អាត | ០ | ០% |
| ប្រព័ន្ធភ្លើងអគ្គិសនីកម្ពុជា | ៤ | ៨% |
| ប្រព័ន្ធភ្លើងអគ្គិសនីផ្សេងៗ | ៤ | ៨% |
| ផ្លូវដី (ផ្លូវចម្បង) | ៣៨ | ៥៦% |
| ផ្លូវបេតុង ឬផ្លូវកៅស៊ូ | ១៦ | ៣២% |

មានតែអ្នកផ្ដល់បទសម្ភាសដែលមកពីសហគមន៍ចំនួន ១១ប៉ុណ្ណោះ ដែលគេផ្ដល់ ឬទទួលបានអាហារ ទឹក និងអនាម័យភ្លាមៗនៅពេលពួកគេទៅដល់តំបន់តាំងទីលំនៅថ្មី។ តម្រូវការចាំបាច់ជាមូលដ្ឋានទាំងនេះ មានសារៈសំខាន់ជាខ្លាំងសម្រាប់ការរស់នៅក្នុងជីវិត ដូចនេះត្រូវធានាថាមាននៅគ្រប់តំបន់តាំងទីលំនៅថ្មីទាំងអស់ ដោយមិនគិតថាមានសំណងផ្សេងទៀតដូចជា ដី ឬប្រាក់ឡើយ។ នៅក្នុងករណីភាគច្រើន សហគមន៍ត្រូវទិញទឹកធុងធំៗពីរថយន្តដឹកទឹកលក់ ដើម្បីប្រើប្រាស់។

លើសពីនេះទៅទៀត អ្នកផ្ដល់បទសម្ភាសដែលមកពីសហគមន៍ចំនួន៣៣ ប្រាប់ថាក្ដីបារម្ភចម្បងរបស់ពួកគេគឺកង្វះឱកាសរកប្រាក់ចំណូលនៅពេលទៅរស់នៅទីកន្លែងថ្មីលើកដំបូង។ ដំណោះស្រាយល្អបំផុតចំពោះបញ្ហានេះគឺអាជ្ញាធរគួរផ្ដល់ដំណឹងពីការបណ្ដេញចេញឱ្យបានយូរបន្តិច ដើម្បីពួកគេអាចគ្រប់គ្រងប្រាក់ចំណូលរបស់ខ្លួនសម្រាប់ត្រៀមក្នុងការតាំងទីលំនៅថ្មី។ អ្នកផ្ដល់បទសម្ភាសស្ទើរតែទាំងអស់ស្នើសុំឱ្យអាជ្ញាធររៀបចំតំបន់តាំងទីលំនៅថ្មីឱ្យស្ថិតនៅក្បែរទីប្រជុំជន ឬជាតំបន់ដែលមានសក្ដានុពលខាងសេដ្ឋកិច្ច។

### ៤.៤.៤.ការរៀបចំ និងភាពអាចរស់នៅបាននៅក្នុងឆ្នាំ២០១៩

**តារាងទី ៨៖** ការប្រៀបធៀបលក្ខណៈនៃតំបន់តាំងទីលំនៅថ្មីនៅពេលសហគមន៍មកដល់ដំបូង និងនៅឆ្នាំ២០១៩

| ការផ្តល់ឱ្យ (កំពុងប្រើប្រាស់) ក្នុងឆ្នាំ ២០១៩ | ចំនួនសហគមន៍ដែលទទួលបានពេលពួកគេមកដល់ | ចំនួនសហគមន៍ដែលទទួលបាននៅក្នុងឆ្នាំ២០១៩ | ភាគរយនៃសហគមន៍សរុបដែលទទួលបាននៅត្រឹមឆ្នាំ២០១៩ |
|---|---|---|---|
| លំនៅឋាន | ៨ | ៥០ | ១០០% |
| កម្មសិទ្ធិ | ២៨ | ២ប្លង់រឹង ឬ២៤ប្លង់ទន់ | ៥២% មានសិទ្ធិកាន់កាប់ (ទទួលបានប្លង់កម្មសិទ្ធិ) |
| ទឹកស្អាតបរិភោគ | ៥ | ៥០ | ១០០% |
| ប្រព័ន្ធលូទឹកស្អុយ | ៣ | ៣៤ | ៦៨% |
| ថាមពលសម្រាប់ចម្អិនអាហារ | ២ | ៥០ | ១០០% |
| ប្រព័ន្ធសម្រាប់បំភ្លឺ និងកំដៅ | ០ | ៥០ | ១០០% |
| កន្លែងអនាម័យ(មិនរាប់បញ្ចូលបន្ទប់ទឹក) | ១ | ៥០ | ១០០% |
| កន្លែងសម្រាប់ស្តុកអាហារ | ០ | ៥០ | ១០០% |
| ទីតាំងចោលសំរាម | ១ | ៣៦ | ៧២% |
| សេវាសុខភាព (ក្នុងចម្ងាយសមរម្យ) | ៩ | ៩ | ១៨% |
| សាលារៀន (ក្នុងចម្ងាយសមរម្យ) | ១៣ | ៥០ | ១០០% |
| ភ្លើងបំភ្លឺដងផ្លូវ | ៤ | ៥ | ១០% |
| ប្រព័ន្ធទឹកស្អាត (PPWSA) | ០ | ៤៥ | ៩០% |
| ប្រព័ន្ធភ្លើង (EDC) | ៤ | ៥០ | ១០០% |
| ផ្លូវដី | ៣៨ | ១០ | ២០% |
| ផ្លូវបេតុង ឬផ្លូវកៅស៊ូ | ១៦ | ៤០ | ៨០% |

តារាងទី៨ និងក្រាហ្វិចទី៣ បានបង្ហាញថាការរៀបចំតំបន់តាំងទីលំនៅថ្មីនៅក្នុងឆ្នាំ២០១៩ មានភាពល្អប្រសើរច្រើនបើប្រៀបធៀបទៅនឹងស្ថានភាពនៅពេលដែលសហគមន៍ទើបតែមកដល់លើកដំបូង។ ក្នុងករណីខ្លះភាពយឺតយ៉ាវក្នុងការផ្តល់សេវាជាមូលដ្ឋាន ដូចជា ទឹក-ភ្លើង គឺអាចដោយសារតែតំបន់ទាំងនោះស្ថិតនៅជាយក្រុងដែលមិនទាន់មានការផ្គត់ផ្គង់សេវាទាំងនោះបានទូលំទូលាយនៅឡើយ។ កង្វះខាតហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាននៅពេលប្រជាពលរដ្ឋមករស់នៅលើកដំបូង ក៏អាចដោយសារតែក្របខ័ណ្ឌរយៈពេលនៃការផ្តល់ដំណឹង និងការបណ្តេញចេញលឿនពេក និងកង្វះកញ្ចប់ថវិកាសម្រាប់រៀបចំតំបន់តាំងលំនៅថ្មីដោយរាជរដ្ឋាភិបាល ឬអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល។ ទោះជាយ៉ាងណាក៏ដោយ គេសង្កេតឃើញមានភាពខុសគ្នាខ្លាំងរវាងការផ្តល់សេវាមូលដ្ឋាននៅក្នុងតំបន់តាំងទីលំនៅថ្មីនៅពេលសហគមន៍មករស់នៅលើកដំបូង និងក្រោយពេលតាំងទីលំនៅអស់រយៈពេលជាច្រើនឆ្នាំ។ រាជរដ្ឋាភិបាលគួរយកចិត្តទុកដាក់ខ្ពស់ចំពោះតំបន់ទាំងនេះ ព្រោះវាអាចជះឥទ្ធិពលដល់សហគមន៍ដែលត្រូវផ្លាស់ទៅតាំងទីលំនៅថ្មីនៅថ្ងៃអនាគត។

ក្រាហ្វិចទី ៣៖ ភាពអាចរស់នៅបាននៅពេលមកដល់ (ពណ៌ក្រហម) និងនៅឆ្នាំ ២០១៩ (ពណ៌បៃតង)




### ៤.៤.៥. ការយល់ឃើញរបស់សហគមន៍ពីភាពខុសគ្នារវាងទីតាំងថ្មី និងទីតាំងចាស់

ដូចដែលមានបង្ហាញក្នុងក្រាហ្វិចទី៣ តំបន់តាំងទីលំនៅថ្មីសព្វថ្ងៃនេះទទួលបានការផ្គត់ផ្គង់សេវាសាធារណៈ និងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធច្រើនជាងមុនពេលដែលពួកគេទើបមករស់នៅដំបូង។ អ្នកផ្តល់បទសម្ភាសជាច្រើន យល់ស្រប ថាទីតាំងដែលពួកគេរស់នៅបច្ចុប្បន្ន មានស្ថានភាពល្អជាងមុនពេលពួកគេទើបមកដល់ដំបូង ប៉ុន្តែប្រជាពលរដ្ឋភាគច្រើនមិនយល់ស្របថា ទីតាំងដែលគេរស់នៅបច្ចុប្បន្នមានភាពល្អប្រសើរជាងទីតាំងដែលពួកគេត្រូវបានគេបណ្តេញចេញនោះទេ។ មូលហេតុចម្បងនោះគឺដោយសារឱកាសផ្នែកសេដ្ឋកិច្ចដែលពួកគេទទួលបាននៅទីតាំងចាស់។

លើសពីនេះ ប្រជាពលរដ្ឋមួយចំនួន បានចាកចេញពីតំបន់តាំងទីលំនៅថ្មី ទៅរស់នៅតំបន់ល្អជាងនេះ។ នៅក្នុងតំបន់១២ទីតាំងប្រជាពលរដ្ឋដែលផ្លាស់មកពីទីតាំងចាស់ជាច្រើនបានប្រាប់ថាលែងជាអ្នកស្រុកក្នុងតំបន់តាំងទីលំនៅថ្មីដោយសារបានផ្លាស់ទៅរស់នៅកន្លែងផ្សេង។ ស្ថានភាពនេះបណ្តាលមកពីមូលហេតុផ្សេងៗ ប៉ុន្តែមូលហេតុខ្លះ គឺអវិជ្ជមាន ដូចជាបញ្ហាលិចទឹក ឬបញ្ហាជំពាក់ប្រាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

មានករណីចំនួន២ អ្នកផ្តល់បទសម្ភាសបានប្រាប់ថា បំណុលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានបង្ខំឱ្យប្រជាពលរដ្ឋមួយចំនួនលក់ផ្ទះសម្បែងរបស់ពួកគេហើយចាកចេញ ប៉ុន្តែរឿងនេះមិនត្រូវបានបញ្ជាក់ដោយអ្នកស្រាវជ្រាវ និងពីអតីតប្រជាពលរដ្ឋនៅទីនោះទេ។



ផ្លូវបេតុងក្នុងសហគមន៍ (ថតដោយអង្គការសមាគមធាងត្នោត ឆ្នាំ២០១៩)

**តារាងទី ៩៖** ចម្ងាយពីតំបន់តាំងទីលំនៅថ្មី ទៅទីតាំងសំខាន់ៗ

| ទីតាំង | ចម្ងាយពីសហគមន៍ | | |
|---|---|---|---|
| | តិចជាង១ គីឡូម៉ែត្រ | ពី ១ទៅ៥ គីឡូម៉ែត្រ | ពី៥ គីឡូម៉ែត្រឡើងទៅ |
| ផ្សារ | ២៩ | ១៩ | ៦ |
| សេវាសុខាភិបាលសាធារណៈ | ២០ | ៣២ | ២ |
| វត្តអារាម (ឬតំបន់សាសនាផ្សេងទៀត ដែលពាក់ព័ន្ធ) | ៥៤ | 0 | 0 |
| សាលាបឋមសិក្សារបស់រដ្ឋ | ៤០ | ១៤ | 0 |
| សាលាអនុវិទ្យាល័យរបស់រដ្ឋ | ១៣ | ៤៣ | ៦ |
| ចំនុចកណ្តាលរាជធានីភ្នំពេញ (វត្តភ្នំ) | 0 | 0 | ៥៤ (២៣ កន្លែង មានចម្ងាយលើស ១០គីឡូម៉ែត្រ ហើយ ២៧កន្លែង មានចម្ងាយលើសពី ១៥គីឡូម៉ែត្រ) |

ក្នុងករណីភាគច្រើន ចម្ងាយទៅកាន់សេវាសាធារណៈ ដូចជាសាលារៀន មណ្ឌលសុខភាពមិនមែនជាបញ្ហានោះទេ ដោយសារមានសហគមន៍ជាច្រើននៅក្បែរនោះ។ នៅក្នុងករណីមួយ ទីតាំងលំនៅថ្មីស្ថិតក្នុងតំបន់ដែលមិនមានសាលាបឋមសិក្សានៅក្បែរ ដែលជាបញ្ហាចម្បងសម្រាប់ប្រជាពលរដ្ឋដែលមកតាំងទីលំនៅថ្មីនៅទីនោះ។ នៅក្នុងស្ថានភាពបែបនេះហើយដែលទីតាំងនៃតំបន់តាំងទីលំនៅថ្មីគឺមានសារៈសំខាន់ ដើម្បីធានានូវការបំពេញបទដ្ឋានលំនៅឋានសមរម្យ។ លទ្ធភាពទទួលបានសេវាសាធារណៈនានា ដូចជាសាលារៀនគឺជាគោលការណ៍មូលដ្ឋាននៃលំនៅឋានសមរម្យ។[៦៩] ការដែលមិនមានសេវាដឹកជញ្ជូនសាធារណៈដើម្បីធានាថាកុមារអាចធ្វើដំណើរមកដល់សាលារៀនដែលនៅឆ្ងាយបាន មានន័យថាតំបន់តាំងទីលំនៅថ្មីនៅឆ្ងាយពីសេវាសាធារណៈជាមូលដ្ឋានអាចធ្វើឱ្យសហគមន៍ដែលផ្លាស់មកតាំងនៅទីនោះប្រឈមមុខនឹងការរស់នៅដាច់ឆ្ងាយកាន់តែខ្លាំង និងរារាំងដល់ការទទួលបាននូវសិទ្ធិមនុស្សដទៃទៀត។

បញ្ហាជាច្រើនត្រូវបានចោទនៅត្រង់ថាតំបន់តាំងទីលំនៅថ្មី នៅឆ្ងាយពីកណ្តាលទីក្រុង។ ក្នុងចំណោមតំបន់តាំងទីលំនៅថ្មីចំនួន៥៤កន្លែង មានចំនួន៤កន្លែង មានចម្ងាយលើសពី៥គីឡូម៉ែត្រ ពីតំបន់កណ្តាលទីក្រុងហើយចំនួន ២៣កន្លែងមានចម្ងាយលើសពី ១០គីឡូម៉ែត្រ និងចំនួន ២៧កន្លែងមានចម្ងាយលើសពី ១៥គីឡូម៉ែត្រ។ នៅតំបន់តាំងទីលំនៅថ្មី១ បញ្ហានេះ មិនមែនជាចំនុចអវិជ្ជមាននោះទេ ដោយសារទីតាំង ឬសមាជិកសហគមន៍ទទួលបានដីស្រែ ហើយសមាជិកសហគមន៍ភាគច្រើនគឺជាកសិករ។ ទោះជាយ៉ាងណាក៏ដោយភាគច្រើននៃករណីទាំងនេះ បញ្ហានៃការតាំងទីលំនៅនៅខណ្ឌខាងក្រៅគឺពាក់ព័ន្ធនឹងការកាត់បន្ថយឱកាសនៃការរកប្រាក់ចំណូល និងគុណភាពសិក្សា។ លើសពីនេះ សមាជិកសហគមន៍ភាគច្រើន ជាពិសេសស្ត្រីបានក្លាយជាកម្មការិនីរោងចក្រកាត់ដេរ និងត្រូវចំណាយពេលធ្វើដំណើរទៅកន្លែងធ្វើការឆ្ងាយអំឡុងពេលយប់ងងឹត។

[៦៩] អង្គការសហប្រជាជាតិ ២០០៩ "ប័ណ្ណព័ត៌មានលេខ២១ សិទ្ធិមនុស្សក្នុងការទទួលបានលំនៅឋានសមរម្យ"

### ៤.៤.៦. ចម្ងាយរវាងតំបន់តាំងទីលំនៅចាស់ និងតំបន់តាំងទីលំនៅថ្មី

ក្រៅពីខកចិត្តដោយសារតំបន់តាំងទីលំនៅថ្មីស្ថិតនៅក្រៅទីក្រុង ឬនៅជាយក្រុងសហគមន៍ជាច្រើនក៏តែងតែបង្ហាញអារម្មណ៍មិនសុខចិត្ត ព្រោះពួកគេត្រូវរស់នៅឆ្ងាយពីតំបន់ដែលពួកគេធ្លាប់រស់នៅពីមុន បើទោះជាតំបន់ចាស់នោះមិនស្ថិតនៅកណ្តាលក្រុងភ្នំពេញក៏ដោយ។ មូលហេតុនៃការខកចិត្តមានច្រើនខុសៗគ្នា អ្នកផ្តល់បទសម្ភាសមួយចំនួនបានលើកហេតុផលថា ពួកគេធ្វើអាជីវកម្មក្នុងតំបន់ដែលពួកគេរស់នៅពីមុនហើយពួកគេព្យាយាមរក្សាអាជីវកម្មនោះ ប៉ុន្តែពួកគេត្រូវបង្កើនការចំណាយជាប្រចាំថ្ងៃ ដោយសារតែត្រូវធ្វើដំណើរឆ្ងាយជាងមុនពីផ្ទះបច្ចុប្បន្ន។ សមាជិកសហគមន៍ខ្លះទៀត បានប្រាប់ថាពួកគេចូលចិត្តរស់នៅក្នុងតំបន់ពីមុន ដោយសារទំនាក់ទំនងល្អជាមួយអ្នកជិតខាង ឬភាពងាយស្រួលធ្វើដំណើរទៅក្នុងទីក្រុង ដែលទាំងនេះពួកគេបានប្រាប់ថាមិនមាននៅទីតាំងថ្មី។

### ៤.៤.៧. សុវត្ថិភាព និងសន្តិសុខអំឡុងពេលផ្លាស់ទីតាំងលំនៅថ្មី និងនៅតំបន់តាំងទីលំនៅថ្មី

អ្នកផ្តល់បទសម្ភាសដែលមកពីសហគមន៍ចំនួន១២ បានប្រាប់ថា តំបន់តាំងទីលំនៅថ្មីបច្ចុប្បន្ន មិនមានសុវត្ថិភាពនោះទេ។ សហគមន៍មួយចំនួនតូចបានបង្ហាញថានេះបណ្តាលមកពីមានបទល្មើសពាក់ព័ន្ធនឹងគ្រឿងញៀន ប៉ុន្តែសហគមន៍ភាគច្រើន និយាយថាពួកគេបារម្ភពីបញ្ហាចោរកម្មនៅពេលធ្វើដំណើរចេញចូលសហគមន៍។ លើសពីនេះ ពួកគេក៏បានលើកឡើងពីការព្រួយបារម្ភមិនអាចសងបំណុលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងការភ័យខ្លាចគេបណ្តេញចេញជាថ្មីម្តងទៀត ។

---

*"ខ្ញុំគ្មានកន្លែងផ្សេងដែលអាចទៅរស់នៅបានទេ។ ខ្ញុំរស់នៅទីនេះ ខ្ញុំអាចរកលុយបាន។"*

---

ការព្រួយបារម្ភអំពីការបណ្តេញចេញជាថ្មីម្តងទៀត មិនមែនមិនសមហេតុផលនោះទេ សម្រាប់ប្រជាពលរដ្ឋសហគមន៍ចំនួន២៤ ដែលនៅមិនទាន់មានប្លង់កម្មសិទ្ធិ។ ការបណ្តេញចេញ និងការផ្លាស់ទីលំនៅជាច្រើនដង ធ្លាប់កើតឡើងជាច្រើនសាររួចមកហើយ ដោយគ្រួសារទាំងនោះ ជាទូទៅត្រូវបានគេបង្ខំឱ្យឆ្លងកាត់បទពិសោធន៍រន្ធត់សារជាថ្មី បន្ទាប់ពីពួកគេបានតាំងទីលំនៅ នៅតំបន់ថ្មី។ នៅក្នុងករណីមួយ ស្ត្រីម្នាក់ត្រូវបានគេបណ្តេញចេញពីតំបន់ចាស់នៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ដើម្បីយកទៅសាងសង់ជាមូលដ្ឋានកងទ័ពមួយ។ អ្នកស្រីមិនបានទទួលសំណងអ្វីឡើយ ហើយក៏មិនបានទទួលដីនៅតំបន់តាំងទីលំនៅថ្មីណាមួយឡើយ។ នៅក្នុងស្ថានភាពនៃការភ័យខ្លាច និងអស់សង្ឃឹម អ្នកស្រី បានទៅរស់នៅតាមមាត់បឹងជាកន្លែងដែលអ្នកស្រីរស់នៅជិត ២០ឆ្នាំ មុនពេលអ្នកស្រី ត្រូវបានគេបណ្តេញចេញជាថ្មីម្តងទៀត។ ដោយមិនអាចទទួលបានដីនៅតំបន់តាំងទីលំនៅថ្មីណាមួយ ឬមិនទទួលបានសំណងជាលើកទីពីរនេះ អ្នកស្រី និងក្រុមគ្រួសារបានទៅរស់នៅតាមមាត់បឹងជាថ្មីម្តងទៀត។ នៅពេលសាកសួរថា ហេតុអ្វីអ្នកស្រីនៅតែទៅរស់នៅតំបន់ដែលអាចធ្វើឱ្យអ្នកស្រីងាយរងគ្រោះពីការបណ្តេញចេញជាថ្មីម្តងទៀត? អ្នកស្រីបានឆ្លើយតបថា៖ "ខ្ញុំមិនមានកន្លែងផ្សេងដែលអាចទៅរស់នៅបានទេ។ ខ្ញុំរស់នៅទីនេះ ខ្ញុំអាចរកលុយបាន"។ អំឡុងពេលនៃការបណ្តេញចេញ អ្នកស្រីត្រូវបានអាជ្ញាធរក្នុងតំបន់ប្រាប់ថា អ្នកស្រីមិនអាចនិយាយជាមួយអង្គការមិនមែនរដ្ឋាភិបាល ឬអ្នកសារព័ត៌មានទេ ព្រោះពួកអ្នកទាំងនោះ មិនអាចជួយអ្នកស្រីបានឡើយ។ អាជ្ញាធរទាំងនោះ ក៏បាននិយាយថាប្រសិនបើចាំបាច់ពួកគេនឹងកំទេចផ្ទះរបស់អ្នកស្រី បើអ្នកស្រីមិនព្រមចាកចេញ។ ដោយប្រឈមមុខនឹងស្ថានភាពនេះ អ្នកស្រីបានសម្រេចចិត្តចាកចេញដោយខ្លួនឯង ដើម្បីកុំឱ្យមានការបំផ្លាញរបស់ទ្រព្យសម្បត្តិ និងផ្ទះដែលបានផ្តល់ទីជម្រកដល់កូនបីនាក់របស់អ្នកស្រី។



គុណភាពលំនៅឋានក្នុងសហគមន៍ (ថតដោយអង្គការសមាគមធាងត្នោត ឆ្នាំ២០១៩)

### ៤.៤.៨. បំណុល

អ្នកផ្ដល់បទសម្ភាសមួយចំនួនបានប្រមាណថា កម្រិតនៃការជំពាក់បំណុល នៅក្នុងតំបន់តាំងទីលំនៅថ្មីរបស់ពួកគេគឺខ្ពស់ខ្លាំង។ គួរកត់សម្គាល់ថាកម្រិតនេះគឺជាការប៉ាន់ស្មានប៉ុណ្ណោះ និងមិនមែនជាសេចក្ដីថ្លែងការណ៍អំពីការពិតដែលមានការបញ្ជាក់រស់នៅក្នុងកម្រិតគ្រួសារនោះទេ។ ភាគច្រើនក្នុងតំបន់តាំងទីលំនៅថ្មី ប្រជាពលរដ្ឋបាននិយាយថាមានកម្រិតនៃការជំពាក់បំណុលធ្ងន់ធ្ងរ ហើយប្រជាពលរដ្ឋជាច្រើននាក់បង្ហាញនូវអារម្មណ៍ភ័យខ្លាច និងពិបាកចិត្តក្នុងការសងលុយត្រឡប់ទៅវិញ។ អ្នកផ្ដល់បទសម្ភាសជាច្រើនបានយល់ស្របថា ពួកគេនឹងមិនត្រូវបានគេឱ្យខ្ចីប្រាក់នោះទេ ប្រសិនបើពួកគេមិនមានប័ណ្ណកម្មសិទ្ធិដីធ្លីដែលពួកគេបានទទួលតាមរយៈនីតិវិធីនៅទីតាំងលំនៅថ្មី ហើយមួយចំនួនទៀត បានសង្កត់ធ្ងន់ថាការផ្ដល់ប័ណ្ណកម្មសិទ្ធិដើម្បីទទួលបានកម្ចីគឺជាកត្តាសំខាន់មួយដែលជំរុញឱ្យពួកគេទាមទារឱ្យមានការផ្ដល់ប័ណ្ណកម្មសិទ្ធិដីធ្លី នៅក្នុងកញ្ចប់សំណងនៅទីតាំងថ្មី។ នៅក្នុងករណីភាគច្រើន "ប្លង់រឹង" ត្រូវបានគេប្រើប្រាស់ដើម្បីដាក់ជាទ្រព្យបញ្ចាំក្នុងការខ្ចីប្រាក់។ ប៉ុន្តែនៅក្នុងករណីខ្លះ "ប្លង់ទន់" ឬវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុក៏អាចជាទ្រព្យបញ្ចាំសម្រាប់ការខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផងដែរ។

លើសពីនេះ អ្នកផ្ដល់បទសម្ភាសជាច្រើនបាននិយាយថា ពួកគេត្រូវដាក់តម្កល់សៀវភៅគ្រួសារ និងអត្តសញ្ញាណប័ណ្ណច្បាប់ដើម នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលឯកសារទាំងនោះនឹងត្រូវបានគេប្រគល់ត្រឡប់មកវិញ នៅពេលដែលពួកគេសងប្រាក់កម្ចីអស់។ គួរកត់សម្គាល់ផងដែរថាអត្តសញ្ញាណប័ណ្ណ និងសៀវភៅគ្រួសារគឺជាឯកសារសំខាន់សម្រាប់ទទួលបានអត្ថប្រយោជន៍ផ្នែកសង្គមកិច្ច និងសិទ្ធិមនុស្ស ដែលរួមមានសេវាសុខាភិបាល និងសិទ្ធិបោះឆ្នោត។ ការគ្រប់គ្រងឯកសារទាំងនោះដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអាចជាការល្មើសច្បាប់ ហើយច្បាស់ណាស់គឺជាកត្តាមួយដែលរួមចំណែកក្នុងការបង្កើតឱ្យមានអតុល្យភាពនៃអំណាចរវាងសមាជិកសហគមន៍ ដែលភ័យខ្លាចបាត់បង់ឯកសាររបស់ពួកគេ ជាមួយនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

**តារាងទី ១០៖** ការប៉ាន់ប្រមាណការជំពាក់បំណុល (សហគមន៍ទាំងមូល)

| ប៉ាន់ស្មានគិតជាភាគរយនៃគ្រួសារក្នុងសហគមន៍ ដែលជំពាក់បំណុល | តំបន់តាំងទីលំនៅថ្មី |
|---|---|
| ៣០%-៥០% | ០ |
| ៥១%-៧០% | ១០ |
| ៧១%-៩០% | ២០ |
| ៩១%+ | ១៧ |
| **ចំនួនសរុប** | **៤៧** |

**ករណីសិក្សាៈ បំណុល និងការគំរាមកំហែង**[៧០]

*គម្រោងស្ដារឡើងវិញនូវផ្លូវដែកនៅក្នុងប្រទេសកម្ពុជា ដែលត្រូវបានអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា និងទទួលបានជំនួយមូលនិធិពីធនាគារអភិវឌ្ឍន៍អាស៊ី និងទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិបានប៉ះពាល់ដល់ប្រជាពលរដ្ឋជាច្រើនគ្រួសារដែលរស់នៅតាមបណ្ដោយផ្លូវដែក និងធ្វើឱ្យប្រជាពលរដ្ឋជាច្រើនគ្រួសារផ្លាស់ទៅតាំងទីលំនៅថ្មីដែលឆ្ងាយពីកន្លែងដែលពួកគេធ្វើការងារ។ នៅក្នុងតំបន់តាំងទីលំនៅថ្មីមួយគ្រួសារជាច្រើនត្រូវប្រឈមមុខនឹងបញ្ហាជាច្រើន ដូចជាការទទួលបានសំណងមិនសមរម្យ កង្វះការប្រឹក្សាផ្នែកច្បាប់ ប្រាក់ចំណូលក្នុងគ្រួសារធ្លាក់ចុះ និងប្រាក់ចំណាយកើនឡើងទៅលើថ្លៃធ្វើដំណើរ។ ប្រាំបីខែបន្ទាប់ពីមកដល់តំបន់តាំងទីលំនៅថ្មី សហគមន៍ជាច្រើន បានទៅរកអ្នកផ្ដល់ប្រាក់កម្ចីដោយដាក់វិញ្ញាបនប័ត្រសម្គាល់ម្ចាស់កម្មសិទ្ធិដីធ្លីរបស់ពួកគេ ជាទ្រព្យបញ្ចាំ។ នៅក្នុងករណីជាច្រើន ប្រាក់កម្ចីត្រូវបានយកដើម្បីសាងសង់ផ្ទះ។ ការបំភិតបំភ័យពីអ្នកចងការប្រាក់ត្រូវបានគេប្រាប់ថា តែងតែកើតមានឡើង ដោយអ្នកចងការប្រាក់គំរាមកំហែងថានឹងយកដីរបស់អ្នកខ្ចី ប្រសិនបើមិនអាចសងប្រាក់មកវិញ។*

### ៤.៥. យេនឌ័រ

សំឡេងរបស់ស្ត្រីត្រូវបានគេរួមបញ្ចូលនៅក្នុងដំណើរការនៃការបណ្ដេញចេញ ប៉ុន្តែមិនច្បាស់ថាវាមានដំណើរការដូចម្ដេច ហើយមានអ្នកផ្ដល់បទសម្ភាសដែលមកពីសហគមន៍ចំនួន៥ បានប្រាប់ថាស្ត្រីមិនត្រូវបានគេឱ្យចូលរួមគ្រប់គ្រាន់នៅក្នុងដំណើរការនោះទេ។ នៅក្នុងសហគមន៍មួយ ស្ត្រីមិនត្រូវបានគេឱ្យចូលរួមក្នុងដំណើរការទាល់តែសោះ។ អំឡុងពេលការពិគ្រោះយោបល់មួយ ក្នុងចំណោមការពិគ្រោះយោបល់មួយចំនួនដែលបានធ្វើឡើងមានតែបុរសប៉ុណ្ណោះដែលត្រូវបានអញ្ជើញឱ្យចូលរួម។នៅក្នុងករណីមួយផ្សេងទៀត ស្ត្រីម្នាក់បានលើកឡើងថា អ្នកស្រីមិនបានចូលរួមក្នុងកិច្ចប្រជុំជាមួយអាជ្ញាធរដោយសារការភ័យខ្លាច។

លើសពីនេះ ស្ត្រីជាច្រើន ប្រឈមមុខនឹងការលំបាកជាច្រើន ដែលបណ្ដាលមកពីដំណើរការនៃការបណ្ដេញចេញ និងការផ្លាស់ទីតាំងលំនៅថ្មី និងជាទូទៅទទួលរងនូវការពិបាកចិត្ត និងការព្រួយបារម្ភរយៈពេលវែងដោយសារដំណើរការនោះ និងដោយសារបទពិសោធន៍ដែលកូនៗរបស់ពួកគេបានឆ្លងកាត់។ នៅក្នុងករណីជាច្រើន កុមារបានឈប់រៀន ក្នុងអំឡុងពេល ឬក្រោយពេលនៃការបណ្ដេញចេញ និងការផ្លាស់ទីតាំងលំនៅថ្មី ដែលក្លាយជាបន្ទុកបន្ថែមដល់ម្ដាយដែលជាអ្នកមើលថែទាំពួកគេ។ ស្ត្រីដែលមានកូនបាននិយាយថាពួកគេមានអារម្មណ៍ពិបាកចិត្តបន្ថែមទៀតនៅដែលពួកគេគឺជាមនុស្សតែម្នាក់នៅក្នុងគ្រួសារដែលត្រូវទទួលបន្ទុកចិញ្ចឹមកូន។ នៅតំបន់តាំងទីលំនៅថ្មីស្ត្រីមួយចំនួន បាននិយាយថាពួកគេមានអារម្មណ៍ថាពួកគេគឺជាអ្នកទទួលខុសត្រូវចំពោះភាពក្រីក្រដែលក្រុមគ្រួសាររបស់ពួកគេបានជួបប្រទះ ព្រោះនៅក្នុងសង្គមការរៀបចំទុកដាក់ផ្ទះសម្បែងគឺជាតួនាទីរបស់ស្ត្រី ដែលនេះគឺជាការគិតរបស់ស្ត្រីទាំងនោះផងដែរ។

តំបន់តាំងទីលំនៅថ្មីដែលមិនអាចរស់នៅបានក៏ផ្ដល់ផលប៉ះពាល់ដល់ស្ត្រីច្រើនជាងបុរសផងដែរ ដោយភាគច្រើននៃស្ត្រីទាំងនោះបានលើកឡើងពីការមានអារម្មណ៍តានតឹង នៅពេលពួកគេមកដល់តំបន់ទាំងនោះ ព្រោះតែតំបន់ទាំងនោះមិនមានបង្គន់អនាម័យ ឬបន្ទប់ទឹក។ ស្ត្រីមួយចំនួនបានប្រាប់ថា ពួកគេមានអារម្មណ៍ពិបាកចិត្តខ្លាំងនៅពេលដែលពួកគេត្រូវប្រើបង្គន់សាធារណៈ ហើយស្ត្រីមួយចំនួនផ្សេងទៀត ពន្យាពេលប្រើបង្គន់អនាម័យ ឬបន្ទប់ទឹកតាមដែលអាចធ្វើទៅបាន ឬរហូតដល់ពេលគ្មានមនុស្សនៅក្បែរ។ នៅក្នុងករណីខ្លះស្ត្រីជាច្រើនត្រូវចេញពីសហគមន៍របស់ពួកគេ ដើម្បីទៅបន្ទប់ទឹកដែលមានលក្ខណៈឯកជន។ ចម្ងាយដែលត្រូវដើរភាពងងឹតស្រយាលនៃតំបន់តាំងទីលំនៅថ្មី និងកង្វះបង្គោលភ្លើងបំភ្លឺផ្លូវសាធារណៈរួមចំណែកធ្វើឱ្យមានការភ័យខ្លាចដល់ស្ត្រី និងក្មេងស្រី។ បុរសក៏អាចជួបប្រទះនឹងបញ្ហាទាំងនេះដែរ ប៉ុន្តែមិនមានបុរសណាម្នាក់ នៅពេលផ្ដល់បទសម្ភាសបានលើកឡើងពីបញ្ហានេះនោះទេ។

---

[៧០] ដកស្រង់ចេញពីរបាយការណ៍របស់អង្គការសមាគមជាងត្នោត" ការបាត់បង់ដី" ឆ្នាំ២០១២ ។

លើសពីនេះស្ត្រីបានប្រាប់ថា ការរំលោភសេពសន្ថវៈ និងការភ័យខ្លាចនឹងទទួលរងអំពើហិង្សាគឺជាការព្រួយបារម្ភសំខាន់មួយនៅក្នុងតំបន់តាំងទីលំនៅថ្មី។ ដូចដែលបានកត់សម្គាល់ខាងលើ តំបន់តាំងទីលំនៅថ្មីតិចជាង ៥កន្លែងបច្ចុប្បន្នមានភ្លើងបំភ្លឺផ្លូវសាធារណៈ។ ស្ត្រីភាគច្រើនដែលមានការងារធ្វើនៅក្រៅផ្ទះ ធ្វើការនៅរោងចក្រ ហើយតែងតែមកដល់ផ្ទះនៅពេលយប់។ ស្ត្រីជាច្រើនបានលើកឡើងថាមានការភ័យខ្លាចអំពីគ្រោះថ្នាក់ចរាចរ និងអំពើរំលោភសេពសន្ថវៈ នៅពេលធ្វើដំណើរឆ្លងកាត់ស្ទើរគ្រប់សហគមន៍ដែលបានតាំងទីលំនៅថ្មី ដើម្បីទៅធ្វើការ និងត្រឡប់មកវិញ។ អំពើចោរកម្មត្រូវបានប្រាប់ដោយស្ត្រីជាច្រើន ថាបានកើតឡើងនៅតាមផ្លូវត្រឡប់មកផ្ទះវិញ នៅពេលយប់។ ស្ត្រី និងសមាជិកសហគមន៍ទូទៅបានលើកឡើងថាការបំភ្លឺផ្លូវសាធារណៈទាំងនៅក្នុង និងនៅតំបន់ជុំវិញសហគមន៍របស់ពួកគេគឺជាកត្តាសំខាន់ចម្បងមួយដែលធ្វើឱ្យពួកគេអាចមានអារម្មណ៍ថាមានសុវត្ថិភាព។

សហគមន៍មួយបានប្រាប់ថា មានអំពើរំលោភសេពសន្ថវៈ និងឃាតកម្មបានកើតឡើងលើស្ត្រី ២នាក់ដែលទំនងជាកើតឡើងនៅពេលយប់។ សហគមន៍បានយល់ស្របទាំងស្រុងថា ភ្លើងបំភ្លឺផ្លូវសាធារណៈ នៅតែខ្វះខាត ហើយពិតជាត្រូវការចាំបាច់នៅក្នុងតំបន់នោះ។

### ៤.៦. ការធ្វើឱ្យប្រសើរឡើងនូវដំណើរការទាំងនេះ

#### ៤.៦.១. សំឡេងរបស់ម្ចាស់សិទ្ធិ ស្តីពីការបណ្តេញចេញ និងការតាំងទីលំនៅថ្មី

នៅចុងបញ្ចប់នៃការសិក្សាស្រាវជ្រាវនេះ អ្នកផ្តល់បទសម្ភាសត្រូវបានសាកសួរពីរបៀប ដែលដំណើរការនៃការបណ្តេញចេញ និងការតាំងទីលំនៅថ្មី គួរត្រូវកែប្រែឱ្យប្រសើរឡើង។ ភាគច្រើននៃអ្នកផ្តល់បទសម្ភាសបានលើកឡើងថាការបណ្តេញចេញមិនត្រូវធ្វើឡើងដោយមិនមានការពិភាក្សាជាមុនឱ្យបានត្រឹមត្រូវនោះទេ។ និយមន័យនៃការពិភាក្សាត្រឹមត្រូវមានភាពខុសៗគ្នាទៅតាមសហគមន៍ ប៉ុន្តែភាគច្រើននៃសហគមន៍ទាំងនោះ យល់ស្របថាការពិគ្រោះយោបល់រវាងសហគមន៍ និងអាជ្ញាធរប្រកបដោយភាពស្មោះត្រង់។ ជាឧទាហរណ៍បញ្ជាក់ចំណុចនេះ នៅក្នុងករណីមួយចំនួនអ្នកផ្តល់បទសម្ភាសជាច្រើនបាននិយាយថា ពួកគេយល់ព្រមទៅនឹងការផ្លាស់ទីតាំងលំនៅថ្មី ប៉ុន្តែពួកគេមិនទទួលបានការពិគ្រោះត្រឹមត្រូវនោះទេ និងត្រូវបានគេបណ្តេញចេញដែលធ្វើឱ្យពួកគេមានការសោកសៅ និងអស់សង្ឃឹមយ៉ាងខ្លាំង នៅពេលពួកគេទៅរស់នៅនៅតំបន់តាំងទីលំនៅថ្មី។ ផ្ទុយទៅវិញ សហគមន៍ទាំងអស់ដែលបានផ្លាស់ទៅទីតាំងលំនៅថ្មី ដោយសារមានការគាំទ្រពីក្រុមសន្សំសហគមន៍ ឬអង្គការមិនមែនរដ្ឋាភិបាលបានប្រាប់ពីការពេញចិត្តកម្រិតខ្ពស់ ទោះបីជាតំបន់តាំងទីលំនៅថ្មីរបស់ពួកគេមិនមានស្ថានភាពល្អប្រសើរចំពោះទីតាំង និងភាពអាចរស់នៅបាន ជាងតំបន់ថ្មីរបស់សហគមន៍ផ្សេងទៀតក៏ដោយ។

នៅពេលនិយាយអំពីកត្តាសំខាន់បំផុតដែលគួរតែធ្វើការកែប្រែឱ្យប្រសើរឡើង នៅពេលផ្លាស់សហគមន៍ឱ្យទៅតាំងទីលំនៅថ្មី អ្នកផ្តល់បទសម្ភាសជាច្រើនហាក់ផ្តោតសំខាន់ទៅលើហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវថ្នល់ អនាម័យ (ពាក់ព័ន្ធនឹងប្រព័ន្ធលូ និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត) ភ្លើងបំភ្លឺផ្លូវក៏ដូចជាឱកាសផ្នែកសេដ្ឋកិច្ច។

អ្នកផ្តល់បទសម្ភាសជាច្រើនបាននិយាយថា ការផ្តល់ផ្ទះសម្បែងនៅតំបន់តាំងទីលំនៅថ្មីមិនដែលត្រូវបានគេពិចារណានោះហើយពួកគេគិតថា ពួកគេនឹងមិនទទួលបាន ឬមិនមានសិទ្ធិទទួលបានផ្ទះសម្បែងនោះទេ។ ការផ្តល់ផ្ទះសម្បែងមានតិចតួចណាស់ក្នុងប្រទេសកម្ពុជា ហើយពួកគេភាគច្រើនមានក្រុមសន្សំ ឬអាចខ្ចីកម្ចីដើម្បីសាងសង់ផ្ទះបាន។

លើសពីនេះ អ្នកផ្តល់បទសម្ភាសនជាច្រើនបានអំពាវនាវ ស្នើសុំឱ្យមានការផ្តល់សំណងឱ្យបានច្រើនជាងមុន រួមទាំងការផ្តល់កញ្ចប់សំណងដែលបូករួមទាំងការលំបាករបស់ពួកគេ ក្នុងការបាត់បង់ឱកាសសេដ្ឋកិច្ចដែលបណ្តាលមកពីការផ្លាស់ទីតាំងលំនៅថ្មី។ ក្នុងករណីមួយចំនួន សមាជិកសហគមន៍ស្នើសុំសំណងទាំងនេះសម្រាប់ឱ្យសហគមន៍រកការងារថ្មីធ្វើ ដោយសារសមាជិកសហគមន៍ជាច្រើននឹងត្រឡប់ទៅទីតាំងចាស់ដើម្បីធ្វើការងារដែលនេះនឹងបង្កឱ្យមានការចំណាយផ្ទាល់ខ្លួនច្រើនដល់ពួកគេ។

## ៥. សេចក្តីសន្និដ្ឋាន

របាយការណ៍នេះបានរកឃើញថានៅក្នុងករណីភាគច្រើន ការបណ្តេញចេញ និងការផ្លាស់ប្តូរទីតាំងលំនៅថ្មី មិនត្រូវបានធ្វើឡើងស្របនឹងគោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋាននោះទេ។ មានភស្តុតាងដែលបង្ហាញថាដំណើរការនៃការបណ្តេញចេញ កំពុងមានភាពប្រសើរឡើង ប៉ុន្តែភស្តុតាងនេះ នៅមិនទាន់ត្រូវបានគេបញ្ជាក់នោះទេ។ នៅក្នុងរយៈពេលពីរបីឆ្នាំខាងមុខការបណ្តេញចេញត្រូវបានគេរំពឹងទុកថានឹងបន្តកើតមានឡើង ហើយច្បាប់បច្ចុប្បន្ន ឬការអនុវត្ត នៅមិនទាន់អាចការពារសហគមន៍ពីការរំលោភសិទ្ធិមនុស្សនៅឡើយ។

ថ្មីៗនេះការបណ្តេញចេញបង្ហាញថាមានការថយចុះ ប៉ុន្តែដំណើរការនៃការបណ្តេញចេញនោះ មិនមានការកែប្រែឡើយ ការបណ្តេញចេញនៅតំបន់ជុំវិញបឹងតាមោកក្នុងឆ្នាំ២០១៩ មិនបានប្រើប្រាស់វិធីសាស្ត្រដោយផ្អែកលើគោលការណ៍សិទ្ធិមនុស្ស ហើយថ្មីៗនេះសហគមន៍ជាច្រើន ពួកគេនៅតែមិនទាន់ដឹងច្បាស់អំពីស្ថានភាពព័ត៌មានផ្លូវច្បាប់ និងការទទួលបាននូវឯកសារផ្លូវច្បាប់របស់សហគមន៍ពួកគេនោះទេ។

ករណីភាគច្រើននៃការបណ្តេញចេញត្រូវបានធ្វើឡើងក្រោមហេតុផលថា សហគមន៍បានកាន់កាប់ដីសាធារណៈរបស់រដ្ឋ។ នៅក្នុងករណីជាច្រើនមូលហេតុនេះអាចជាការពិត ប៉ុន្តែមានតែពីរករណីប៉ុណ្ណោះដែលមានការតវ៉ាជំទាស់តាមផ្លូវច្បាប់ទាក់ទងនឹងហេតុផលនេះ។ ការរកឃើញនេះបង្ហាញឱ្យឃើញនូវបញ្ហាដ៏ធំដែលប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា។ លើសពីនេះ វិធានការច្បាប់គួរតែត្រូវបានតាក់តែង និងអនុវត្តដើម្បីសម្រេចបាននូវលទ្ធផលកាន់តែល្អប្រសើរនៅក្នុងការអនុវត្តការបណ្តេញចេញ និងការផ្លាស់ទីតាំងលំនៅថ្មី។ ប៉ុន្តែគិតត្រឹមពេលចេញផ្សាយរបាយការណ៍នេះ មានតែសារាចរលេខ០៣ ប៉ុណ្ណោះ ដែលគ្រាន់តែជាសេចក្តីណែនាំ និងមិនមែនជាច្បាប់ត្រូវបានបង្កើត និងអនុវត្តឱ្យមានប្រសិទ្ធភាពបន្ថែមពីនេះ មានសហគមន៍តែមួយប៉ុណ្ណោះដែលបានប្រាប់ថាសារាចរនេះត្រូវបានគេប្រើប្រាស់នៅក្នុងដំណើរការនៃការបណ្តេញចេញ។

ការកត់សម្គាល់ជាវិជ្ជមានគឺថាតំបន់តាំងទីលំនៅថ្មីមានការអភិវឌ្ឍន៍គួរឱ្យកត់សម្គាល់ ទៅលើភាពដែលអាចរស់នៅបាន ប៉ុន្តែភាគច្រើននៃតំបន់ទាំងនេះ ទទួលបានស្ថានភាពដូចបច្ចុប្បន្ន ដោយត្រូវការរយៈពេលយូរឆ្នាំ ហើយនៅពេលសហគមន៍ទើបមកដល់ដំបូង តំបន់ទាំងនោះមិនមានស្ថានភាពល្អដូចសព្វថ្ងៃនោះទេ។ ស្ទើរពាក់កណ្តាលនៃតំបន់ទាំងនេះនៅមិនទាន់ទទួលបានសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី ហើយតំបន់ស្ទើរតែទាំងអស់ជំពាក់បំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាច្រើន។

អ្នកផ្តល់បទសម្ភាសបានអំពាវនាវមានការចូលរួមសម្រេចចិត្តបានច្រើនពីសហគមន៍ក្នុងដំណើរការនៃការបណ្តេញចេញ និងការផ្លាស់ប្តូរទីតាំងលំនៅថ្មី។ លើសពីនេះ ពួកគេបានអំពាវនាវមាននូវកញ្ចប់សំណងដែលល្អប្រសើរ និងការផ្តល់នូវសេវា និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈនានា នៅពេលសហគមន៍ទៅដល់តំបន់តាំងទីលំនៅថ្មី។ យ៉ាងតិចណាស់ មានការបណ្តេញចេញចំនួន៨ ដែលអាចមានការផ្លាស់ទីតាំងទីលំនៅថ្មីផងនោះ នឹងកើតមានឡើងនាឆ្នាំខាងមុខ។ ការរកឃើញនៃរបាយការណ៍នេះ បង្ហាញឃើញថាមានបញ្ហាលក្ខណៈជាប្រព័ន្ធនៅក្នុងដំណើរការបណ្តេញចេញដែលកើតមានជាច្រើនឆ្នាំកន្លងមកនេះ។ ប៉ុន្តែតាមរយៈការគ្រប់គ្រងឱ្យបានល្អ និងការអនុវត្តនូវសារាចរណែនាំលេខ០៣ ការបណ្តេញចេញអាចនឹងមានស្ថានភាពល្អប្រសើរសម្រាប់ផលប្រយោជន៍មនុស្សគ្រប់រូបនៅក្នុងរាជធានីភ្នំពេញ។

ជាចុងក្រោយ រាជរដ្ឋាភិបាលកម្ពុជាគួរតែប្តេជ្ញាក្នុងការស្រាវជ្រាវ ពិនិត្យទៅលើមូលហេតុចម្បងនៃការកាន់កាប់ដីសាធារណៈរបស់រដ្ឋដែលត្រូវបានកំណត់យ៉ាងច្បាស់ថាជាហេតុផលចម្បងនៃការបណ្តេញចេញ។ ប្រសិនបើរកឃើញថាមានសហគមន៍មួយចំនួនរស់នៅលើដីសាធារណៈរបស់រដ្ឋដោយសារការមិនយល់ច្បាប់ នោះរាជរដ្ឋាភិបាលគួរតែធ្វើការបញ្ជាក់។ ហើយប្រសិនបើរកឃើញថាពួកគេរស់នៅដីសាធារណៈរបស់រដ្ឋនោះ ដោយសារកំនើននៃសហគមន៍ ក្នុងនេះដែរ មានសហគមន៍មួយចំនួនក្នុងការស្រាវជ្រាវនេះ បានស្នើសុំថាធនធានរបស់រដ្ឋគួរតែផ្តោត

សំខាន់ទៅលើផែនការយុទ្ធសាស្ត្រលំនៅឋាន។ រាជរដ្ឋាភិបាលកម្ពុជា គួរព្យាយាមបំពេញនូវកាតព្វកិច្ចរបស់ខ្លួនក្នុងការលើកកម្ពស់សិទ្ធិលំនៅឋានដែលជាសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋកម្ពុជា តាមរយៈការលើកកម្ពស់គម្រោងលំនៅឋានសង្គមកិច្ច ការបញ្ជាក់ឱ្យបានច្បាស់នូវច្បាប់នានាពាក់ព័ន្ធនឹងការកាន់កាប់ដីសាធារណៈរបស់រដ្ឋ និងការធ្វើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីអនុញ្ញាតឱ្យប្រជាពលរដ្ឋកាន់តែអាចទទួលបាននូវសិទ្ធិក្នុងការទទួលបានយុត្តិធម៌។

## ៦. អនុសាសន៍

ដោយយោងតាមការរកឃើញនៃការសិក្សាស្រាវជ្រាវនេះ អនុសាសន៍មួយចំនួនដូចខាងក្រោមត្រូវបានលើកឡើងជូនដល់រាជរដ្ឋាភិបាលកម្ពុជា៖

### ច្បាប់ និងគោលនយោបាយ

១. ច្បាប់ដែលមានស្រាប់ស្តីពីការកាន់កាប់ទ្រព្យសម្បត្តិសាធារណៈ ត្រូវតែធ្វើការបញ្ជាក់ឱ្យបានច្បាស់លាស់ជាពិសេសពាក់ព័ន្ធនឹងលក្ខខណ្ឌចាំបាច់នានា អំពីទ្រព្យសម្បត្តិសាធារណៈ។ ប្រសិនបើពុំមានព័ត៌មានច្បាស់លាស់សហគមន៍នឹងមិនអាចសម្រេចចិត្តត្រឹមត្រូវបានទេ។

២. លើសពីនេះ ទិន្នន័យអំពីទ្រព្យសម្បត្តិសាធារណៈនៅទូទាំងប្រទេស គួរតែត្រូវបានផ្សព្វផ្សាយតាមប្រព័ន្ធអ៊ិនធឺណេត និងអាចរកបានជាសាធារណៈសម្រាប់ការពិនិត្យមើល និងការប្រឹក្សាយោបល់ជាមួយសហគមន៍ដែលរស់នៅលើតំបន់ដីសាធារណៈរបស់រដ្ឋ។

៣. ការអនុវត្តសារាចរណែនាំ លេខ០៣ បច្ចុប្បន្ន ដោយអាជ្ញាធរនៅក្នុងដំណើរការនៃការបណ្តេញចេញនៅមិនទាន់អស់ពីលទ្ធភាពនោះទេ ហើយត្រូវមានការខិតខំបន្ថែមក្នុងការធានាសម្រេចឱ្យបាននូវគោលបំណងសំខាន់នៃសារាចរនេះ។ របាយការណ៍នេះ ផ្តល់អនុសាសន៍ថា សារាចរណែនាំលេខ០៣ គួរតែ (១) ត្រូវបានត្រួតពិនិត្យឱ្យបានច្បាស់លាស់ ដោយស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានានូវការអនុវត្តស្របតាមសារាចរនេះ ឬ (២) ធ្វើឱ្យស្របទៅនឹងគោលនយោបាយស្តីពីការតាំងទីលំនៅថ្មី។

### ប្រព័ន្ធច្បាប់

១. ប្រព័ន្ធយុត្តិធម៌គួរតែទទួលបានកញ្ចប់ថវិកាច្រើនជាងនេះ ដើម្បីបង្កើនការផ្តល់សេវាជំនួយផ្នែកច្បាប់មានតែសហគមន៍ចំនួន២ ដែលបានតវ៉ានឹងការបណ្តេញចេញរបស់ពួកគេ តាមរយៈ បណ្តឹងទៅតុលាការគឺជាភស្តុតាងមួយដែលបង្ហាញថា ជំនួយផ្នែកច្បាប់នៅមិនទាន់មានគ្រប់គ្រាន់នៅឡើយសម្រាប់សហគមន៍ ហើយប្រព័ន្ធច្បាប់នៅមិនទាន់រៀបចំបានគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហានៃការបណ្តេញចេញនោះទេ។

២. ការធ្វើអស្សាមិករណ៍ និងដំណើរការនៃការបណ្តេញចេញត្រូវតែមានការបកស្រាយបញ្ជាក់បន្ថែម ហើយកញ្ចប់ថវិកាត្រូវតែមានទុកបម្រុង ដើម្បី ធានាថាមន្ត្រី រដ្ឋបាល និងតុលាការត្រៀមរួចរាល់ក្នុងការដោះស្រាយតាមនីតិវិធីច្បាប់នៃការបណ្តេញចេញដែលរួមមាន ការវាស់វែងដី ការវាយតម្លៃដី និងទ្រព្យសម្បត្តិ ការផ្តល់ជំនួយផ្នែកច្បាប់ និងការផ្តល់យោបល់ឯករាជ្យដល់បុគ្គលដែលរងការបណ្តេញចេញ និងដំណើរការនៃការប្រឹក្សាយោបល់ជាសាធារណៈ។ល។

## រាជរដ្ឋាភិបាល

១. រាជរដ្ឋាភិបាលកម្ពុជា និងសាលារាជធានីភ្នំពេញត្រូវតែប្រឹងប្រែង ដើម្បីធានាថាការគ្រប់គ្រងជាពិសេសការបណ្តេញចេញ និងការផ្លាស់ប្តូរទីតាំងលំនៅថ្មីត្រូវមានការចូលរួមពិភាក្សាជាសាធារណៈ។ ការខ្វះការពិគ្រោះយោបល់ជាមូលហេតុចម្បងនៃការមិនសប្បាយចិត្តនិងជាអ្វីដែលមិនគួរមើលរំលង នេះបើតាមការឆ្លើយរបស់ប្រជាសហគមន៍ដែលផ្តល់ការសម្ភាស។

២. ក្រៅពីការលើកឡើងរបស់សហគមន៍ អង្គការក្រៅរដ្ឋាភិបាល និងក្រុមអង្កេត ឬឃ្លាំមើលគួរតែត្រូវបានឱ្យមានការចូលរួមនៅក្នុងដំណើរការពិគ្រោះយោបល់ជាសាធារណៈ ដើម្បីធានាថាជាដំណើរការប្រកបដោយតម្លាភាព និងយុត្តិធម៌។

៣. តម្លាភាពគួរតែត្រូវបានបង្កើនដើម្បីធានាថាអ្នកពាក់ព័ន្ធទាំងអស់ អាចទទួលបានព័ត៌មានផ្សេងៗ និងមានភាពងាយស្រួលក្នុងការទំនាក់ទំនង។ រាជរដ្ឋាភិបាល និងសាលារាជធានីភ្នំពេញ ទទួលខុសត្រូវក្នុងការធានាឱ្យមានតម្លាភាព ក្នុងករណីដែលក្រុមហ៊ុន និងអ្នកពាក់ព័ន្ធឯកជនចូលរួមក្នុងដំនើរការបណ្តេញចេញ។

ទូរសព្ទទំនាក់ទំនង ៖ ០២៣ ៥៥៥ ១៩៦៤
គេហទំព័រ ៖ http://teangtnaut.org
សំឡេងទីក្រុង ៖ https://urbanvoicecambodia.net
ហ្វេសប៊ុក ៖ https://www.facebook.com/teangtnaut